ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ផែនការមេបច្ចេកវិទ្យាព័ត៌មាន ២០២១-២០២៥
# Information Technology Master Plan 2021-2025



ឆ្នាំ ២០២១

# មាតិកា


**មាតិកា** ............................................................ i

**អារម្ភកថា** ............................................................ v

**តារាងពាក្យកាត់** ............................................................ vii

**បញ្ជីរូបភាព** ............................................................ x

**១.សេចក្តីផ្តើម** ............................................................ 1

១.១.ទិដ្ឋភាពទូទៅ ............................................................ 1

១.២.ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ............................................................ 3

១.៣.អំពីបច្ចេកវិទ្យាព័ត៌មាន ............................................................ 6

១.៤.យុទ្ធសាស្រ្ត និង ផែនការសកម្មភាពប្រទាក់ក្រឡារបស់ កសហវ ............................................................ 6

**២.ស្ថានភាពបច្ចុប្បន្ននៃបច្ចេកវិទ្យាព័ត៌មានក្នុង កសហវ** ............................................................ 11

២.១.ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ............................................................ 11

២.១.១.មជ្ឈមណ្ឌលទិន្នន័យ ............................................................ 11

២.១.២.បណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង និង បណ្តាញអ៊ីនធឺណិត ............................................................ 13

២.១.៣.ឧបករណ៍បច្ចេកវិទ្យាព័ត៌មានសម្រាប់អ្នកប្រើប្រាស់ ............................................................ 14

២.២.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ............................................................ 15

២.២.១.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ............................................................ 16

២.២.២.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ............................................................ 18

២.២.៣.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ ............................................................ 21

២.២.៤.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ............................................................ 22

២.២.៥.ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ............................................................ 24

២.២.៦.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗ ............................................................ 24

២.៣.បណ្តាញទំនាក់ទំនង និង ប្រព័ន្ធផ្សព្វផ្សាយ ............................................................ 26

២.៣.១.គេហទំព័រ ............................................................ 26

២.៣.២.អ៊ីមែល ............................................................ 26

២.៣.៣.បណ្តាញទំនាក់ទំនងសង្គម ............................................................ 26

២.៣.៤.ប្រព័ន្ធសន្និសីទវីដេអូ ............................................................ 26

២.៤.អង្គភាព និង ធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មាន ............................................................ 28

២.៥.បញ្ហាប្រឈមនៃបច្ចេកវិទ្យាព័ត៌មាននៅក្នុង កសហវ ........ 28
២.៥.១.បញ្ហាប្រឈមពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ........ 28
២.៥.២.បញ្ហាប្រឈមពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ........ 30
២.៥.៣.បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មាន ........ 32
២.៥.៤.បញ្ហាប្រឈមផ្នែកគោលការណ៍ណែនាំ ស្តង់ដារ និង សន្តិសុខបច្ចេកវិទ្យាព័ត៌មាន ........ 32
២.៥.៥.បញ្ហាប្រឈមលើការប្រើប្រាស់កម្មវិធីសម្រាប់ទំនាក់ទំនងក្នុងការងារ និង កិច្ចប្រជុំ ........ 32
២.៦.ការវិភាគភាពខ្លាំង, ភាពខ្សោយ, កាលានុវត្តភាព និង ការគំរាមកំហែង ........ 33
**៣.ផែនការមេបច្ចេកវិទ្យាព័ត៌មាន** ........ 35
៣.១.ចក្ខុវិស័យ ........ 35
៣.២.គោលបំណង ........ 35
៣.៣.គោលដៅ និង សកម្មភាពគន្លឹះ ........ 35
៣.៤.ពង្រឹង និង បង្កើនសមត្ថភាព និង ស្ថិរភាពនៃហេដ្ឋារចនាសម្ព័ន្ធ និង ធនធាន IT ........ 38
៣.៤.១.ការផ្តួចផ្តើមក្នុងការរៀបចំសហមជ្ឈមណ្ឌលទិន្នន័យចែករំលែក ........ 38
៣.៤.២.បង្កើនធនធានប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ, ម៉ាស៊ីនមេ និង ឃ្លាំងផ្ទុកទិន្នន័យ ........ 39
៣.៤.៣.បង្កើនវិសាលភាព និង ភាពងាយស្រួលនៃការតភ្ជាប់ការប្រើប្រាស់ IT ........ 40
៣.៤.៤.ពង្រឹងការគ្រប់គ្រង និង បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍របស់អ្នកប្រើប្រាស់ ........ 41
៣.៤.៥.ផ្តួចផ្តើមក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដសម្រាប់សេវាហេដ្ឋារចនាសម្ព័ន្ធ IT ........ 41
៣.៥.បង្កើនការអភិវឌ្ឍ, នវានុវត្តន៍ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធ និង កម្មវិធី IT ........ 42
៣.៥.១.រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគាំទ្រការងារកែទម្រង់ និង មុខងារស្នូល កសហវ ........ 43
៣.៥.២.រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងកិច្ចការបុគ្គលិក, រដ្ឋបាល និង បណ្តុះបណ្តាល ........ 44
៣.៥.៣.រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងការទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការរួម ........ 44
៣.៥.៤.រៀបចំប្រព័ន្ធអេកូឡូស៊ី និង ពង្រឹងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ........ 45
៣.៥.៥.ពង្រឹងការគ្រប់គ្រងលើដំណើរការរៀបចំ, អភិវឌ្ឍ និង កែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ........ 45
៣.៦.ផ្តួចផ្តើម និង សហការបង្កើនការផ្តល់សេវាអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម ........ 46
៣.៦.១.កសាងមូលដ្ឋានគ្រឹះគាំទ្រការផ្តល់សេវាបែបអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម ........ 46
៣.៦.២.ផ្តួចផ្តើមក្នុងការបង្កើនការផ្តល់សេវាបែបអេឡិចត្រូនិក ........ 47
៣.៦.៣.រៀបចំអង្គភាពការងារបែបអេឡិចត្រូនិក និង ឌីជីថលគំរូ ........ 47
៣.៦.៤.ចាប់យកនិន្នាការបច្ចេកវិទ្យាព័ត៌មានថ្មីៗគាំទ្រដល់ការធ្វើឌីជីថលូបនីយកម្ម ........ 48
៣.៧.ពង្រឹងប្រព័ន្ធសន្តិសុខព័ត៌មាន និង ធានានិរន្តរភាពប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មាន ........ 49

៣.៧.១.រៀបចំប្រព័ន្ធការពារការវាយប្រហារ និង ការជ្រៀតចូលប្រព័ន្ធ IT កសហវ ........................................49
៣.៧.២.បង្កើនសណ្តាប់ធ្នាប់នៃការគ្រប់គ្រង និង ប្រើប្រាស់ IT........................................................50
៣.៧.៣.ពង្រឹងនិរន្តរភាពនៃប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មាន ..........................................................50
៣.៨.អភិវឌ្ឍសមត្ថភាព និង ពង្រឹងការគ្រប់គ្រងធនធានមនុស្សផ្នែក IT .................................. 51
៣.៨.១.កសាងសមត្ថភាពជំនាញវិជ្ជាជីវៈ IT ដល់មន្ត្រី និង បុគ្គលិកបច្ចេកទេសផ្នែក IT ..........................51
៣.៨.២.កសាងសមត្ថភាព IT និង ឌីជីថលកម្រិតមូលដ្ឋានដល់មន្ត្រី និង បុគ្គលិកទូទៅ .........................51
៣.៨.៣.រៀបចំ និង ពង្រឹងយន្តការគ្រប់គ្រង និង ធានានិរន្តរភាពធនធានមនុស្សផ្នែក IT.........................52
៣.៩.ពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន............................................. 52
៣.៩.១.រៀបចំក្របខណ្ឌអភិបាលកិច្ចបច្ចេកវិទ្យាព័ត៌មាន...........................................................52
៣.៩.២.បង្កើនប្រសិទ្ធភាពការគ្រប់គ្រងវដ្តអាយុកាល, លទ្ធកម្ម និង ក្រុមហ៊ុនផ្គត់ផ្គង់ផ្នែក IT....................53
៣.៩.៣.គ្រប់គ្រងការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT .........................................................53
**៤.ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ** ............... 55
៤.១.ការរៀបចំក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួល.................................................. 55
៤.២.ការតាមដាន និង វាយតម្លៃការអនុវត្តផែនការមេ IT ........................................................ 59
៤.២.១.ការរៀបចំផែនការសកម្មភាព..................................................................................59
៤.២.២.ការតាមដាន និង ការវាយតម្លៃ ..............................................................................60
៤.៣.អភិក្រម និង គោលការណ៍អនុវត្ត ........................................................................... 60
**ឧបសម្ព័ន្ធទី ១: តារាងសកម្មភាពគន្លឹះ និង លទ្ធផលរំពឹងទុក**................................. 63
**ឧបសម្ព័ន្ធទី ២: បញ្ជីសេវាសាធារណៈរបស់ កសហវ ឆ្នាំ ២០២០** .......................... 83
**ឧបសម្ព័ន្ធទី ៣: ប្រកាសស្តីពីការរៀបចំ និង ប្រព្រឹត្តទៅក្រុមប្រឹក្សា IT នៃ កសហវ**..... 91

# អារម្ភកថា

បដិវត្តន៍ឧស្សាហកម្មទី ៤ បាន និងកំពុងបោះជំហានទៅមុខក្នុងល្បឿនយ៉ាងលឿនលើសពីការរំពឹងទុក គ្របដណ្ដប់ទៅលើស្ទើរគ្រប់វិស័យនៃសេដ្ឋកិច្ច និង សង្គមទូទាំងពិភពលោក ជាពិសេស ក្នុងបរិការណ៍នៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ។ ស្ថិតក្នុងស្ថានភាពនៃការរាតត្បាតនេះ, បច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលបានកំពុងដើរតួនាទីយ៉ាងសំខាន់ និង កំពុងមានល្បឿននៃការចាប់យកការប្រើប្រាស់លើសពីធម្មតា ក្នុងការធានាបាននូវនិរន្តរភាពការងារ, សកម្មភាពសង្គម និង ប្រតិបត្តិការសេដ្ឋកិច្ច និង ធុរកិច្ច ដែលបង្ហាញពីសក្ដានុពលដ៏ធំធេងនៃបច្ចេកវិទ្យាព័ត៌មាន ។

ដើម្បីទាញយកប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាព័ត៌មាននេះ, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្ត “**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**" ដែលមានចក្ខុវិស័យកសាង និង អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើកនៅកម្ពុជា ។ សម្រាប់រយៈពេល ៥ ឆ្នាំដំបូង, រាជរដ្ឋាភិបាលនឹងផ្ដល់អាទិភាពលើការកសាងមូលដ្ឋានគ្រឹះ និង ការចាប់យកឌីជីថល តាមរយៈការកំណត់គោលដៅនៃការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល ដោយមានការកសាងរដ្ឋាភិបាលឌីជីថល ជាសសរស្ដម្ភកណ្ដាល ដែលមានតួនាទីសំខាន់នាំមុខជាកម្លាំងជំរុញផង និង ផ្សារភ្ជាប់រវាងធុរកិច្ច និង ពលរដ្ឋឌីជីថលផង ។ ផ្អែកលើមូលដ្ឋាននេះ, ក្នុងគោលបំណងជំរុញអភិបាលកិច្ចដោយផ្អែកលើទិន្នន័យ និង ធានាការចូលរួមឱ្យបានខ្លាំងក្លា ប្រកបដោយអន្តរសកម្មពីសំណាក់តួអង្គពាក់ព័ន្ធក្នុងវិស័យឌីជីថល, រាជរដ្ឋាភិបាលនឹងបន្តជំរុញការធ្វើទំនើបកម្មប្រព័ន្ធការងារក្នុងវិស័យសាធារណៈ ជាពិសេស មុខងារស្នូល និង កិច្ចការរដ្ឋបាលរបស់ក្រសួង-ស្ថាប័ន, ការដ្ឋានកែទម្រង់សំខាន់ៗ, លើកកម្ពស់ការផ្ដល់ និង ការពង្រឹងប្រសិទ្ធភាពសេវាកម្មសាធារណៈ តាមរយៈការបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង បច្ចេកវិទ្យាឌីជីថល ។

ដើម្បីចូលរួមសម្រេចបាននូវចក្ខុវិស័យក្នុងក្របខណ្ឌសំខាន់ៗខាងលើ ជាពិសេស ការកសាងរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព និង ស័ក្ដិសិទ្ធភាព, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានរៀបចំ និង ដាក់ចេញនូវ **ផែនការមេបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់រយៈពេល ៥ ឆ្នាំ** ។ ជារួម, ផែនការមេបច្ចេកវិទ្យាព័ត៌មាននេះនឹងក្លាយជាផែនទីចង្អុលផ្លូវរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ និង ការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយធានាបាននូវសុខដុមនីយកម្ម, ការវិនិយោគចំគោលដៅ និង ការចែករំលែកការប្រើប្រាស់ធនធានបច្ចេកវិទ្យាព័ត៌មានឱ្យអស់សក្ដានុពល និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ផែនការមេបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់រយៈពេល ៥ ឆ្នាំនេះ បានកំណត់នូវចក្ខុវិស័យច្បាស់លាស់សំដៅ “**កសាង និង អភិវឌ្ឍមូលដ្ឋានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលរឹងមាំមានសុវត្ថិភាព និង មានស្ថិរភាពខ្ពស់ និង ជំរុញការចាប់យកឌីជីថល ដើម្បីបង្កើនផលិតភាព, ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធនៃការងារ និង សេវាសាធារណៈ គាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រួមចំណែកដល់ការកសាង និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលនៅកម្ពុជា**” ។ ចក្ខុ-

វិស័យនេះ ត្រូវសម្រេចឱ្យបានត្រឹមរយៈពេល ៥ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២១ ទៅដល់ឆ្នាំ ២០២៥ ដោយមានសមាសធាតុសំខាន់ៗ ដែលចែកជាសសរស្តម្ភ ចំនួន ៦ រួមមានៈ ១-ពង្រឹង និង បង្កើនសមត្ថភាព និង ស្ថិរភាពនៃហេដ្ឋារចនាសម្ព័ន្ធ និង ធនធានបច្ចេកវិទ្យាព័ត៌មាន, ២-បង្កើនការអភិវឌ្ឍ, នវានុវត្តន៍ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធ ឬ កម្មវិធីបច្ចេកវិទ្យាព័ត៌មាន, ៣- ផ្តួចផ្តើម និង សហការបង្កើនការផ្តល់សេវាអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម, ៤-ពង្រឹងប្រព័ន្ធសន្តិសុខព័ត៌មាន និង ធានានិរន្តរភាពនៃប្រតិបត្តិការបច្ចេក-វិទ្យាព័ត៌មាន, ៥-អភិវឌ្ឍសមត្ថភាព និង ពង្រឹងការគ្រប់គ្រង ធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មាន និង ៦-ពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន ។ បន្ថែមពីនេះ, ផែនការមេនេះមានវិសាលភាពគ្របដណ្តប់នូវរាល់ការងារពាក់ព័ន្ធនឹងវិស័យឌីជីថលក្នុងក្របខណ្ឌតួនាទី និង ភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយរួមបញ្ចូលទាំងអង្គភាពក្រោមឱវាទនៅថ្នាក់កណ្តាល និង ថ្នាក់ក្រោមជាតិ និង គម្រោងបច្ចេកវិទ្យាព័ត៌មាននានាដែលរៀបចំ និង គ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជាទីបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **គង់ ម៉ារី** អនុរដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារ និង លោក **អៀច សេដ្ឋា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋាន និង ថ្នាក់ដឹកនាំ និង មន្ត្រីជំនាញនៃអគ្គនា-យកដ្ឋាន និង អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម និង បានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធ រហូតបានបញ្ចប់ផែនការមេបច្ចេកវិទ្យាព័ត៌មាននេះ ដោយជោគជ័យជាស្ថាពរ ៕

ថ្ងៃសុក្រ ១២រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# តារាងពាក្យកាត់

| ពាក្យកាត់ | ពាក្យពេញអង់គ្លេស | បរិយាយ |
|---|---|---|
| កសហវ | | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| សហវ | | សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| អគរ | | អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា |
| អតប | | អាករលើតម្លៃបន្ថែម |
| ACTS | ASEAN Customs Transit System | ប្រព័ន្ធឆ្លងកាត់គយអាស៊ាន |
| AFD | Administration and Finance Department | នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ |
| AP | Account Payable Module | មុខងារគណនីត្រូវសងនៃ FMIS |
| AR | Account Receivable Module | មុខងារគណនីត្រូវទារនៃ FMIS |
| ARISE+ | ASEAN Regional Integration Support | ក្រុមគាំទ្រការធ្វើសមាហរណកម្មតំបន់អាស៊ាន |
| ASYCUDA | Automated System for Customs Data | ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ |
| B2B | Business to Business | ផ្លាស់ប្តូរព័ត៌មានរវាងធុរជន និង ធុរជន |
| BA | Budget Allocation Module | មុខងារវិភាជន៍ថវិកានៃ FMIS |
| BE | Budget Entity | អង្គភាពថវិកា |
| BI | Business Intelligent | ធុរកិច្ចឆ្លាតវៃ |
| BP | Budget Planning Module | មុខងាររៀបចំផែនការថវិកានៃ FMIS |
| CamDigiKey | Cambodia Digital Key | ថ្នាលគ្រប់គ្រងអត្តសញ្ញាណឌីជីថល |
| CamDX | Cambodia Data Exchange | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា |
| CM | Cash Management Module | មុខងារគ្រប់គ្រងសាច់ប្រាក់នៃ FMIS |
| COTS | Commercial Off-The-Shelf | ផលិតផលក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិ |
| CRMDS | Customs Risk Management Database System | ប្រព័ន្ធគ្រប់គ្រងទិន្នន័យហានិភ័យគយ |
| DEF | Department of Economy and Finance | មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| DMFAS | Debt Management and Financial Analysis System | ប្រព័ន្ធគ្រប់គ្រងបំណុល និង វិភាគហិរញ្ញវត្ថុ |
| DTA | Double Taxation Agreement | កិច្ចព្រមព្រៀងមិនយកពន្ធត្រួតគ្នា |
| EFI | Economic and Finance Institute | វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |

| | | |
|---|---|---|
| e-GP | Electronic Government Procurement | លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក |
| FMIS | Financial Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| FMWG | FMIS project Management Working Group | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| G2B | Government to Business | ផ្លាស់ប្តូរព័ត៌មានរវាងអង្គភាពរដ្ឋ និង ឯកជន |
| G2C | Government to Citizen | ផ្លាស់ប្តូរព័ត៌មានរវាងរដ្ឋ និង ប្រជាជន |
| G2G | Government to Government | ផ្លាស់ប្តូរទិន្នន័យរវាងអង្គភាពរដ្ឋ និង រដ្ឋ |
| GD | General Department | អគ្គនាយកដ្ឋាន |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា |
| GDIA | General Department of Internal Audit | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| GDICDM | General Department of International Cooperation and Debt Management | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង គ្រប់គ្រងបំណុល |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ |
| GDP | General Department of Policy | អគ្គនាយកដ្ឋានគោលនយោបាយ |
| GDPP | General Department of Public Procurement | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |
| GDSNAF | General Department of Sub National Administration Finance | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ |
| GDSPNTR | General Department of State Property and Nontax Revenue | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ |
| GL | General Ledger | សៀវភៅធំ |
| GS | General Secretariat | អគ្គលេខាធិការដ្ឋាន |
| GTAS | Global Travel Assessment System | ប្រព័ន្ធវាយតម្លៃការធ្វើដំណើរសាកល |
| ICT | Information and Communication Technology | បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន |
| IP | Internet Protocol | ពិធីសារអ៊ីនធឺណិត |

| | | |
|---|---|---|
| IT | Information Technology | បច្ចេកវិទ្យាព័ត៌មាន |
| ITAD | Information Technology Audit Department | នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន |
| ITD | Information Technology Department | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| LCS | Legal Council Secretariat | លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម |
| LD | Line Department | មន្ទីរជំនាញ |
| LM | Line Ministry | ក្រសួង-ស្ថាប័ន |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| MOC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MOI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MPWT | Ministry of Public Works and Transportation | ក្រសួងសាធារណការ និង ដឹកជញ្ជូន |
| NBC | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |
| NRMIS | Nontax Revenue Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិន-មែនសារពើពន្ធ |
| NSW | National Single Windows | ប្រព័ន្ធបញ្ជរតែមួយជាតិ |
| PA | Provincial Administration | រដ្ឋបាលរាជធានី-ខេត្ត |
| PIMS | Public Investment Management System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងវិនិយោគសាធារណៈ |
| PO | Purchase Order Module | មុខងារទិញនៃ FMIS |
| PR | Procurement Module | មុខងារលទ្ធកម្មនៃ FMIS |
| PT | Provincial Treasury | រតនាគាររាជធានី-ខេត្ត |
| SARMIS | State Asset Register Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើ-ភណ្ឌទ្រព្យសម្បត្តិរដ្ឋ |
| SDLC | System Development Life Cycle | វដ្តនៃការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន |
| TCMS | Trader Credibility Management System | ប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន |
| UNCTAD | United Nations Conference on Trade and Development | សន្និសីទអង្គការសហប្រជាជាតិសម្រាប់ពាណិជ្ជកម្ម និង ការអភិវឌ្ឍ |

# បញ្ជីរូបភាព


រូបភាពទី ១.១: គំនូសបំព្រួញនៃមូលដ្ឋានចាប់ផ្ដើមលើវិថីឌីជីថលទៅរកការធ្វើបរិវត្តកម្មឌីជីថល
រូបភាពទី ១.២: គោលការណ៍ និង ក្របខណ្ឌកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា
រូបភាពទី ២.១: មជ្ឈមណ្ឌលទិន្នន័យក្នុងក្របខណ្ឌ កសហវ
រូបភាពទី ២.២: ហេដ្ឋារចនាសម្ព័ន្ធបណ្ដាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានរបស់ កសហវ
រូបភាពទី ២.៣: ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាននៅកន្លែងការងារ
រូបភាពទី ២.៤: ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានធំៗរបស់ កសហវ
រូបភាពទី ២.៥: ទិដ្ឋភាពទូទៅនៃប្រព័ន្ធ FMIS
រូបភាពទី ២.៦: ទិដ្ឋភាពទូទៅនៃប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ
រូបភាពទី ២.៧: ទិដ្ឋភាពទូទៅនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ
រូបភាពទី ២.៨: ទិដ្ឋភាពទូទៅនៃប្រព័ន្ធ NRMIS
រូបភាពទី ២.៩: ទិដ្ឋភាពទូទៅនៃថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (CamDX)
រូបភាពទី ២.១០: កម្មវិធីបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់កិច្ចប្រជុំពីចម្ងាយ
រូបភាពទី ២.១១: ប្រព័ន្ធសន្និសីទវីដេអូរបស់ កសហវ
រូបភាពទី ២.១២: រចនាសម្ព័ន្ធអង្គភាពទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាននៃ កសហវ
រូបភាពទី ៣.១: គំនូសបំព្រួញផែនការមេបច្ចេកវិទ្យាព័ត៌មាន កសហវ
រូបភាពទី ៣.២: ក្របខណ្ឌហេដ្ឋារចនាសម្ព័ន្ធ IT
រូបភាពទី ៣.៣: ផែនការមជ្ឈមណ្ឌលទិន្នន័យ កសហវ
រូបភាពទី ៣.៤: ហេដ្ឋារចនាសម្ព័ន្ធ IT ឆ្នាំ ២០២៥
រូបភាពទី ៤.១: ក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួលការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មាន
រូបភាពទី ៤.២: ការរៀបចំផែនការសកម្មភាព, ការតាមដាន និង វាយតម្លៃ

# ១.សេចក្តីផ្តើម

## ១.១.ទិដ្ឋភាពទូទៅ

វឌ្ឍនភាពនៃវិទ្យាសាស្ត្រ, វិស្វកម្ម និង បច្ចេកវិទ្យា គឺជាគន្លឹះដ៏សំខាន់សម្រាប់ជំរុញការផ្លាស់ប្តូររបស់ពិភពលោកឱ្យកាន់តែមានការរីកចម្រើនឥតឈប់ឈរជាលំដាប់ ។ បច្ចុប្បន្ននេះ ពិភពលោកកំពុងតែស្ថិតក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី ៤.០ ដែលផ្តោតជាសំខាន់លើ**បរិវត្តកម្មឌីជីថល** ។ **បច្ចេកវិទ្យាឌីជីថល** និង **បច្ចេកវិទ្យាព័ត៌មាន** បានដើរតួនាទីដ៏សំខាន់ក្នុងការចូលរួមចំណែកគាំទ្រ និង ជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម, ជានាបាននូវកំណើន និង គុណភាពនៅក្នុងផ្នែកផលិតកម្ម និង សេវាកម្ម, ពង្រឹងបាននូវអភិបាលកិច្ចល្អ, តម្លាភាព, គណនេយ្យភាព និង ប្រសិទ្ធភាពនៅក្នុងស្ថាប័ន និង បង្កើតឱ្យមាននូវនវានុវត្តន៍ថ្មីៗបន្ថែមទៀតដែលជាប្រយោជន៍សម្រាប់សេដ្ឋកិច្ច និង សង្គម ។ បច្ចេកវិទ្យាព័ត៌មាន (Information Technology - IT) ត្រូវបានផ្តោតជាសំខាន់ទៅលើវិធីសាស្ត្រនៃការគ្រប់គ្រង និង ការប្រើប្រាស់ឧបករណ៍ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មាន, ដោយឡែក បច្ចេកវិទ្យាឌីជីថល ត្រូវបានផ្តោតជាសំខាន់ទៅលើការយកបច្ចេកវិទ្យាព័ត៌មានមកប្រើប្រាស់ក្នុងការដោះស្រាយបញ្ហានានា ដែលកើតមានឡើងនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្សលោក ។

ក្នុងបរិការណ៍នៃការរីករាលដាលនូវជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (**កូវីដ-១៩**) បានធ្វើឱ្យពិភពលោកផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និង បច្ចេកវិទ្យាព័ត៌មានដែលជាដំណោះស្រាយដ៏មានប្រសិទ្ធភាពក្នុងការធានានិរន្តរភាពការងាររបស់ស្ថាប័ន ព្រោះការរាតត្បាតនៃជំងឺថ្មីខាងលើនេះ ទាមទារឱ្យមានការចាត់វិធានការយ៉ាងតឹងរឹងមួយចំនួននៅក្នុងសង្គម ដូចជា ការរក្សាគម្លាតសង្គម, ការកាត់បន្ថយការជួបជុំគ្នា, ការកាត់បន្ថយការធ្វើដំណើរ ជាដើម ដែលតម្រូវឱ្យបុគ្គលិក, មន្ត្រីរាជការ, អាជីវករ, ធុរជន និង សាធារណជនទូទៅ បំពេញការងារ ឬ ប្រជុំពិភាក្សាការងារពីចម្ងាយ, ប្រើប្រាស់ឯកសារក្នុងទម្រង់ជាឌីជីថល, រៀបចំបែបបទនីតិវិធីអនុវត្តការងារថ្មីតាមបែបឌីជីថល ជាដើម ។ ការណ៍នេះ បានធ្វើឱ្យស្ថាប័ននីមួយៗទាំងវិស័យសាធារណៈ និង វិស័យឯកជន ជំរុញកាន់តែខ្លាំងលើការរៀបចំ និង ដាក់ឱ្យដំណើរការភ្លាមៗនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីគាំទ្រដល់ដំណើរការការងារប្រចាំថ្ងៃដូចជា ប្រព័ន្ធសន្និសីទវីដេអូ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រង និង ចែករំលែកឯកសារឌីជីថល, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងកិច្ចសហប្រតិបត្តិការការងារ និង រំហូរការងារ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងកិច្ចការស្នូលនៅក្នុងស្ថាប័ន ជាដើម ។

ផ្អែកលើនិន្នាការនៃការរីកចម្រើនបច្ចេកវិទ្យាឌីជីថល និង បញ្ហាប្រឈមនៃការរីករាលដាលជំងឺថ្មីៗ ឬ គ្រោះមហន្តរាយផ្សេងៗនៅក្នុងសាកលលោក ប្រជាជាតិអាស៊ានក៏រួមគ្នារៀបចំនូវ "**ផែនការមេឌីជីថលអាស៊ាន ២០២៥**" ដែលមានចក្ខុវិស័យប្រែក្លាយអាស៊ានទៅជាតំបន់នាំមុខលើសេដ្ឋកិច្ច និង សហគមន៍ឌីជីថល ។ ជាមួយគ្នានេះ ព្រះរាជាណាចក្រកម្ពុជាដែលជាប្រជាជាតិមួយនៅក្នុងសហគមន៍អាស៊ាន ក៏បានរៀបចំរួចរាល់នូវ "**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**" ដែលមានទស្សនវិស័យវែងឆ្ងាយក្នុងការតម្រង់ទិសសម្រាប់ការអភិវឌ្ឍ និង ដំណើរការបរិវត្តកម្មឌីជីថល

ដែលមានការគិតគូរ និង ការចាប់ផ្តើមជាជំហានៗទៅតាមតម្រូវការ ធនធាន និង សមត្ថភាព នៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន គាំទ្រដល់ចក្ខុវិស័យរបស់តំបន់ និង សហគមន៍ ។ ម្យ៉ាងទៀត កម្ពុជាក៏កំពុងរៀបចំនូវសេចក្តីព្រាង ក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ផងដែរ ដើម្បីគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាលកម្ពុជា លើបេសកកម្ម **ដឹកនាំ និង គ្រប់គ្រងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និង លើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និង សមធម៌សង្គម, បានផ្តល់អាទិភាព និង បាន**ចាប់យកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង បច្ចេកវិទ្យាឌីជីថល** ក្នុងការគាំទ្រ ជំរុញ និង ពន្លឿនដល់ការអនុវត្តកម្មវិធីគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យសម្រេចបានតាមគោលដៅដែលបានដាក់ចេញប្រកបដោយ **គណនេយ្យភាព, តម្លាភាព, ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ** ដែលគ្របដណ្តប់លើការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមាន ការគ្រប់គ្រងចំណូល-ចំណាយថវិកាជាតិ, ការគ្រប់គ្រងសាច់ប្រាក់, ការគ្រប់គ្រងបំណុលសាធារណៈ, ការគ្រប់គ្រងកិច្ចលទ្ធកម្ម, ការគ្រប់គ្រងការអនុវត្តថវិកា, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ, ការគ្រប់គ្រងឧស្សាហកម្មហិរញ្ញវត្ថុ, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាតិ ជាដើម ។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែល កសហវ បានរៀបចំ និង ដាក់ឱ្យដំណើរការកន្លងមក និង ដែលមានវិសាលភាពធំៗគ្របដណ្តប់នៅទូទាំងប្រទេស រួមមាន **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលពន្ធដារ, ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** ដែលជាចំណែកមួយនៃដំណើរ-ការរៀបចំរដ្ឋាភិបាលឌីជីថល ដោយមានការផ្លាស់ប្តូរទិន្នន័យ ឬ ព័ត៌មានជាទម្រង់អេឡិចត្រូនិករវាងអង្គភាពរដ្ឋ និង អង្គភាពរដ្ឋ (G2G) និង រវាងអង្គភាពរដ្ឋ និង ធុរជន ឬ ប្រជាជន (G2B, G2C) ។ ក្រៅពីនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនផ្សេងទៀត ក៏ត្រូវបានបង្កើតឡើងសម្រាប់គ្រប់គ្រងកិច្ចការងាររដ្ឋបាលផ្ទៃក្នុង, ការងារប្រចាំថ្ងៃ និង ការផ្តល់សេវាសាធារណៈ ផងដែរ ។ ទន្ទឹមនឹងនេះ កសហវ បានកសាងរួចរាល់នូវមជ្ឈមណ្ឌលទិន្នន័យ ដើម្បីទ្រទ្រង់ដល់ដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចមានរៀបរាប់ខាងលើប្រកបដោយស្ថិរភាព និង ប្រសិទ្ធភាព ព្រមទាំងបានដំឡើងបណ្តាញតភ្ជាប់បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ទៅកាន់ការដ្ឋានដែលជាអង្គភាពក្រោមឱវាទជាច្រើននៅទូទាំងប្រទេស ដែលផ្តល់នូវឱកាស និង លទ្ធភាពដល់អង្គភាពក្រោមឱវាទ អាចពង្រីកបន្ថែមការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង បង្កើនការគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ។

បើទោះបីជាបច្ចេកវិទ្យាព័ត៌មានត្រូវបានយកមកប្រើប្រាស់មួយភាគធំ និង ទូលំទូលាយនៅក្នុងក្របខណ្ឌ កសហវ គិតត្រឹមឆ្នាំ ២០២០ នេះក៏ដោយ ក៏**ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៅមានលក្ខណៈដាច់ដោយឡែកៗពីគ្នា, មិនមានសង្គតិភាពនឹងគ្នា, ប្រើប្រាស់ធនធានផ្សេងៗគ្នា, ចែករំលែកទិន្នន័យរវាងគ្នានៅមានកម្រិត, មិនមានក្របខណ្ឌរួមសម្រាប់ការគ្រប់គ្រង និង ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ជាដើម**

ដែលជាបញ្ហាប្រឈមនាំឱ្យមានការវិនិយោគ និង ការប្រើប្រាស់នូវធនធានត្រួតស៊ីគ្នា, ការប្រើប្រាស់មិនអស់លទ្ធភាពនូវធនធានបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់, ការខ្វះព័ត៌មានអំពីក្របខណ្ឌនៃការវិនិយោគ និង ការចំណាយទៅលើអាជ្ញាបណ្ណ និង សេវាថែទាំគាំទ្រលើឧបករណ៍ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មានរួមរបស់ កសហវ ដែលនាំឱ្យមានការលំបាកក្នុងការបែងចែងធនធានថវិកានៅក្នុងវិស័យ IT នេះ ។ ផ្អែកលើនិន្នាការជាសាកលលោក, ការតម្រង់ទិសពីក្របខណ្ឌគោលនយោបាយថ្នាក់ជាតិលើបច្ចេកវិទ្យាឌីជីថល និង បញ្ហាប្រឈមមួយចំនួនដូចមានរៀបរាប់ខាងលើ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាំបាច់ត្រូវតែរៀបចំឱ្យបាននូវ "**ផែនការមេបច្ចេកវិទ្យាព័ត៌មាន**" មួយសម្រាប់ក្របខណ្ឌរួមនៃ កសហវ ទាំងមូល ក្នុងរយៈពេល ៥ ឆ្នាំ គឺ ២០២១-២០២៥ ដែលស្ថិតនៅក្រោមឆត្រនៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ រួមទាំង ក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ប្រកបដោយភាពប្រទាក់ក្រឡាគ្នាជាមួយនឹងយុទ្ធសាស្ត្រ និង ផែនការនានាដែលមានស្រាប់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ផែនការមេបច្ចេកវិទ្យាព័ត៌មាន នឹងឆ្លុះបញ្ចាំងអំពីទិដ្ឋភាពរួមនៃការប្រើប្រាស់ និង ការចាប់យកបច្ចេកវិទ្យាព័ត៌មាន និង បច្ចេកវិទ្យាឌីជីថល មកធ្វើជាកម្លាំងជំរុញ និង គាំទ្រដល់ការរៀបចំយន្តការអភិវឌ្ឍស្ថាប័ន, សម្រួលដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនានា និង ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈរបស់ កសហវ ។ ផែនការមេនេះ ត្រូវបានបែងចែកជា **៤ ផ្នែក** រួមមាន **១-សេចក្តីផ្តើម**: រៀបរាប់អំពីទិដ្ឋភាពទូទៅ និង មូលដ្ឋាននៃការរៀបចំផែនការមេ, **២-ស្ថានភាពបច្ចុប្បន្ននៃបច្ចេកវិទ្យាព័ត៌មានក្នុង កសហវ**: រៀបរាប់អំពីធនធាន និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងក្របខណ្ឌ កសហវ ដែលកំពុងប្រើប្រាស់នៅតាមអង្គភាពក្រោមឱវាទ ជាមួយនឹងការលើកឡើងនូវបញ្ហាប្រឈម, ការវិភាគលើចំណុចខ្លាំង និង ចំណុចខ្សោយនៃបច្ចេកវិទ្យាព័ត៌មានបច្ចុប្បន្ន, **៣-ផែនការមេបច្ចេកវិទ្យាព័ត៌មាន**: រៀបរាប់អំពីចក្ខុវិស័យ, គោលបំណង, គោលដៅ និង សកម្មភាពគន្លឹះៗ សម្រាប់រយៈពេល ៥ ឆ្នាំ និង **៤-ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ**: រៀបរាប់អំពីការរៀបចំក្របខណ្ឌស្ថាប័នអនុវត្តផែនការមេ, យន្តការសម្របសម្រួល និង វិធានសម្រាប់ការតាមដាន និង វាយតម្លៃ ។

## ១.២.ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** បានអនុម័តឱ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២១ ដែលមានទស្សនវិស័យវែងឆ្ងាយក្នុងការតម្រង់ទិសសម្រាប់ការអភិវឌ្ឍ និង ដំណើរការបរិវត្តកម្មឌីជីថល ដែលមានការគិតគូរ និង ការចាប់ផ្តើមជាជំហានៗទៅតាមតម្រូវការធនធាន និង សមត្ថភាព នៅក្នុងវិស័យសាធារណៈ និង ឯកជន ។ ក្របខណ្ឌគោលនយោបាយនេះ បានដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈ ការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង ការធ្វើបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គមទាំងរដ្ឋ, ពលរដ្ឋ និង ធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម ដោយផ្អែកលើគន្លង "**ប្រក្រតីភាពថ្មី**" ។

រដ្ឋាភិបាលឌីជីថល គឺជាតួអង្គដ៏ចាំបាច់ក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា និង ត្រូវដើរឈានមុខគេក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើតឱ្យមាននូវតម្រូវការផ្ទាល់ និង បង្ហាញឱ្យធុរជន និង ប្រជាពលរដ្ឋ ឆាប់ចាប់យកវិស័យឌីជីថលនេះទៅប្រើប្រាស់ ដើម្បីបម្រើជាប្រយោជន៍ផ្សេងៗ ។ **ការធ្វើឌីជីថលូបនីយកម្មនៃការផ្តល់សេវាសាធារណៈ និង ការធ្វើបរិវត្តកម្មប្រព័ន្ធរដ្ឋបាលសាធារណៈ គឺជាធាតុដ៏សំខាន់នៃការរៀបចំរដ្ឋាភិបាលឌីជីថល** ហើយរាជរដ្ឋាភិបាលកម្ពុជាក៏បានអនុវត្តនូវកម្មវិធី និង គំនិតផ្តួចផ្តើមមួយចំនួនលើកិច្ចការងារនេះជាបន្តបន្ទាប់ ។ រាជរដ្ឋាភិបាលនឹងផ្តោតការកសាងរដ្ឋាភិបាលឌីជីថល លើទិដ្ឋភាព ៣ រួមមាន ការកំណត់ស្តង់ដារនៃសេវាសាធារណៈតាមបច្ចេកវិទ្យាឌីជីថលដោយរក្សាភាពជាម្ចាស់នៃក្រសួង-ស្ថាប័ន, ការកសាងថ្នាលឌីជីថលមូលដ្ឋានរបស់រដ្ឋ និង ការរៀបចំនូវប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យក្នុងបរិការណ៍រដ្ឋាភិបាលឌីជីថល ។

ជាមួយគ្នានេះ ថ្នាលឌីជីល (Digital Platform) និង ទិន្នន័យ (Data) ត្រូវបានកំណត់ជាមូលដ្ឋាន និង ជាស្នូលនៃការចាប់យកឌីជីថល និង ការធ្វើបរិវត្តកម្មឌីជីថល ។ "ថ្នាលឌីជីថល" គឺសំដៅទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចប្រើប្រាស់រួមគ្នាក្នុងគោលបំណងតែមួយ ។ ចំណែកឯ "ទិន្នន័យ" គឺជាទ្រព្យឌីជីថលដ៏មានតម្លៃរបស់ស្ថាប័ននីមួយៗប្រើប្រាស់សម្រាប់ជំនួសឱ្យកំណត់ត្រា, ការផ្ទៀងផ្ទាត់ និង ការធ្វើកិច្ចបញ្ជិកានានាជាក្រដាស ដែលស្ថាប័ននីមួយៗធ្លាប់ប្រើប្រាស់ក្នុងសម័យអតីតកាល ព្រមទាំងផ្តល់ជាមូលដ្ឋានដ៏សំខាន់សម្រាប់ការស្វែងរក, ការវិភាគ និង ការព្យាករណ៍ដោយស្វ័យប្រវត្តិជូនដំណឹងសម្រាប់ការសម្រេចចិត្តនានាដល់ប្រធានស្ថាប័ន ។




*ប្រភព: ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

**រូបភាពទី ១.១**: គំនូសបំព្រួញនៃមូលដ្ឋានចាប់ផ្តើមលើវិថីឌីជីថលទៅរកការធ្វើបរិវត្តកម្មឌីជីថល

អនុលោមតាមគោលការណ៍នៃការកសាងរដ្ឋាភិបាលឌីជីថល ប្រព័ន្ធ IT របស់រដ្ឋាភិបាលឌីជីថលត្រូវបែងចែកជា ៣ ផ្នែកធំៗ គឺ ទិន្នន័យ, ថ្នាលឌីជីថល និង សេវាឌីជីថល ។ តួអង្គនៃរដ្ឋាភិបាលឌីជីថលនីមួយៗត្រូវចូលរួមរៀបចំ, បង្កើត, គ្រប់គ្រង និង អនុវត្តគម្រោងរដ្ឋាភិបាលឌីជីថលជំណាលគ្នា ឬ ដាច់ដោយឡែកពីគ្នា ស្របតាមផែនការ និង ទិសដៅនៃរដ្ឋាភិបាលឌីជីថល ។ ម្យ៉ាងទៀត គម្រោងនីមួយៗតម្រូវឱ្យអនុវត្តតាមឯកសារណែនាំស្តង់ដាគំរូ (Standard Template) លើពិធីសារ, លក្ខណៈបច្ចេកទេស, អន្តរប្រតិបត្តិការ (Interoperability), សន្តិសុខសាយប័រ និង រូបរាងការរចនាផតថល (UI/UX) ជាដើម ដើម្បីធានាបាននូវសង្គតិភាពនៃការងារបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋាភិបាល ។

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ បានផ្តល់នូវមូលដ្ឋានដ៏សំខាន់ក្នុងការរៀបចំផែនការមេបច្ចេកវិទ្យាព័ត៌មាន ២០២១-២០២៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាពិសេសផ្នែកដែលពាក់ព័ន្ធនឹងការរៀបចំកសាងរដ្ឋាភិបាលឌីជីថល និង ការធ្វើបរិវត្តកម្មឌីជីថលនៃវិស័យសាធារណៈ ដែលសំដៅដល់ការធ្វើសមាហរណកម្មប្រព័ន្ធរដ្ឋាភិបាលគ្រប់ក្រសួង-ស្ថាប័ន និង ធានាបាននូវការលើកកម្ពស់គុណភាពនៃ**ការផ្តល់សេវាសាធារណៈ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប, គ្រប់ពេលវេលា និង គ្រប់ទីកន្លែង** ។ ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាលកំណត់យកគោលការណ៍ធំៗចំនួន ៣ ក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា, ដែលរួមមាន "**ការកសាងមូលដ្ឋានគ្រឹះឌីជីថល-ការចាប់យកឌីជីថល-ការធ្វើបរិវត្តកម្មឌីជីថល**", ដោយក្នុងនោះឆ្នាំ ២០២១-២០២៥ គឺជាពេលវេលានៃការកសាងមូលដ្ឋានគ្រឹះ និង ការចាប់យកឌីជីថល ។




*ប្រភព: ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា*

**រូបភាពទី ១.២:** គោលការណ៍ និង ក្របខណ្ឌកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា

## ១.៣.អំពីបច្ចេកវិទ្យាព័ត៌មាន

បច្ចេកវិទ្យាព័ត៌មាន (IT) គឺសំដៅលើការប្រើប្រាស់បញ្ចូលគ្នានូវ ម៉ាស៊ីនកុំព្យូទ័រ, ឧបករណ៍អេឡិចត្រូនិក, ប្រព័ន្ធ ឬ កម្មវិធីកុំព្យូទ័រ, បណ្តាញតភ្ជាប់កុំព្យូទ័រ, ឧបករណ៍រក្សាទុកទិន្នន័យ, ឧបករណ៍សំឡេង, ជាដើម ដែលផ្តល់ជាមធ្យោបាយក្នុងការរក្សាទុកទិន្នន័យ, ទាញយកទិន្នន័យ, ដំណើរការទិន្នន័យ, បញ្ជូនទិន្នន័យ និង ទទួលទិន្នន័យក្នុងទម្រង់ជាអេឡិចត្រូនិក ។ ចំណែកឯ បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន (ICT) គឺសំដៅទៅលើការពង្រីកសមត្ថភាពបន្ថែមទៅលើបច្ចេកវិទ្យាព័ត៌មាន ដោយបានបញ្ចូលបន្ថែមនូវប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍ផ្សារភ្ជាប់នឹងការប្រើប្រាស់បណ្តាញតភ្ជាប់កុំព្យូទ័រ ។

សមាសធាតុធំៗនៃបច្ចេកវិទ្យាព័ត៌មានរួមមាន៖

- **ឧបករណ៍ និង ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន** គឺជាសមាសធាតុរឹង និង ជាគ្រឹះសម្រាប់ទ្រទ្រង់ដល់ដំណើរការនៃប្រព័ន្ធ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មាន ឬ ប្រព័ន្ធឌីជីថលនានា ដែលរួមមាន មជ្ឈមណ្ឌលទិន្នន័យ (Data Center), ម៉ាស៊ីនមេ (Server), ឧបករណ៍ ឬ ប្រព័ន្ធរក្សាទុកទិន្នន័យ (Storage), ឧបករណ៍ IT សម្រាប់អ្នកប្រើប្រាស់ (កុំព្យូទ័រ, ទូរសព្ទ, ឧបករណ៍ឆ្លាតវៃផ្សេងទៀត ជាដើម), បណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មាន (បណ្តាញតភ្ជាប់ផ្ទៃក្នុង និង បណ្តាញតភ្ជាប់ទូទាំងប្រទេស), បណ្តាញអ៊ីនធឺណិត ។ល។
- **ប្រព័ន្ធ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មាន** គឺជាសមាសធាតុទន់ដែលដំណើរការនៅក្នុងឧបករណ៍ IT និង ធ្វើឱ្យឧបករណ៍ IT នីមួយៗមានដំណើរការអន្តរសកម្មជាមួយគ្នា ស្របតាមការបញ្ជារបស់អ្នកប្រើប្រាស់ ឬ ដំណើរការដោយស្វ័យប្រវត្តិ ។ ផ្អែកលើវិសាលភាព និង ភាពគ្រប់គ្រាន់នៃហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន, កម្មវិធីបច្ចេកវិទ្យាព័ត៌មានត្រូវបានបង្កើតឡើងផ្តល់ជាប្រយោជន៍ក្នុងការគាំទ្រដល់ប្រតិបត្តិការការងារប្រចាំថ្ងៃ, ប្រតិបត្តិការធុរកិច្ច, ស្វ័យប្រវត្តិកម្មការងារ, ផលិតកម្ម, ការផ្តល់សេវាសាធារណៈ ជាដើម និង ផ្តល់លទ្ធភាពក្នុងការប្រើប្រាស់បានពីគ្រប់ទីកន្លែង និង គ្រប់ពេលវេលា ។
- **ទិន្នន័យ** គឺជាធាតុមួយដ៏ចាំបាច់បំផុតមិនអាចខ្វះបានសម្រាប់កម្មវិធីបច្ចេកវិទ្យាព័ត៌មាន ក្នុងការដំណើរការ និង ផលិតចេញនូវលទ្ធផលជាច្រើនតាមតម្រូវការ និង គោលបំណងរបស់អ្នកប្រើប្រាស់ ។

## ១.៤.យុទ្ធសាស្ត្រ និង ផែនការសកម្មភាពប្រទាក់ក្រឡារបស់ កសហវ

គិតត្រឹមដំណាច់ឆ្នាំ ២០២០ នេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំរួចរាល់នូវយុទ្ធសាស្ត្រ និង ផែនការសកម្មភាពមួយចំនួន គាំទ្រដល់ការងារកែទម្រង់របស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានសកម្មភាពគន្លឹះមួយចំនួន ផ្សារភ្ជាប់នឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (ដែលបានផ្តល់នូវមូលដ្ឋានមួយចំនួន សម្រាប់ការរៀបចំផែនការមេបច្ចេកវិទ្យាព័ត៌មាន កសហវ ២០២១-២០២៥) ដូចខាងក្រោម ៖

“**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥**” និង “**ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥**” បានដាក់ចេញនូវសកម្មភាពមួយចំនួនពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមមាន៖

- ការបង្រួម និង ពន្លឿននីតិវិធីនៃការបើកផ្តល់តាមរយៈបទដ្ឋានគតិយុត្តិសម្រាប់ការអនុវត្តថវិកាសមិទ្ធកម្ម ដើម្បីឈានទៅអនុវត្តស្វ័យប្រវត្តិកម្មតាមប្រព័ន្ធ FMIS នៅឆ្នាំ ២០២៥
- ការពង្រីកការអនុវត្តប្រព័ន្ធ FMIS លើមុខងាររៀបចំផែនការ និង អនុវត្តថវិកា រួមទាំង មុខងារគណនេយ្យ
- ការធ្វើសវនកម្មតាមប្រព័ន្ធ FMIS ។

“**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩-២០២៥**” និង “**ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩-២០២៥**” បានដាក់ចេញនូវសកម្មភាពមួយចំនួនផ្សារភ្ជាប់នឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន រួមមាន៖

- ការបង្រួម និង ពន្លឿននីតិវិធីនៃការបើកផ្តល់តាមរយៈបទដ្ឋានគតិយុត្ត និង ឈានទៅអនុវត្តស្វ័យប្រវត្តិកម្មតាមប្រព័ន្ធ FMIS ឆ្នាំ ២០២៥ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពង្រីកការដាក់អនុវត្តប្រព័ន្ធ FMIS ដល់រដ្ឋបាលរាជធានី-ខេត្ត
- ការសិក្សាប្រព័ន្ធឯកសារឌីជីថលដើម្បីអនុវត្តសម្រាប់រដ្ឋបាលក្រុង-ស្រុក-ខណ្ឌ និង រដ្ឋបាលឃុំ-សង្កាត់ ។

“**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥**” និង “**ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥**” បានដាក់ចេញនូវសកម្មភាពមួយដែលផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានគឺ ការសិក្សាអំពីការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក (e-GP) ។

“**យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣**” និង “**ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣**” បានដាក់ចេញនូវសកម្មភាពមួយចំនួនផ្សារភ្ជាប់នឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន រួមមាន៖

- ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចែករំលែកទិន្នន័យបែបអេឡិចត្រូនិក
- ការរៀបចំនីតិវិធីអនុវត្តការងារថ្មី (Business Process Re-Engineering) និង ការគ្រប់គ្រងការផ្លាស់ប្តូរក្នុងការធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធ ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការវិភាគទិន្នន័យ ដើម្បីបង្កើនសមត្ថភាពក្នុងការធ្វើសវនកម្ម
- ការដាក់អនុវត្ត “ការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក” (e-Registration)
- ការដាក់អនុវត្ត “ការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអេឡិចត្រូនិក” (e-Filing)

- ការដាក់អនុវត្ត "ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក" (e-Payment)
- ការអនុវត្តផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសារពើពន្ធ ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និង ប្រទាក់ក្រឡា ជាមួយ ប្រព័ន្ធវិភាគទិន្នន័យ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអ្នកជាប់ពន្ធពេញលេញ, ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធ និង ប្រព័ន្ធចែករំលែកទិន្នន័យអន្តរស្ថាប័ន
- ការជំរុញការប្រើប្រាស់ និង អភិវឌ្ឍបន្ថែម "ប្រព័ន្ធបញ្ជរតែមួយជាតិ"
- ការពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងហានិភ័យគយ
- ការជំរុញការដាក់អនុវត្តនូវ "ប្រព័ន្ធព័ត៌មានមុនការមកដល់" (Pre-arrival information)
- ការតភ្ជាប់ប្រព័ន្ធបញ្ជរតែមួយជាតិទៅប្រព័ន្ធបញ្ជរតែមួយអាស៊ាន
- ការរៀបចំ និង អនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មានរបស់គយ
- ការធ្វើទំនើបកម្ម និង សន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់គយ និង ប្រព័ន្ធពាក់ព័ន្ធ
- ការបន្តអភិវឌ្ឍ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ការបន្តអភិវឌ្ឍ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)
- ការអនុវត្តការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រព័ន្ធ NRMIS ។

**"យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥"** និង **"ផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពី ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥"** បានដាក់ចេញនូវសកម្មភាពមួយចំនួនផ្សារភ្ជាប់នឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន រួមមាន៖

- ការរៀបចំ និង ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមនៃគម្រោងវិនិយោគសាធារណៈ
- ការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ ។

**"យុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ២០២០-២០២៤ នៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា"** បានដាក់ចេញនូវសកម្មភាពធំៗ រួមមាន៖

- ការធ្វើទំនើបកម្មកិច្ចប្រតិបត្តិការគយ
- ការធ្វើទំនើបកម្មកិច្ចសហប្រតិបត្តិការគយ
- ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

**"ផែនការពង្រីកការអនុវត្តគម្រោង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០២១-២០២៥"** បានដាក់ចេញនូវសកម្មភាពធំៗ រួមមាន៖

- ការពង្រីកការប្រើប្រាស់មុខងារស្នូលនៃប្រព័ន្ធ FMIS ទៅរដ្ឋបាលរាជធានី-ខេត្តទាំង ២៥, រដ្ឋបាលក្រុងចំនួន ២៧, រដ្ឋបាលខណ្ឌចំនួន ១៤, រដ្ឋបាលស្រុកចំនួន ២ ជាគំរូ, មន្ទីរជំនាញចំនួន ២ នៅរាជធានី-ខេត្តទាំង ២៥ និង គ្រឹះស្ថានសាធារណៈលក្ខណៈរដ្ឋបាលយ៉ាងតិចចំនួន ៣០
- ការពង្រីកការដាក់ឱ្យប្រើប្រាស់មុខងារថ្មីចំនួន ២ បន្ថែមគឺ មុខងាររៀបចំផែនការថវិកា និង មុខងារលទ្ធកម្មពេញលេញទៅដល់គ្រប់ការដ្ឋាននៃប្រព័ន្ធ FMIS
- ការអភិវឌ្ឍ និង ដាក់ឱ្យដំណើរការប្រព័ន្ធរបាយការណ៍ធុរកិច្ចឆ្លាតវៃ ( BI Reports )
- ការអភិវឌ្ឍមុខងារ ២ ថ្មីបន្ថែមទៀតគឺ មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង មុខងារគ្រប់គ្រងបញ្ជីសារពើភណ្ឌ
- ការអភិវឌ្ឍមុខងារសន្ធានកម្មថ្មីៗបន្ថែមទៀតជាមួយប្រព័ន្ធពាក់ព័ន្ធខាងក្រៅ
- ការអភិវឌ្ឍ និង ដាក់ឱ្យដំណើរការកម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់រដ្ឋបាលឃុំ-សង្កាត់ និង រដ្ឋបាលស្រុក ( FMIS Portal ) ផ្សារភ្ជាប់ជាមួយនឹងមុខងារស្នូលនៃប្រព័ន្ធ FMIS
- ការពង្រីកសមត្ថភាពមជ្ឈមណ្ឌលទិន្នន័យរបស់គម្រោង FMIS
- ការពង្រឹងសមត្ថភាពគ្រប់គ្រង និង ត្រួតពិនិត្យផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន ។

**"ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០២០-២០២៥"** បានដាក់ចេញនូវគោលដៅធំចំនួន ២ ផ្សារភ្ជាប់នឹងការប្រើប្រាស់ប្រព័ន្ធ FMIS រួមមាន៖

- ការកាត់តម្រឹមជំហាននៃនីតិវិធីអនុវត្តការងារដែលនៅខាងក្រៅប្រព័ន្ធ FMIS ជាអតិបរមា ឬ ទាំងស្រុង ដោយនឹងត្រូវកំណត់ថេរវេលាច្បាស់លាស់ ក្នុងការអនុវត្តការងារនៅដំណាក់កាលនីមួយៗ ពីដំណាក់កាលចាប់ផ្តើមរហូតដល់ដំណាក់កាលចុងក្រោយនៃនីតិវិធីអនុវត្តការងារ
- ការកាត់បន្ថយឯកសារជាក្រដាស ដែលប្រើប្រាស់នៅខាងក្រៅប្រព័ន្ធ FMIS ជាអតិបរមា ឬ ទាំងស្រុង ។

# ២.ស្ថានភាពបច្ចុប្បន្ននៃបច្ចេកវិទ្យាព័ត៌មានក្នុង កសហវ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចចាត់ទុកថាជាក្រសួងមួយដែលមានការវិវឌ្ឍខ្លួនយ៉ាងរហ័ស ក្នុងការចាប់យកបច្ចេកវិទ្យាព័ត៌មាន និង បច្ចេកវិទ្យាឌីជីថល មកប្រើប្រាស់ដើម្បីជាកម្លាំងជំរុញក្នុងការអភិវឌ្ឍស្ថាប័ន, ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការធ្វើទំនើបកម្ម និង បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង បង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងកិច្ចការងារផ្ទៃក្នុងជាច្រើនផ្សេងទៀត ។ បច្ចុប្បន្ន កសហវ បានកសាងរួចរាល់នូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើនផ្នែក, បានរៀបចំ និង ដាក់ឱ្យដំណើរការនូវកម្មវិធី និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួន និង មានធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មានដែលមានសមត្ថភាពជាច្រើនរូប ។

## ២.១.ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន

### ២.១.១.មជ្ឈមណ្ឌលទិន្នន័យ

មជ្ឈមណ្ឌលទិន្នន័យ គឺសំដៅទៅលើអគារ ឬ បន្ទប់នៅក្នុងអគារ ដែលជាទីតាំងទ្រទ្រង់ដល់ដំណើរការនៃប្រព័ន្ធប្រតិបត្តិការម៉ាស៊ីនមេ, ឧបករណ៍ ឬ ប្រព័ន្ធរក្សាទុកទិន្នន័យ, ឧបករណ៍បណ្តាញតភ្ជាប់រួម, ប្រព័ន្ធគ្រប់គ្រងទិន្នន័យរួម ជាដើម ។ បច្ចុប្បន្ន កសហវ បានកសាងរួចរាល់នូវមជ្ឈមណ្ឌលទិន្នន័យ ចំនួន ៤ ធំៗ រួមមាន៖

- ✓ មជ្ឈមណ្ឌលទិន្នន័យនៃគម្រោង FMIS
- ✓ មជ្ឈមណ្ឌលទិន្នន័យនៃអគ្គនាយកដ្ឋានពន្ធដារ
- ✓ មជ្ឈមណ្ឌលទិន្នន័យនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា និង
- ✓ មជ្ឈមណ្ឌលទិន្នន័យរួមនៃ កសហវ ។

ក្នុងចំណោមមជ្ឈមណ្ឌលទិន្នន័យទាំង ៤ ខាងលើ, មានមជ្ឈមណ្ឌលទិន្នន័យចំនួន ២ ដែលមានមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យគឺ ១-មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យនៃគម្រោង FMIS, ២-មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ។ ជាមួយគ្នានេះ មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យដែលមានស្រាប់បច្ចុប្បន្ន ក៏មិនទាន់គោរពបាននូវលក្ខខណ្ឌបច្ចេកទេសគ្រប់គ្រាន់នៅឡើយដែរ ដែលទាមទារឱ្យមានការគិតគូរក្នុងការពង្រឹង និង កែលម្អបន្ថែម ស្របតាមបទដ្ឋានបច្ចេកទេស ។ ដោយឡែក អគ្គនាយកដ្ឋានពន្ធដារ, បើទោះបីជាមិនទាន់មានមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ ក៏អគ្គនាយកដ្ឋានបានរៀបចំនូវប្រព័ន្ធសង្គ្រោះ និង បម្រុងទិន្នន័យប្រកបដោយការទុកចិត្ត និង អាចធានាបាននូវការមិនបាត់បង់ទិន្នន័យ និង និរន្តរភាពនៃការងារក្នុងកម្រិតមួយផងដែរ ។ ចំណែកឯ មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យរួមនៃ កសហវ គឺមិនទាន់មាននៅឡើយផងដែរ ដែលជាចំណុចត្រូវមានការគិតគូរបន្ថែមសម្រាប់រយៈពេលវែង ។

មជ្ឈមណ្ឌលទិន្នន័យនីមួយៗក្នុងក្របខណ្ឌ កសហវ ខាងលើកសាងឡើងក្នុងគោលបំណងគាំទ្រដល់ការធ្វើទំនើបកម្មការគ្រប់គ្រងការងារនៅក្នុងអង្គភាពផ្សេងគ្នា, គាំទ្រដល់ការងារកែទម្រង់នានា និង ប្រើប្រាស់ធនធានមនុស្សរបស់អង្គភាពរៀងៗខ្លួន ។ មជ្ឈមណ្ឌលទិន្នន័យនៃគម្រោង FMIS គាំទ្រដល់ការធ្វើទំនើបកម្មការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា, មជ្ឈមណ្ឌលទិន្នន័យនៃអគ្គនាយកដ្ឋានពន្ធដារ គាំទ្រដល់ការធ្វើទំនើបកម្មការផ្តល់សេវាពន្ធដារ និង ការគ្រប់គ្រងចំណូលពន្ធដារ, មជ្ឈមណ្ឌលទិន្នន័យនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា គាំទ្រដល់ការធ្វើទំនើបកម្មការផ្តល់សេវាគយ, ការគ្រប់គ្រងចំណូលគយ និង រដ្ឋាករ, ការគ្រប់គ្រងប្រតិបត្តិការគយ និង ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការគយ ។ ដោយឡែក មជ្ឈមណ្ឌលទិន្នន័យរួមនៃ កសហវ កសាងឡើងក្នុងគោលបំណងគាំទ្រការធ្វើទំនើបកម្មការគ្រប់គ្រង និង ផ្តល់សេវាផ្សេងៗទៀត (ដែលនៅសេសសល់ក្រៅពីសេវាផ្នែកពន្ធដារ និង សេវាផ្នែកគយ), ការគ្រប់គ្រងកិច្ចការងារផ្ទៃក្នុងនានា (ដូចជា ការគ្រប់គ្រងធនធានមនុស្ស, ការគ្រប់គ្រងកិច្ចការរដ្ឋបាល, ការទំនាក់ទំនងផ្ទៃក្នុង ជាដើម របស់អង្គភាពក្រោមឱវាទ កសហវ ក្រៅពីអង្គភាពដែលមានមជ្ឈមណ្ឌលទិន្នន័យខាងលើ), ការគ្រប់គ្រងគេហទំព័រ និង អ៊ីមែលរួម, ការចែកចាយសេវាអ៊ីនធឺណិតរួម និង ការធ្វើជាមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យសម្រាប់អង្គភាពផ្សេងទៀត ។ ប៉ុន្តែ ធនធានបច្ចេកវិទ្យាព័ត៌មាននៅក្នុងមជ្ឈមណ្ឌលទិន្នន័យរួមរបស់ កសហវ បច្ចុប្បន្ននៅមានកម្រិតនៅឡើយក្នុងការទ្រទ្រង់នូវតម្រូវការដែលបានកើនឡើង ។




**រូបភាពទី ២.១:** មជ្ឈមណ្ឌលទិន្នន័យក្នុងក្របខណ្ឌ កសហវ

មជ្ឈមណ្ឌលទិន្នន័យទាំងអស់ បានភ្ជាប់រួចរាល់ទៅកាន់បណ្តាញតភ្ជាប់ឆ្អឹងខ្នងរួមរបស់ កសហវ (បច្ចុប្បន្នហៅថា បណ្តាញអ៊ីនត្រាណិតរួម កសហវ) ប៉ុន្តែមិនទាន់បានប្រើប្រាស់ទូលំទូលាយ ក្នុងការផ្លាស់ប្តូរទិន្នន័យរវាងគ្នានៅឡើយ ដោយប្រើប្រាស់ទៅតាមតម្រូវការចាំបាច់មួយចំនួនតែប៉ុណ្ណោះ ដូចជា ការធ្វើសន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ និង ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ, ការធ្វើសន្ទានកម្មរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ និង ការធ្វើសន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ និង ប្រព័ន្ធថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ជាដើម ។

ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់មជ្ឈមណ្ឌលទិន្នន័យនីមួយៗ មានភាពខុសគ្នាខ្លះ និង ដូចគ្នាខ្លះ ផ្អែកតាមតម្រូវការនៃការកសាងមជ្ឈមណ្ឌលទិន្នន័យនីមួយៗ និង នៅមិនទាន់បានគិតគូរជាក្របខណ្ឌរួម ក្នុងការចែករំលែកធនធានបច្ចេកវិទ្យាព័ត៌មានដែលនៅសេសសល់ សម្រាប់គាំទ្រដល់អង្គភាពក្រោមឱវាទ កសហវ ផ្សេងទៀតដែលមានតម្រូវការក្នុងការធ្វើទំនើបកម្មការគ្រប់គ្រងការងាររបស់ខ្លួននៅឡើយ ។

## ២.១.២.បណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង និង បណ្តាញអ៊ីនធឺណិត

បណ្តាញតភ្ជាប់ IT ផ្ទៃក្នុង កសហវ ត្រូវបានរៀបចំរួចរាល់មួយចំនួនធំទាំងបណ្តាញតភ្ជាប់ផ្ទៃក្នុងអង្គភាព និង បណ្តាញតភ្ជាប់អន្តរអង្គភាពនៅក្រោមឱវាទ កសហវ ។ នៅក្នុងទីស្តីការ កសហវ ផ្ទាល់ បណ្តាញតភ្ជាប់ស្នូលត្រូវបានរៀបចំរួចរាល់ជាជំហានបឋម ដែលអាចបម្រើដល់ការផ្តល់សេវាអ៊ីនធឺណិតរួមនៅទូទាំងទីស្តីការ កសហវ, សេវាចែករំលែកទិន្នន័យឌីជីថល, ការទំនាក់ទំនងផ្ទៃក្នុងតាមរយៈទូរសព្ទ IP (IP Phone) និង ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុងរបស់អង្គភាពដែលស្ថិតនៅក្នុងទីស្តីការ កសហវ ដូចជា ប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រី និង បុគ្គលិក, ប្រព័ន្ធគ្រប់គ្រងឯកសារ ជាដើម ។ ការតភ្ជាប់បណ្តាញនៅក្នុងទីស្តីការ កសហវ មានពីរប្រភេទគឺ ការតភ្ជាប់ដោយប្រើប្រាស់ខ្សែ (Wire) និង ការតភ្ជាប់ដោយឥតខ្សែ (Wi-Fi) ។ សម្រាប់អង្គភាពក្រោមឱវាទ កសហវ ដែលស្ថិតនៅក្រៅទីស្តីការ កសហវ ក៏មានបណ្តាញតភ្ជាប់ផ្ទៃក្នុងអគាររបស់ខ្លួនផងដែរសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរៀងៗខ្លួន ។

ដោយឡែក អង្គភាពក្រោមឱវាទ កសហវ នៅថ្នាក់មូលដ្ឋាន ដូចជា មន្ទីរ សហវ និង រតនាគាររាជធានី-ខេត្ត ស្ទើរតែទាំងអស់ មិនទាន់មានបណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានស្នូល សម្រាប់គាំទ្រដល់កិច្ចការងារប្រចាំថ្ងៃរបស់ខ្លួននៅឡើយទេ ដោយមានតែបណ្តាញតភ្ជាប់សម្រាប់ក្របខណ្ឌនៃការប្រើប្រាស់ប្រព័ន្ធ FMIS តែប៉ុណ្ណោះ ។ ចំណែកឯ សាខាពន្ធដារ និង សាខា/ការិយាល័យគយ និង រដ្ឋាករ ភាគច្រើនបានតភ្ជាប់បណ្តាញផ្ទៃក្នុងរួចរាល់ សម្រាប់ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានរៀងខ្លួន ជាពិសេសលើការគ្រប់គ្រងការប្រមូលចំណូលពន្ធដារ និង ចំណូលគយ និង រដ្ឋាករ ។

ជាមួយគ្នានេះ កសហវ ក៏បានរៀបចំដំឡើងរួចរាល់មួយចំនួនធំនូវបណ្តាញតភ្ជាប់ឆ្អឹងខ្នងដោយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកនៅទូទាំងប្រទេសក្នុងឆ្នាំ ២០២០ ហៅថា បណ្តាញអ៊ីនត្រាណិតរួម កសហវ និង បានបញ្ចប់ការដាក់ឱ្យដំណើរការក្នុងជំហានទី ១ រួចរាល់ ដោយតភ្ជាប់ចេញពីទីស្តីការ កសហវ ទៅកាន់ទីតាំងមជ្ឈមណ្ឌលទិន្នន័យទាំងអស់របស់ កសហវ, ទីតាំងនៃអគ្គនាយកដ្ឋានដែលស្ថិតនៅក្រៅ ទីស្តីការ កសហវ, មន្ទីរ សហវ រាជធានី-ខេត្ត, រតនាគាររាជធានី-ខេត្ត, សាខា និង ការិយាល័យគយរាជធានី-ខេត្តមួយចំនួនដែលស្ថិតនៅតំបន់ក្រុង និង សាខាពន្ធដាររាជធានី-ខេត្ត ស្ទើរតែទាំងអស់សរុបជាង ១០០ ការដ្ឋាន ។ បើទោះបីជាមានបណ្តាញអ៊ីនត្រាណិតរួមនេះ ក៏ការប្រើប្រាស់សេវាបច្ចេកវិទ្យាព័ត៌មាននៅលើបណ្តាញនេះនៅមានកម្រិតនៅឡើយ ពោលគឺ នៅប្រើប្រាស់សម្រាប់តែសេវាផ្ទៃក្នុងរបស់អង្គភាពរៀងខ្លួនតែប៉ុណ្ណោះ លើកលែងតែប្រព័ន្ធសន្និសីទវីដេអូ កសហវ ដែលបានដំណើរការនៅលើបណ្តាញនេះជារួម សម្រាប់ការរៀបចំកិច្ចប្រជុំរវាងអង្គភាពក្រោមឱវាទ កសហវ មួយភាគធំ ។

សម្រាប់បណ្តាញអ៊ីនធឺណិតត្រូវបានប្រើប្រាស់ផ្សេងៗគ្នាសម្រាប់ទីស្តីការ កសហវ, អគ្គនាយកដ្ឋាននៅក្រៅទីស្តីការ កសហវ និង អង្គភាពនានានៅថ្នាក់មូលដ្ឋាន ។ នៅក្នុងទីស្តីការ កសហវ គ្រប់អគារត្រូវ

បានប្រើប្រាស់សេវាអ៊ីនធឺណិតរួម តាមរយៈបណ្តាញតភ្ជាប់ផ្ទៃក្នុងដូចមានរៀបរាប់ខាងលើ ទាំងបណ្តាញមានខ្សែ និង បណ្តាញឥតខ្សែ ។




**រូបភាពទី ២.២:** ហេដ្ឋារចនាសម្ព័ន្ធបណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានរបស់ កសហវ

## ២.១.៣.ឧបករណ៍បច្ចេកវិទ្យាព័ត៌មានសម្រាប់អ្នកប្រើប្រាស់

ក្នុងយុគសម័យឌីជីលថលនេះ មន្ត្រីរាជការ និង បុគ្គលិក កសហវ ភាគច្រើនមានម៉ាស៊ីនកុំព្យូទ័រ, ម៉ាស៊ីនបោះពុម្ព, ម៉ាស៊ីនស្កែន ជាដើម ប្រើប្រាស់នៅតាមការិយាល័យ និង អង្គភាពរៀងៗខ្លួន ដើម្បីធ្វើការរៀបចំ និង បោះពុម្ពឯកសាររដ្ឋបាល ឬ ឯកសារនានា, ធ្វើការទំនាក់ទំនងការងារតាមរយៈអ៊ីមែល ឬ កម្មវិធីទំនាក់ទំនងសង្គម, ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ប្រតិបត្តិការផ្ទៃក្នុង និង ការប្រើប្រាស់សេវាអ៊ីនធឺណិតសម្រាប់ការងារស្រាវជ្រាវ ជាដើម ។

យោងតាមលទ្ធផលនៃកម្រងសំណួរកាលពីក្នុងឆ្នាំ ២០១៩, កសហវ មានម៉ាស៊ីនកុំព្យូទ័រសរុបទាំងអស់ចំនួនប្រមាណ ៤ ៧០០ គ្រឿង ទាំងកុំព្យូទ័រលើតុ និង កុំព្យូទ័រយួរដៃ ដែលមានន័យថា កសហវ មានមន្ត្រី និង បុគ្គលិកប្រមាណជាង ៨០% មានម៉ាស៊ីនកុំព្យូទ័រប្រើប្រាស់សម្រាប់បំពេញការងារប្រចាំថ្ងៃរួមទាំងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ទន្ទឹមនឹងនេះ ស្ទើរតែគ្រប់មន្ត្រី និង បុគ្គលិកទាំងអស់មានឧបករណ៍ទូរសព្ទដៃឆ្លាតវៃ (Smart Phone) សម្រាប់ប្រើប្រាស់ជាមធ្យោបាយទំនាក់ទំនង និង ប្រើប្រាស់កម្មវិធីបច្ចេកវិទ្យាព័ត៌មានមួយចំនួនជាជំនួយនៅក្នុងការងាររបស់អង្គភាព ឬ ស្ថាប័ន ។



**រូបភាពទី ២.៣**: ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាននៅកន្លែងការងារ

ទោះជាយ៉ាងនេះក្តី ការប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័ររបស់អ្នកប្រើប្រាស់គឺនៅជួបប្រទះនូវបញ្ហាប្រឈម ដែលត្រូវគិតគូរក្នុងការពង្រឹងបន្ថែម ព្រោះកុំព្យូទ័ររបស់អ្នកប្រើប្រាស់ភាគច្រើនមិនមានអាជ្ញាបណ្ណប្រព័ន្ធ ឬ កម្មវិធីបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រាន់ឡើយ ទាំងប្រព័ន្ធប្រតិបត្តិការម៉ាស៊ីនកុំព្យូទ័រ (Operating System), ទាំងកម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារការិយាល័យ (Microsoft Office) និង កម្មវិធីបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់ការងារផ្សេងៗទៀត ។ ម្យ៉ាងទៀត ម៉ាស៊ីនកុំព្យូទ័រមួយចំនួនត្រូវបានប្រើប្រាស់ដោយសេរី ដូចជា ការដំឡើងកម្មវិធីបច្ចេកវិទ្យាព័ត៌មានផ្សេងៗដែលទាញពីបណ្តាញអ៊ីនធឺណិត ឬ ការប្រើប្រាស់ឧបករណ៍រក្សាទិន្នន័យ (USB Drive) ដោតចុះដោតឡើង ។ល។ ដែលបង្កឱ្យមានការកើតឡើងនូវបញ្ហាមួយចំនួន រួមមាន ការឆ្លងមេរោគក្នុងកុំព្យូទ័រ, ការបាត់បង់ឯកសារ, ការខូចកម្មវិធីក្នុងកុំព្យូទ័រ, ការខូចខាតឯកសារ ជាដើម ។ សម្រាប់ម៉ាស៊ីនបោះពុម្ពភាគច្រើនអ្នកប្រើប្រាស់មានដោយឡែកៗពីគ្នា បើទោះបីជាអង្គុយនៅក្នុងបន្ទប់ការងារជាមួយគ្នាក៏ដោយ ហើយភាគតិចណាស់ដែលមានបន្ទប់ការិយាល័យមួយចំនួនមានការរៀបចំប្រើប្រាស់ម៉ាស៊ីនបោះពុម្ពតភ្ជាប់បណ្តាញប្រើប្រាស់រួមគ្នា ។

## ២.២.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

កសហវ បានដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើនរួចហើយ ក្នុងការជួយសម្រួលដល់ការផ្តល់សេវាសាធារណៈ, ការគ្រប់គ្រងកិច្ចការងារស្នូលរបស់ កសហវ (ដូចជា ថវិកា, លទ្ធកម្ម, ចំណូល, ចំណាយ, សាច់ប្រាក់, បំណុល, ទ្រព្យសម្បត្តិរដ្ឋ, គណនេយ្យ និង ហិរញ្ញវត្ថុសាធារណៈ ។ល។) រួមទាំងការគ្រប់គ្រងកិច្ចការរដ្ឋបាល និង កិច្ចការបុគ្គលិក ជាដើម ។ ម្យ៉ាងទៀត ជាចំណែកនៃការរៀបចំរដ្ឋាភិបាលអេឡិចត្រូនិក (e-Government) កសហវ បានដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនដែលមានការផ្លាស់ប្តូរទិន្នន័យជាមួយនឹងអង្គភាពរដ្ឋផ្សេងទៀត ហៅថា G2G (Government to Government), ផ្លាស់ប្តូរទិន្នន័យជាមួយធុរជនហៅថា G2B (Government to Business) និង ផ្លាស់ប្តូរទិន្នន័យជាមួយសាធារណជន ហៅថា G2C (Government to Citizen) ។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រខុសៗគ្នា ក្នុងនោះមានមួយចំនួន ប្រើប្រាស់ផលិតផលក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិ (COTS Software), មួយចំនួនប្រើប្រាស់ធនធានរបស់អង្គភាពក្នុងការផលិត (In-House Development) និង មួយចំនួនទៀតជួលក្រុមហ៊ុនឯកជនក្នុងស្រុកក្នុងការផលិត ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានធំៗបច្ចុប្បន្នរបស់ កសហវ រួមមាន៖

- ✓ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)
- ✓ ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ
- ✓ ប្រព័ន្ធបញ្ជរតែមួយជាតិ និង ប្រព័ន្ធបញ្ជរតែមួយអាស៊ាន
- ✓ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ
- ✓ ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)
- ✓ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ។




**រូបភាពទី ២.៤**: ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានធំៗរបស់ កសហវ

## ២.២.១.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

ប្រព័ន្ធ FMIS ជាប្រព័ន្ធស្នូលមួយដ៏សំខាន់សម្រាប់គាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលនៅគ្រប់ដំណាក់កាល និង ប្រើប្រាស់ក្នុងការគ្រប់គ្រងការរៀបចំ និង អនុវត្តថវិកាជាតិ (ចំណូល-ចំណាយ), ការអនុវត្តកិច្ចលទ្ធកម្ម, កិច្ចបញ្ជិកាគណនេយ្យសាធារណៈ, ការគ្រប់គ្រងសាច់ប្រាក់ និង ធនាគារ, និង ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសាធារណៈ ។ ប្រព័ន្ធ FMIS មានមុខងារ

ស្នូលចំនួន ៦ ពាក់ព័ន្ធនឹងការអនុវត្តថវិកា និង កិច្ចការរតនាគារ រួមមាន មុខងារវិភាជន៍ថវិកា, មុខងារធានាចំណាយ និង ការទិញ, មុខងារគណនីត្រូវសង និង ចំណាយថវិកា, មុខងារគណនីត្រូវទារ និង ចំណូលថវិកា, មុខងារគ្រប់គ្រងសាច់ប្រាក់ និង មុខងារសៀវភៅធំ ។ នៅក្នុងឆ្នាំ ២០២០ ប្រព័ន្ធ FMIS បានអភិវឌ្ឍនូវមុខងារថ្មីបន្ថែមពីរទៀតគឺ មុខងាររៀបចំផែនការថវិកា និង មុខងារលទ្ធកម្មពេញលេញ ដែលនឹងចាប់-ផ្ដើមអនុវត្តសាកល្បងជំហានដំបូងក្នុងឆ្នាំ ២០២១ ។

ប្រព័ន្ធ FMIS ជាប្រព័ន្ធដែលមានរំហូរប្រតិបត្តិការហិរញ្ញវត្ថុ និង ថវិកា រវាងអង្គភាពរដ្ឋនានាជាមួយនឹង កសហវ (G2G) ដែលជាផ្នែកមួយនៃរដ្ឋាភិបាលអេឡិចត្រូនិក និង ឌីជីថល ។ ប្រព័ន្ធ FMIS បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការចាប់តាំងពីឆ្នាំ ២០១៥ និង រហូតមកដល់ឆ្នាំ ២០២០ បានដាក់ដំណើរការប្រើប្រាស់នៅការដ្ឋានសរុបជាង ១២០ រួមមាន អគ្គនាយកដ្ឋានគន្លឹះៗនៃ កសហវ (ដូចជា អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង គ្រប់គ្រងបំណុល, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, អគ្គាធិការដ្ឋាន និង អគ្គនាយកដ្ឋានគោលនយោបាយ), អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័នទាំងអស់, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំងអស់នៅថ្នាក់កណ្ដាល, មន្ទីរ សហវ រាជធានី-ខេត្ត និង រតនាគាររាជធានី-ខេត្តទាំងអស់ នៅទូទាំងប្រទេស ដែលមានអ្នកប្រើប្រាស់សរុបក្នុងរង្វង់ ១៦៦០ នាក់ ។




**រូបភាពទី ២.៥**: ទិដ្ឋភាពទូទៅនៃប្រព័ន្ធ FMIS

ប្រព័ន្ធ FMIS បានធ្វើសន្ទានកម្មផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនរួចហើយ ដូចជា ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ (ចំណូលគយ និង រដ្ឋាករ), ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ (ចំណូលពន្ធដារ), ប្រព័ន្ធ NRMIS (ចំណូលមិនមែនសារពើពន្ធ), ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបំណុលសាធារណៈ (ចំណូលមូលធន), ប្រព័ន្ធធនាគាររបស់ធនាគារជាតិកម្ពុជា និង ប្រព័ន្ធធនាគាររបស់ធនាគារពាណិជ្ជដៃគូ រួមមាន ធនាគារអេស៊ីលីដា, ធនាគារកាណាឌីយ៉ា, ធនាគារកម្ពុជាសាធារណៈ, ធនាគារវឌ្ឍនៈ, ធនាគារជេថ្រាស់រ៉ូយ៉ាល់, ធនាគារស្ថាបនា និង ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ។

ជាមួយគ្នានេះ ក្នុងឆ្នាំ ២០២០ ប្រព័ន្ធ FMIS បានចាប់ផ្តើមដាក់ឱ្យដំណើរការនូវការតម្រង់ទិសនីតិវិធីអនុវត្តការងារថ្មីលើការបើកផ្តល់បៀវត្ស និង ទូទាត់ចំណាយមួយចំនួនដែលមានហានិភ័យទាបដែលជាជំហានចាប់ផ្តើមដ៏ល្អប្រសើរ សម្រាប់ការងារតម្រង់ទិសនីតិវិធីអនុវត្តការងារផ្សេងទៀតតាមប្រព័ន្ធ FMIS ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបច្ចុប្បន្នកំពុងតែអនុវត្តទាំងនៅក្នុងប្រព័ន្ធ និង នៅខាងក្រៅប្រព័ន្ធ ដោយនឹងត្រូវប្រែក្លាយឱ្យទៅជានីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ទាំងស្រុង ដើម្បីពង្រឹង និង បង្កើនបន្ថែមទៀតនូវតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ប្រព័ន្ធ FMIS ជាប្រព័ន្ធដំណើរការលើវ៉ិបជាមូលដ្ឋាន (Web Based) ប្រើប្រាស់ផលិតផលក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិ ប៉ុន្តែត្រូវបានកែសម្រួល និង អភិវឌ្ឍបន្ថែមដោយប្រើប្រាស់ធនធានមនុស្សដែលមានស្រាប់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អមដោយជំនួយពីទីប្រឹក្សាបច្ចេកទេសមួយចំនួនតាមការចាំបាច់នៃកម្រិតស្មុគស្មាញផ្នែកបច្ចេកទេស ។

## ២.២.២.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា

### ២.២.២.១.ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ

ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ ត្រូវបានរៀបចំ និង កសាងឡើងនូវប្រព័ន្ធមួយចំនួនដាច់ដោយឡែកពីគ្នា ដោយប្រព័ន្ធទីមួយហៅថា ASYCUDA ជាប្រព័ន្ធដែលអភិវឌ្ឍដោយសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ (UNCTAD) ប្រើប្រាស់ក្នុងការគ្រប់គ្រងប្រតិបត្តិការនាំចេញ-នាំចូល និង ចំណូលគយពីការធ្វើប្រតិវេទន៍គយធម្មតា ។ មុខងារសំខាន់ៗនៃប្រព័ន្ធនេះ រួមមាន មុខងារស្វ័យប្រវត្តិកម្មប្រតិវេទន៍គយ (នាំចេញ-នាំចូល), មុខងារគ្រប់គ្រងបណ្ណបញ្ជីទំនិញពីគយ, មុខងារគ្រប់គ្រងឃ្លាំងគយមានដែនកំណត់, មុខងារគ្រប់គ្រងកិច្ចការគណនេយ្យ (ទូទាត់, បង្វិលសង, ទូទាត់អេឡិចត្រូនិក - e-Payment ជាដើម), មុខងារគ្រប់គ្រងបង្កាន់ដៃពន្ធយានយន្ត, មុខងារគ្រប់គ្រងលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យ និង វាយតម្លៃប្រព្រឹត្តិកម្មប្រតិវេទន៍គយតាមកម្រិតហានិភ័យ, មុខងារគ្រប់គ្រងនិវេទនបណ្ណទំនិញ និង មុខងារកត់ត្រាលទ្ធផលត្រួតពិនិត្យរូបវន្តទំនិញ ។

ចំណែកឯប្រព័ន្ធទីពីរហៅថាប្រព័ន្ធអេឡិចត្រូនិកគយ (E-Customs) អភិវឌ្ឍឡើងដោយមន្ត្រីបច្ចេកទេសរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជាផ្ទាល់ ដើម្បីបំពេញបន្ថែមឱ្យប្រព័ន្ធទីមួយខាងលើ និង គាំទ្រនីតិវិធីគយជាក់លាក់មួយចំនួន ដូចជា ការចុះកិច្ចបញ្ជិកាទំនិញមានស្រាប់ក្នុងប្រទេស, ការធ្វើ

ប្រតិវេទន៍ឆ្លងកាត់គយ, ការចុះកិច្ចបញ្ជិកាប្រតិវេទន៍គយសង្ខេប, ការតាមដានស្ថានភាពប្រតិវេទន៍គយ, ការតាមដានលទ្ធផលស្កែនកុងតឺន័រ, ការគ្រប់គ្រងលើតែមប្រ៊ីអាករលើផលិតផលថ្នាំជក់, ការគ្រប់គ្រងលិខិតអនុញ្ញាតជញ្ជូនទំនិញ និង ផលិតផលតេលសិលា, ការកែបង្កាន់ដៃពន្ធយានយន្ត, ការរៀបចំសលាកបត្របង់ចំណូលថវិកាជាតិ ជាដើម ។ ម្យ៉ាងទៀត ប្រព័ន្ធអេឡិចត្រូនិកគយបានដាក់ឱ្យដំណើរការនូវមុខងារទូទាត់អេឡិចត្រូនិកផងដែរ (e-Payment) ដែលអនុញ្ញាតឱ្យធុរជនធ្វើការទូទាត់បានតាមអនឡាញបានដោយមិនចាំបាច់យកសាច់ប្រាក់ទៅបង់ផ្ទាល់នៅបញ្ជរបង់ប្រាក់ នៃអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជាឡើយ ។

ក្រៅពីនេះ អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជាបានទទួលយក ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស (GTAS) ពីអង្គការគយពិភពលោក (WCO) ដែលបានដាក់ជាប្រភេទបើកទូលាយ (Open Source) សម្រាប់ប្រទេសសមាជិកអាចយកទៅប្រើប្រាស់ និង អភិវឌ្ឍមុខងារបន្ថែមសម្រាប់គ្រប់គ្រងការត្រួតពិនិត្យអ្នកដំណើរតាមផ្លូវអាកាសសំដៅបង្ការ និង បង្ក្រាបបទល្មើសឆ្លងដែនតាមផ្លូវអាកាស មានជាអាទិ៍ ការរត់គេចពន្ធ, ការលាងសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម, ការជួញដូរគ្រឿងញៀន និង បទល្មើសឆ្លងដែនផ្សេងទៀត ។

បន្ថែមលើនេះ ស្ថិតក្រោមក្របខណ្ឌអាស៊ាន អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា បានចូលរួមជាមួយប្រទេសសមាជិកអាស៊ានផ្សេងទៀត ដើម្បីដាក់ឱ្យអនុវត្តប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS) សំដៅជួយសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់អន្តរជាតិក្នុងតំបន់អាស៊ាន ។ ប្រព័ន្ធនេះ ត្រូវបានអភិវឌ្ឍ និង គាំទ្រដោយក្រុមការងារគម្រោង ARISE+ ហើយប្រសិនបើប្រទេសសមាជិកអាស៊ានណាមួយចង់កែសម្រួល ឬ បន្ថែមមុខងារនានានៅក្នុងប្រព័ន្ធ អាចលើកជាសំណើនៅក្នុងកិច្ចប្រជុំក្រុមការងារអាស៊ាន។




**រូបភាពទី ២.៦**: ទិដ្ឋភាពទូទៅនៃប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ

ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការចាប់ពីឆ្នាំ ២០០៨ និង រហូតមកដល់ឆ្នាំ ២០២០ នេះ ប្រើប្រាស់នៅការដ្ឋានសរុបចំនួនជាង ៨៤ ទីតាំង រួមមាន នាយកដ្ឋាន, សាខា និង ការិយាល័យគយ និង រដ្ឋាករនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា នៅទូទាំងប្រទេស ដោយគ្រប-ដណ្តប់ទាំងស្រុងលើអង្គភាពគយ និង រដ្ឋាករដែលមានប្រតិបត្តិការនាំចេញ-នាំចូល និង ប្រើប្រាស់ដោយមន្ត្រីគយ, ធុរជន និង ជើងសាគយចំនួនប្រមាណ ៨០០០ នាក់ ។ ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករបានដំណើរការមុខងារសន្ទានកម្មផ្លាស់ប្តូរទិន្នន័យ ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់រាជរដ្ឋា-ភិបាល រួមមាន ប្រព័ន្ធ FMIS, ប្រព័ន្ធគ្រប់គ្រងយានយន្តរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន, ប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ, ប្រព័ន្ធបញ្ជរតែមួយជាតិ និង ប្រព័ន្ធបញ្ជរតែមួយអាស៊ាន ។

### ២.២.២.២.ប្រព័ន្ធបញ្ជរតែមួយជាតិ និង ប្រព័ន្ធបញ្ជរតែមួយអាស៊ាន

ប្រព័ន្ធបញ្ជរតែមួយជាតិ គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលអនុញ្ញាតឱ្យភាគីពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មដឹកជញ្ជូនទំនិញឆ្លងដែន (នាំចេញ-នាំចូល) ដាក់ស្នើព័ត៌មានដោយភ្ជាប់នឹងសំណុំឯកសារនៅត្រង់ច្រកចូលរួមតែមួយ ជាពិសេសសម្រាប់មុខទំនិញដែលជាកម្មវត្ថុនៃការស្នើសុំអាជ្ញាប័ណ្ណ, លិខិតអនុញ្ញាត, វិញ្ញាបនបត្រ ជាដើម ។ ប្រព័ន្ធនេះជាចំណែកមួយនៃរដ្ឋាភិបាលអេឡិចត្រូនិកដែលផ្លាស់ប្តូរព័ត៌មានរវាងអង្គភាពរដ្ឋ និង រដ្ឋ (G2G), ផ្លាស់ប្តូរព័ត៌មានរវាងរដ្ឋ និង ធុរជន (G2B) និង ផ្លាស់ប្តូរព័ត៌មានរវាងធុរជន និង ធុរជន (B2B) ។

ប្រព័ន្ធបញ្ជរតែមួយជាតិ បានចាប់ផ្តើមដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ ២០១៩ ដោយមានក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនចូលរួមអនុវត្តជាមួយអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា រួមមាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងពាណិជ្ជកម្ម, ក្រសួងសុខាភិបាល, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ ទន្ទឹមនឹងនេះ ប្រព័ន្ធបញ្ជរតែមួយជាតិក៏បានដាក់ឱ្យដំណើរការនូវសេវាផ្តល់លិខិតអនុញ្ញាតគយតាមអនឡាញផងដែរ ដែលអនុញ្ញាតឱ្យធុរជនស្នើសុំលិខិតអនុញ្ញាតគយដោយខ្លួនឯង មិនចាំបាច់ធ្វើដំណើរទៅកាន់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជាឡើយ ។

ចំណែកឯប្រព័ន្ធបញ្ជរតែមួយអាស៊ាន គឺជាប្រព័ន្ធរួមរបស់សហគមន៍អាស៊ាន ដែលត្រូវបានតភ្ជាប់សន្ទានកម្មជាមួយប្រព័ន្ធបញ្ជរតែមួយរបស់ប្រទេសជាសមាជិកអាស៊ានទាំងអស់ រួមទាំងព្រះរាជាណាចក្រ-កម្ពុជាផងដែរ ។ បច្ចុប្បន្ន ប្រព័ន្ធនេះបាននឹងកំពុងធ្វើការផ្លាស់ប្តូរទិន្នន័យវិញ្ញាបនបត្រដើមកំណើតទំនិញក្នុងទម្រង់ជាអេឡិចត្រូនិក (ATIGA e-Form D) ទិន្នន័យប្រតិវេទន៍គយអាស៊ាន (ACDD) និង ត្រៀមផ្លាស់ប្តូរឯកសារផ្សេងៗទៀត តាមការចាំបាច់ពាក់ព័ន្ធនឹងពាណិជ្ជកម្មឆ្លងកាត់ព្រំដែននៅពេលខាងមុខ ក៏ដូចជាការពង្រីកការផ្លាស់ប្តូរជាមួយប្រទេសដៃគូពាណិជ្ជកម្មផ្សេងទៀតក្រៅពីអាស៊ានផងដែរ ។

ក្រៅពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដូចបានរៀបរាប់ខាងលើ អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជាបានរៀបចំ និង កសាងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនផ្សេងទៀតសម្រាប់ជាជំនួយក្នុងការគ្រប់គ្រងកិច្ចការងាររបស់សមត្ថកិច្ចគយ រួមមាន៖

- ✓ ប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS) មានមុខងារធ្វើចំណាត់ថ្នាក់ធុរជន ផ្អែកតាមអនុលោមភាព និង សូចនាករហានិភ័យដែលបានកំណត់ដោយ អគរ
- ✓ ប្រព័ន្ធគ្រប់គ្រងទិន្នន័យហានិភ័យគយ (CRMDS) មានមុខងារធ្វើចំណាត់ថ្នាក់ច្រកប្រព្រឹត្តិកម្មប្រតិវេទន៍គយតាមកម្រិតហានិភ័យដែលប្រកាសដោយប្រតិវេទករ ។ បច្ចុប្បន្នប្រព័ន្ធនេះ បានដាក់ឱ្យប្រើប្រាស់នៅតាមសាខា និង ការិយាល័យគយ និង រដ្ឋាករចំនួន ១០ កន្លែង សម្រាប់បំពេញបែបបទសំខាន់ៗ
- ✓ ប្រព័ន្ធផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ (CVDS) មានមុខងារគណនា និង បោះពុម្ពប្រតិវេទន៍តម្លៃគិតពន្ធគយ, រក្សាទុកវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និង ពន្ធប៉ាតង់ប្រចាំឆ្នាំ និង សម្រួលនីតិវិធីការងារផ្ទៃក្នុងមួយចំនួនរបស់មន្ត្រីមានសមត្ថកិច្ច ។

ម្យ៉ាងទៀត អគរ ក៏បានរៀបចំ និង អភិវឌ្ឍកម្មវិធីទូរសព្ទដៃមួយចំនួនផងដែរ ដើម្បីសម្រួលបន្ថែមដល់ធុរជនក្នុងការសិក្សាលើតម្លៃពន្ធគយ, អនុវត្តនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ, ផ្ទៀងផ្ទាត់បង្កាន់ដៃយានយន្ត, ផ្ទៀងផ្ទាត់ឯកសារបោះពុម្ពចេញពីប្រព័ន្ធសម្រាប់មន្ត្រីគយ ជាដើម ។

### ២.២.៣.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ ជាប្រព័ន្ធដែលប្រើប្រាស់សម្រាប់គ្រប់គ្រងរាល់ប្រតិបត្តិការដែលជាមុខងារប្រតិបត្តិការស្នូលរបស់អគ្គនាយកដ្ឋានពន្ធដារ រួមមាន ការចុះបញ្ជីពន្ធដារ និង ការគ្រប់គ្រងព័ត៌មានអ្នកជាប់ពន្ធ (សហគ្រាស និង រូបវន្តបុគ្គល), ការគ្រប់គ្រងលើការប្រកាសពន្ធ និង ការបង់ប្រាក់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការបង្វិលសងអាករលើតម្លៃបន្ថែមតាមអនឡាញ, ការធ្វើសវនកម្មពន្ធ, ការគ្រប់គ្រងបំណុលពន្ធ និង បណ្តឹងតវ៉ា ជាដើម ។ ប្រព័ន្ធនេះបានដាក់ឱ្យដំណើរការនៅតាមអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារចំនួន ៤៨ កន្លែង (រួមមាន នាយកដ្ឋានថ្នាក់កណ្តាល, សាលាជាតិពន្ធដារ, ទីចាត់ការពន្ធដាររាជធានីភ្នំពេញ, សាខាពន្ធដារខេត្ត-ខណ្ឌ និង ការិយាល័យពន្ធដារក្រុង-ស្រុក), ធនាគារពាណិជ្ជដៃគូចំនួន ០៧, ក្រុមហ៊ុនបោះពុម្ពចំនួន ០១ និង រោងចក្រចំនួន ០១ សរុប ៥៧ កន្លែងនៅទូទាំងប្រទេស ដែលប្រើប្រាស់ដោយមន្ត្រីពន្ធដារ, បុគ្គលិករបស់ធនាគារពាណិជ្ជដៃគូ និង បុគ្គលិកក្រុមហ៊ុនបោះពុម្ពតែមប៊ីបារីសរុបចំនួនប្រមាណ ៥៥០០ នាក់ ។

ទន្ទឹមនឹងនេះ ប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារបានដាក់ឱ្យដំណើរការនូវសេវាអនឡាញមួយចំនួនសម្រាប់អ្នកជាប់ពន្ធ និង សាធារណជន រួមមាន ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform), ការប្រកាសពន្ធអាជីវកម្ម, ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ, ការបង់ប្រាក់ពន្ធ, ការស្នើសុំបង្វិលសង អតប, ការស្នើសុំជៀសវាងការយកពន្ធត្រួតគ្នា (DTA), ការស្នើសុំការលើកទឹកចិត្ត, ការប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច, ការបញ្ជូនឯកសារលិខិតប្រកាសពន្ធ និង ការគ្រប់គ្រងការសិក្សាពន្ធដារ ជាដើម ។ ទន្ទឹមនឹងនេះ កម្មវិធីទូរសព្ទដៃមួយចំនួនក៏ត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវព័ត៌មាន, ការជូនដំណឹង, ការគណនា និង ការបង់ប្រាក់ពន្ធសម្រាប់ជាជំនួយដល់អ្នកជាប់ពន្ធ និង សាធារណជនផងដែរ ដូចជា កម្មវិធីទូរសព្ទដៃអ្នកជាប់ពន្ធ, ការត្រួតពិនិត្យ និង តាមដានឯកសារ, ការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់លើលិខិតឧទ្ទេសនាមស្តីពីការចុះធ្វើសវនកម្ម, ការគណនាពន្ធលើបៀវត្ស, ការ

គណនាពន្ធលើមធ្យោបាយដឹកជញ្ជូន, ប្រតិទិនពន្ធដារ, ការជួបសន្ទនាផ្ទាល់ជាមួយមន្ត្រីជំនាញពន្ធដារ និង ការផ្តល់ព័ត៌មានស្តីពីពន្ធដារ ។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ បានធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS ក្នុងការផ្លាស់ប្តូរទិន្នន័យចំណូលពន្ធដារ, ធ្វើសន្ទានកម្មជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ ក្នុងការផ្លាស់ប្តូរទិន្នន័យក្រុមហ៊ុននាំចូល និង ការបង់ពន្ធ, ធ្វើសន្ទានកម្មជាមួយប្រព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម ក្នុងការផ្លាស់ប្តូរទិន្នន័យការចុះបញ្ជីពាណិជ្ជកម្ម, ធ្វើសន្ទានកម្មជាមួយប្រព័ន្ធរបស់ក្រសួងសាធារណការ និង ដឹក-ជញ្ជូន ក្នុងការផ្លាស់ប្តូរទិន្នន័យម្ចាស់កម្មសិទ្ធិយានយន្ត និង ការផ្ទេរកម្មសិទ្ធិ, ធ្វើសន្ទានកម្មជាមួយប្រព័ន្ធរបស់ក្រសួងមហាផ្ទៃ ក្នុងការផ្លាស់ប្តូរទិន្នន័យអត្តសញ្ញាណរបស់ប្រជាពលរដ្ឋ និង ធ្វើសន្ទានកម្មជាមួយប្រព័ន្ធរបស់ធនាគារពាណិជ្ជដៃគូក្នុងការពង្រីកការអនុវត្តការទូទាត់តាមអេឡិចត្រូនិក (e-Payment)។

ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារ ក៏បានរៀបចំ និង អភិវឌ្ឍប្រព័ន្ធ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មានមួយចំនួនសម្រាប់មុខងារគាំទ្រទូទៅ ដូចជា ការគ្រប់គ្រងធនធានមនុស្ស, ការគ្រប់គ្រងការងាររដ្ឋបាល, ការគ្រប់គ្រងការងារបណ្តុះបណ្តាល ជាដើម ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ រួមទាំង ប្រព័ន្ធ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មាននានាដូចមានរៀបរាប់ខាងលើ ត្រូវបានកសាង និង អភិវឌ្ឍដោយមន្ត្រីបច្ចេកទេសរបស់អគ្គនាយកដ្ឋានពន្ធដារផ្ទាល់ ។




**រូបភាពទី ២.៧**: ទិដ្ឋភាពទូទៅនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ

## ២.២.៤.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ហៅកាត់ថា NRMIS ប្រើប្រាស់សម្រាប់កត់ត្រា និង គ្រប់គ្រងចំណូលមិនមែនសារពើពន្ធដែលបានមកពីការផ្តល់សេវាសាធារណៈ និង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ (ចំណូលពីកិច្ចសន្យា, សៀវភៅបន្ទុក, អាជ្ញាប័ណ្ណ ជាដើម), ការបង្វែរចំណូល

ចូលគណនីទោលរតនាគារ និង ការទូទាត់ប្រាក់រង្វាន់ ។ ប្រព័ន្ធនេះក៏ផ្តល់លទ្ធភាពឱ្យអ្នកបង់ប្រាក់ អាចធ្វើការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (e-Payment) បានផងដែរ ដែលបានដាក់ឱ្យដំណើរការសាកល្បងក្នុងត្រីមាសទី ១ ឆ្នាំ ២០២១ និង ពង្រីកការអនុវត្តជាបន្តបន្ទាប់ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

ប្រព័ន្ធ NRMIS បានដាក់ឱ្យប្រើប្រាស់នៅក្រសួង-ស្ថាប័នចំនួន ២៣ នៅថ្នាក់កណ្តាល, អង្គភាព និង មន្ទីរជំនាញនៅថ្នាក់មូលដ្ឋានចំនួន ១៨ នៅទូទាំងរាជធានី-ខេត្ត, និង រតនាគាររាជធានី-ខេត្តទាំង ២៥ ដែលមានអ្នកប្រើប្រាស់ប្រមាណ ១២០០ នាក់ គិតត្រឹមឆ្នាំ ២០២០ ។

ប្រព័ន្ធ NRMIS បានធ្វើសន្ទានកម្មផ្លាស់ប្តូរទិន្នន័យរួចរាល់ជាមួយប្រព័ន្ធ FMIS លើព័ត៌មានចំណូលមិនមែនសារពើពន្ធដែលបង្វែរជាចំណូលថវិកាជាតិ និង បានធ្វើសន្ទានកម្មផ្លាស់ប្តូរព័ត៌មានជាមួយនឹងប្រព័ន្ធរបស់ធនាគារពាណិជ្ជដៃគូពាក់ព័ន្ធនឹងព័ត៌មានវិក្កយបត្រ, ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និង ការបែងចែកចំណូលចូលគណនីផ្សេងគ្នាផងដែរ ។

ប្រព័ន្ធ NRMIS ជាប្រព័ន្ធដែលរៀបចំ និង អភិវឌ្ឍឡើងដោយក្រុមការងារបច្ចេកទេសដើម្បីសម្រួលនីតិវិធីកត់ត្រាចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ដែលមានអង្គភាពចំនួន ៣ គន្លឹះ គឺ អគ្គនាយកដ្ឋានរតនាគារជាតិ ទទួលបន្ទុកដឹកនាំសម្របសម្រួលក្រុមការងារ និង និតិវិធីអនុវត្តការងារ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធទទួលបន្ទុកសិក្សា និង រៀបចំនីតិវិធីអនុវត្តការងារ និង នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលបន្ទុកកិច្ចការបច្ចេកទេសនៃបច្ចេកវិទ្យាព័ត៌មានរបស់ប្រព័ន្ធ ។




**រូបភាពទី ២.៨**: ទិដ្ឋភាពទូទៅនៃប្រព័ន្ធ NRMIS

### ២.២.៥.ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា

ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលរៀបចំ និង អភិវឌ្ឍឡើងដោយ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ, ដែលមានមុខងារជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការតភ្ជាប់ និង ផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងគ្នា ដែលមានតម្រូវការក្នុងការផ្លាស់ប្តូរទិន្នន័យរវាងគ្នាទៅវិញទៅមក ។ ប្រព័ន្ធនេះ មិនមានការរក្សាទុកទិន្នន័យរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានណាមួយនោះទេ គ្រាន់តែជាឧបករណ៍តភ្ជាប់រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានាក្នុងការផ្លាស់ប្តូរទិន្នន័យរវាងគ្នាតែប៉ុណ្ណោះ ដោយធានាបាននូវសុចរិតភាព, ឯកជនភាពនៃទិន្នន័យ និង មានលក្ខណៈវិមជ្ឈការ ។




**រូបភាពទី ២.៩**: ទិដ្ឋភាពទូទៅនៃថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)

### ២.២.៦.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗ

#### ២.២.៦.១.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបំណុលសាធារណៈ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបំណុលសាធារណៈ ប្រើប្រាស់ផលិតផលក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិស្រាប់ហៅថា DMFAS ដែលមានមុខងារសម្រាប់គ្រប់គ្រងបំណុលសាធារណៈ, គ្រប់គ្រងជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍, និង តាមដានការទូទាត់សងការប្រាក់ និង ប្រាក់ដើម ជាដើម ។ ប្រព័ន្ធនេះកំពុងដំណើរការប្រើប្រាស់នៅក្នុងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង គ្រប់គ្រងបំណុល (GDICDM) តែមួយប៉ុណ្ណោះចាប់តាំងពីឆ្នាំ ២០០៧ មកម្ល៉េះ ។ GDICDM គ្រោងនឹងធ្វើទំនើបកម្មបន្ថែមលើប្រព័ន្ធនេះដោយប្រើប្រាស់កម្មវិធីជំនាន់ថ្មីចុងក្រោយក្នុងពេលដ៏ខ្លីខាងមុខផងដែរ ។

#### ២.២.៦.២.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ត្រូវបានរៀបចំឡើងដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, សម្រាប់គ្រប់គ្រងការចុះបញ្ជី

ទ្រព្យសម្បត្តិរដ្ឋតែប៉ុណ្ណោះនៅដំណាក់កាលដំបូង និង បានដាក់ឱ្យដំណើរការសាកល្បងកាលពីដើមឆ្នាំ ២០២១ នៅក្រសួង-ស្ថាប័ន, រដ្ឋបាលរាជធានី-ខេត្ត និង នីតិបុគ្គលសាធារណៈ លើកលែងតែរដ្ឋបាលក្រុង-ស្រុក និង ឃុំ-សង្កាត់តែប៉ុណ្ណោះ ។ ប្រព័ន្ធនេះ រៀបចំកសាងឡើងដោយក្រុមហ៊ុនឯកជនក្នុងស្រុក និង ត្រូវបានដាក់ឱ្យដំណើរការជំហានដំបូងជាលក្ខណៈដាច់ៗដោយឡែកពីគ្នា មិនទាន់ធ្វើសមាហរណកម្មដោយស្វ័យប្រវត្តិនៅឡើយ ។ អង្គភាពដែលប្រើប្រាស់ប្រព័ន្ធនេះត្រូវបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធដែលដំឡើងនៅក្នុងម៉ាស៊ីនកុំព្យូទ័ររៀងៗខ្លួន រួចទាញទិន្នន័យចេញពីប្រព័ន្ធមកវិញ (Export File) ដោយភ្ជាប់ជាមួយនឹងទម្រង់របាយការណ៍ដែលបោះពុម្ពចេញពីប្រព័ន្ធ រួចធ្វើជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ ដើម្បីធ្វើការពិនិត្យ និង បូកសរុបនៅថ្នាក់កណ្តាល ។

### ២.២.៦.៣.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងការងារសវនកម្ម

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងការងារសវនកម្ម (SAAT - System of Administration Audit Task) មានមុខងារគាំទ្រដល់ដំណើរការប្រតិបត្តិការមុខងារសវនកម្មផ្ទៃក្នុង ក្នុងការរក្សាទុកឯកសារ, សន្លឹកកិច្ចការតាមស្តង់ដារសវនកម្ម, លិខិតបទដ្ឋានគតិយុត្ត និង ការរៀបចំរបាយការណ៍សម្រាប់សវនកម្ម ។ ប្រព័ន្ធនេះប្រើប្រាស់តែសម្រាប់ការងារផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងតែប៉ុណ្ណោះ និង ជាប្រព័ន្ធដែលបង្កើតឡើងដោយប្រើប្រាស់ធនធានមនុស្សផ្ទាល់របស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

### ២.២.៦.៤.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបុគ្គលិក និង កិច្ចការរដ្ឋបាល

ក្រៅពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គាំទ្រដល់មុខងារស្នូលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដូចមានរៀបរាប់ខាងលើ អង្គភាពក្រោមឱវាទ កសហវ នីមួយៗបានរៀបចំ និង កសាងនូវប្រព័ន្ធគ្រប់គ្រងកិច្ចការងារផ្ទៃក្នុងមួយចំនួនផ្សេងទៀតរៀងខ្លួនដើម្បីគាំទ្រដល់ការគ្រប់គ្រងបុគ្គលិក និង កិច្ចការរដ្ឋបាល ដូចជា៖

- ✓ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបុគ្គលិក និង វត្តមាន
- ✓ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងឯកសារ
- ✓ ប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិករក្សាទុកឯកសារបណ្ណសារ និង ឯកសារគតិយុត្ត
- ✓ កម្មវិធីបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងកាលវិភាគប្រជុំ
- ✓ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌ ។ល។

### ២.២.៦.៥.ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងជំនួយគាំទ្រ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងជំនួយគាំទ្រ (Helpdesk System) ត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់ការដោះស្រាយបញ្ហានានាជុំវិញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬ ការផ្តល់សេវាផ្សេងៗ ដូចជា បញ្ហាលើការប្រើប្រាស់ប្រព័ន្ធ FMIS, បញ្ហាលើការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ ជាដើម តាមរយៈការបង្កើតប្រអប់សំបុត្របញ្ហា, សំណើសុំផ្លាស់ប្តូរអ្នកប្រើប្រាស់ ឬ លើកជាសំណួរផ្សេងៗ ដើម្បីស្នើទៅក្រុមការងារគ្រប់គ្រងប្រព័ន្ធនីមួយៗធ្វើការពិនិត្យ, ដោះស្រាយ និង ឆ្លើយតប ។

## ២.៣.បណ្ដាញទំនាក់ទំនង និង ប្រព័ន្ធផ្សព្វផ្សាយ

### ២.៣.១.គេហទំព័រ

កសហវ មាននូវគេហទំព័រផ្លូវការរួចជាស្រេច ប៉ុន្តែស្ថិតនៅលើម៉ាស៊ីនមេដែលត្រូវបានជួលផ្ដាច់នៅក្រុមហ៊ុនឯកជន ។ ជាមួយគ្នានេះ គេហទំព័ររបស់អង្គភាពក្រោមឱវាទ កសហវ មួយចំនួនធំស្ថិតនៅជ្រកក្រោមស្លាកគេហទំព័ររបស់ កសហវ លើកលែងតែអគ្គនាយកដ្ឋានធំៗចំនួន ៣ ដែលមានគេហទំព័រផ្ទាល់ខ្លួន មិនស្ថិតក្រោមស្លាករបស់ កសហវ គឺ អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានរតនាគារជាតិ ។

គេហទំព័ររបស់ កសហវ រួមទាំងគេហទំព័ររបស់អង្គភាពក្រោមឱវាទ កសហវ ប្រើប្រាស់សម្រាប់ជាមធ្យោបាយក្នុងការផ្សព្វផ្សាយព័ត៌មានជូនសាធារណជន ជាពិសេសព័ត៌មានពាក់ព័ន្ធនឹងសេវាសាធារណៈ, សេចក្ដីជូនដំណឹង, សេចក្ដីប្រកាសព័ត៌មាន, ឯកសារច្បាប់ និង គតិយុត្ត ជាដើម ដែលជាប្រយោជន៍សម្រាប់សាធារណជន និង ស្ថាប័នជាតិ និង អន្តរជាតិពាក់ព័ន្ធ ។

គេហទំព័ររបស់អង្គភាពក្រោមឱវាទ កសហវ នីមួយៗ រៀបចំទៅតាមមុខងារ និង ភារកិច្ចរៀងៗខ្លួន ដោយមិនទាន់មានជាគោលការណ៍ ឬ ស្តង់ដារនៃការរៀបចំគេហទំព័រនៅឡើយ ។

### ២.៣.២.អ៊ីមែល

ដូចគ្នានឹងគេហទំព័ររបស់ កសហវ ផងដែរ អ៊ីមែលរបស់ កសហវ មានរួចជាស្រេច និង ស្ថិតនៅលើម៉ាស៊ីនមេរួមជាមួយនឹងម៉ាស៊ីនមេរបស់គេហទំព័រ កសហវ ដែលបានជួលជាមួយនឹងក្រុមហ៊ុនឯកជន ។ បច្ចុប្បន្ន ការប្រើប្រាស់អ៊ីមែលរបស់ កសហវ មិនទាន់ទូលំទូលាយនៅឡើយ ដោយភាគច្រើនប្រើប្រាស់សម្រាប់តែជាមធ្យោបាយទំនាក់ទំនងផ្លូវការផ្ទៃក្នុង និង ជាមួយស្ថាប័នខាងក្រៅបន្តិចបន្តួចតែប៉ុណ្ណោះ ព្រោះការទំនាក់ទំនងគ្នាភាគច្រើន ត្រូវបានប្រើប្រាស់កម្មវិធីទំនាក់ទំនងតេលេក្រាម ស្ទើរតែទាំងស្រុង ។

### ២.៣.៣.បណ្ដាញទំនាក់ទំនងសង្គម

កសហវ និង អង្គភាពក្រោមឱវាទស្ទើរតែទាំងអស់បានបង្កើតនូវទំព័រផ្សព្វផ្សាយព័ត៌មាន តាមរយៈបណ្ដាញសង្គមហ្វេសប៊ុក (Facebook) និង មួយចំនួនក៏មានបណ្ដាញយូធូប (Youtube) ផងដែរ សម្រាប់ផ្សព្វផ្សាយនូវព័ត៌មានជាលក្ខណៈវីដេអូ ។ ដោយឡែកបណ្ដាញសង្គមអ៊ីនស្តាក្រាម (Instagram) មានតែអគ្គនាយកដ្ឋានពន្ធដារតែប៉ុណ្ណោះដែលបានបង្កើតឡើងក្នុងគោលបំណង ផ្សព្វផ្សាយនូវព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងព័ត៌មានផ្នែកពន្ធដារ និង ការផ្ដល់សេវាផ្នែកពន្ធដារ ។ ជាមួយគ្នានេះ បណ្ដាញទំនាក់-ទំនងសង្គមតេលេក្រាម (Telegram) ក៏ត្រូវបានប្រើប្រាស់ស្ទើរតែទាំងស្រុងទាំងមធ្យោបាយសម្រាប់ការទំនាក់ទំនងគ្នា និង ការផ្សព្វផ្សាយព័ត៌មាន ។

### ២.៣.៤.ប្រព័ន្ធសន្និសីទវីដេអូ

ក្នុងឆ្នាំ ២០២០ កន្លងទៅនេះមានការផ្ទុះឡើងនូវការរាតត្បាតជំងឺលោកផ្លូវដង្ហើមធ្ងន់ធ្ងរថ្មីហៅថាកូវីដ-១៩ ដែលតម្រូវឱ្យមន្ត្រីរាជការ, បុគ្គលិកក្រុមហ៊ុនឯកជន និង ប្រជាជនគ្រប់លំដាប់ថ្នាក់បំពេញ

ការងារ និង ប្រកបរបរអាជីវកម្មនានា ដោយប្រកាន់ខ្ជាប់នូវគោលការណ៍រក្សាគម្លាតសង្គមដើម្បីបង្ការនូវការឆ្លង ។ គោរពតាមគោលការណ៍នេះ កិច្ចប្រជុំពីចម្ងាយត្រូវបានចាប់ផ្តើមគិតគូររៀបចំជាអាទិភាព ដោយត្រូវប្រើប្រាស់នូវឧបករណ៍ និង ប្រព័ន្ធឌីជីថលនានាដើម្បីជាដំណោះស្រាយ ។

កសហវ ក៏បានប្រើប្រាស់នូវកម្មវិធីបច្ចេកវិទ្យាព័ត៌មានមួយចំនួនសម្រាប់គាំទ្រដល់ការរៀបចំកិច្ចប្រជុំ និង ចូលរួមកិច្ចប្រជុំពីចម្ងាយ រួមមាន កម្មវិធី Zoom, Microsoft Team, Cisco Webex និង Google Meet ។ ជាមួយគ្នានេះដែរ កសហវ ក៏បានរៀបចំ និង បំពាក់នូវប្រព័ន្ធសន្និសីទវីដេអូខ្នាតធំផងដែរ ដោយប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មានជាមូលដ្ឋាន បំពាក់នៅតាមបន្ទប់ប្រជុំអាទិភាពមួយចំនួន ដើម្បីរៀបចំកិច្ចប្រជុំធំៗ សរុបជាង ៤០ ការដ្ឋាន ក្នុងនោះរួមមាន បន្ទប់ប្រជុំនៅក្នុងទីស្តីការ កសហវ, បន្ទប់ប្រជុំនៃអគ្គនាយកដ្ឋានក្រោមឱវាទ កសហវ ដែលមានទីតាំងនៅខាងក្រៅទីស្តីការ កសហវ និង បន្ទប់ប្រជុំនៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាទីតាំង។




**រូបភាពទី ២.១០**: កម្មវិធីបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់កិច្ចប្រជុំពីចម្ងាយ



**រូបភាពទី ២.១១**: ប្រព័ន្ធសន្និសីទវីដេអូរបស់ កសហវ

## ២.៤.អង្គភាព និង ធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មាន

អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ កសហវ មួយចំនួនបានបង្កើតអង្គភាពទទួលបន្ទុកផ្នែកបច្ចេកវិទ្យាព័ត៌មានក្នុងកម្រិតជានាយកដ្ឋាន ដូចជា អគ្គលេខាធិការដ្ឋាន កសហវ, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ។ ដោយឡែក អគ្គនាយកដ្ឋាន និង អង្គភាពមួយចំនួនផ្សេងទៀតក៏អាចមានអង្គភាពទទួលបន្ទុកកិច្ចការងារបច្ចេកវិទ្យាព័ត៌មានផងដែរ ប៉ុន្តែក្នុងកម្រិតតូចជាងនាយកដ្ឋាន ។




**រូបភាពទី ២.១២**: រចនាសម្ព័ន្ធអង្គភាពទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាននៃ កសហវ

យោងតាមលទ្ធផលនៃការធ្វើសម្រង់ព័ត៌មានក្នុងឆ្នាំ ២០២១ ធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន សរុបប្រមាណ ២៥៩ នាក់ (ដោយមិនរាប់បញ្ចូលមន្ត្រីនៃអង្គភាពផ្សេងទៀតដែលស្ថិតក្នុងកម្រិតតូចជានាយកដ្ឋាន) និង មន្ត្រីសរុបរបស់អង្គភាពទទួលបន្ទុកការងារបច្ចេក-វិទ្យាព័ត៌មាន សរុបប្រមាណ ៤៨៧ នាក់ (២៥៩/៤៨៧) ដែលស្ថិតក្នុងនាយកដ្ឋាន ឬ អង្គភាពបច្ចេកវិទ្យាព័ត៌មាន ។ នេះបញ្ជាក់ថា មន្ត្រីបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន និង មន្ត្រីនៃអង្គភាពទទួលបន្ទុកការងារបច្ចេកវិទ្យាព័ត៌មាន មានចំនួនច្រើនដែលអាចរួមគ្នាធ្វើកិច្ចការងារបានយ៉ាងច្រើនពាក់ព័ន្ធនឹងការងារបច្ចេក-វិទ្យាព័ត៌មាន និង ឌីជីថល បម្រើដល់ប្រយោជន៍ស្ថាប័ន និង សង្គមជាតិ ។

## ២.៥.បញ្ហាប្រឈមនៃបច្ចេកវិទ្យាព័ត៌មាននៅក្នុង កសហវ

### ២.៥.១.បញ្ហាប្រឈមពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**១.មជ្ឈមណ្ឌលទិន្នន័យច្រើន**: កសហវ បានរៀបចំ កសាង និង កំពុងដំណើរការនូវមជ្ឈមណ្ឌលទិន្នន័យគោលចំនួន ៤ នៅទីតាំងផ្សេងគ្នា រួមជាមួយនឹង មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យចំនួន ២ បន្ថែមទៀត សម្រាប់គាំទ្រដល់ដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗគ្នារបស់ កសហវ ។ ករណីនេះ បានបង្កើតឱ្យមាននូវបញ្ហាប្រឈមមួយចំនួនដូចតទៅ៖

- បង្កើនបន្ទុកចំណាយវិនិយោគច្រើនទាំងពេលសាងសង់ដំបូង និង ពេលផ្លាស់ប្តូរ ឬ បំពាក់បន្ថែមឧបករណ៍ថ្មី
- បង្កើនបន្ទុកចំណាយចរន្តលើការប្រើប្រាស់សេវាថែទាំគាំទ្រប្រចាំឆ្នាំ
- បង្កើនបន្ទុកចំណាយលើបុគ្គលិក ដែលស្ថិតក្នុងក្របខណ្ឌការងារបច្ចេកទេសដូចគ្នា រួមមាន ផ្នែកគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ, ផ្នែកអគ្គិសនី, ផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន, ផ្នែកម៉ាស៊ីនមេ, ផ្នែកបណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មាន ជាដើម
- បង្កើនបន្ទុកចំណាយចរន្តលើការប្រើប្រាស់ថាមពលអគ្គិសនីច្រើនកន្លែង
- ខាតបង់ទីធ្លា ឬ បន្ទប់នៃអគារច្រើនកន្លែង
- បង្កើនកម្តៅផែនដី និង ប៉ះពាល់ដល់បរិស្ថាន ។

ម្យ៉ាងទៀត កសហវ ក៏មិនទាន់មានក្របខណ្ឌរួមនៃការគ្រប់គ្រងធនធានបច្ចេកវិទ្យាព័ត៌មាននៅឡើយ ដូចជា ធនធានម៉ាស៊ីនមេ, ធនធាននៃការរក្សាទុកទិន្នន័យ ជាដើម ដែលធនធានទាំងនេះអាចនឹងមាននៅសេសសល់នៅតាមមជ្ឈមណ្ឌលទិន្នន័យនីមួយៗ ដែលអាចចែករំលែកដល់អង្គភាពផ្សេងៗទៀតក្រោមឱវាទ កសហវ ក្នុងការស្នើសុំប្រើប្រាស់តាមតម្រូវការចាំបាច់សម្រាប់ការធ្វើទំនើបកម្មកិច្ចការងាររបស់ខ្លួន ដែលនឹងអាចកាត់បន្ថយបានខ្លះនូវភាពខ្វះខាតក្នុងការវិនិយោគ ផងដែរ ។

ជាដំណោះស្រាយសម្រាប់រយៈពេលខ្លី គឺត្រូវធ្វើការស្រង់នូវធនធាននៃមជ្ឈមណ្ឌលទិន្នន័យរបស់ កសហវ ដែលមានស្រាប់ បូកសរុបជាក្របខណ្ឌរួមរបស់ កសហវ ដើម្បីមានមូលដ្ឋានក្នុងការគិតគូរបន្តទៀតក្នុងការត្រៀមផ្គត់ផ្គង់ធនធាននេះដល់អង្គភាពផ្សេងៗដែលមិនមានមជ្ឈមណ្ឌលទិន្នន័យផ្ទាល់ខ្លួន ។ សម្រាប់រយៈពេលវែង គួរគិតគូររៀបចំឡើងវិញនូវមជ្ឈមណ្ឌលទិន្នន័យរួមក្នុងក្របខណ្ឌ កសហវ តែម្តងរួមទាំង មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ, ដោយសារតែការរៀបចំនេះមានចរិតលក្ខណៈ និង មានកម្មវត្ថុជាក្របខណ្ឌរួម ។

**២.ការបំពាក់ឧបករណ៍ស្ទួនជូនអ្នកប្រើប្រាស់តែមួយ:** ដោយសារហេតុផលនៃការពង្រឹងសន្តិសុខទិន្នន័យ និង សន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ បានធ្វើឱ្យមន្រ្តី ឬ បុគ្គលិកនៃអង្គភាពមួយចំនួនត្រូវបានបំពាក់ម៉ាស៊ីនកុំព្យូទ័រលើសពី ១ គ្រឿង នៅលើតុធ្វើការងាររបស់ខ្លួន រួមទាំងការតភ្ជាប់បណ្តាញបច្ចេកវិទ្យាព័ត៌មានលើសពី ១ ខ្សែផងដែរ ។ ឧទាហរណ៍: ម៉ាស៊ីនកុំព្យូទ័រ និង បណ្តាញតភ្ជាប់ ១ ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាពខ្លួន, ម៉ាស៊ីនកុំព្យូទ័រ និង បណ្តាញតភ្ជាប់ ១ ទៀតប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាពផ្សេង និង អាចមានម៉ាស៊ីនកុំព្យូទ័រ និង បណ្តាញតភ្ជាប់ ១ ទៀតប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ១ ផ្សេងទៀត ។ ករណីដូចនេះ គឺបង្កឱ្យមានការខាតបង់ និង ខ្វះខាតធនធានថវិកាយ៉ាងធ្ងន់ធ្ងរសម្រាប់ កសហវ ក្នុងការចំណាយទៅលើការទិញម៉ាស៊ីនកុំព្យូទ័រ និង ការភ្ជាប់បណ្តាញបច្ចេកវិទ្យាព័ត៌មាន ។

ជាដំណោះស្រាយបឋម ត្រូវលើកយកករណីសិក្សាជាក់ស្តែងមកធ្វើការវិភាគ និង កំណត់នូវវិធានសម្រាប់ការតម្រង់ទិសឈានទៅរកការប្រើប្រាស់ឧបករណ៍ និង បណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានរួមតែ

មួយសម្រាប់ប្រព័ន្ធផ្សេងៗគ្នារបស់ កសហវ ដោយផ្តោតជាសំខាន់ទៅលើកត្តាសន្តិសុខបច្ចេកវិទ្យាព័ត៌មាន និង ការប្រើប្រាស់បណ្តាញអ៊ីនត្រាណិតរួម កសហវ ។

**៣.ខ្វះគោលការណ៍ពង្រឹងការប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រ**: បច្ចុប្បន្ន ម៉ាស៊ីនកុំព្យូទ័រមួយចំនួនធំត្រូវបានទិញយកមកបម្រើកិច្ចការងាររដ្ឋបាលប្រចាំថ្ងៃរបស់អង្គភាពនីមួយៗ ដោយក្នុងនោះស្ទើរតែទាំងអស់មិនមានប្រើប្រាស់កម្មវិធីដែលមានអាជ្ញាបណ្ណត្រឹមត្រូវនោះទេ និង មិនសូវបានគិតគូរអំពីសន្តិសុខទិន្នន័យនោះឡើយ ដែលបង្កជាបញ្ហាប្រឈមមួយចំនួន ដូចជា ម៉ាស៊ីនកុំព្យូទ័រដំណើរការមិនប្រក្រតីក្នុងពេលបម្រើការងារ, កម្មវិធីកុំព្យូទ័រដំណើរការរអាក់រអួល, ទិន្នន័យអាចត្រូវមានអ្នកលួចតាមរយៈកម្មវិធីចារកម្មបច្ចេក-វិទ្យាព័ត៌មាន ជាដើម ។ ម្យ៉ាងទៀត ម៉ាស៊ីនកុំព្យូទ័រមួយភាគធំរបស់ កសហវ គឺមិនស្ថិតក្នុងក្របខណ្ឌនៃការគ្រប់គ្រងរួមនោះទេ គឺនៅមានភាពរប៉ាត់រប៉ាយ ដែលនាំឱ្យមានការលំបាកក្នុងការគ្រប់គ្រងបណ្តាញតភ្ជាប់ផងដែរ ខុសពីម៉ាស៊ីនកុំព្យូទ័រក្នុងក្របខណ្ឌនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួន ដែលមានការគ្រប់គ្រងរួម ងាយស្រួលក្នុងការកំណត់ជាគោលការណ៍ផ្សេងៗដើម្បីពង្រឹងការប្រើប្រាស់ ។

ជាដំណោះស្រាយ ត្រូវគិតគូររៀបចំ និង អនុវត្តផែនការតម្រង់ទិសលើការប្រើប្រាស់កម្មវិធីដែលមានអាជ្ញាបណ្ណត្រឹមត្រូវ និង រៀបចំនូវគោលការណ៍នៃការប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រដែលផ្តល់ដោយស្ថាប័ន ឬ ម៉ាស៊ីនកុំព្យូទ័រផ្ទាល់ខ្លួនរបស់មន្ត្រី ព្រមទាំងសម្រង់នូវបញ្ជីសារពើភណ្ឌពាក់ព័ន្ធនឹងម៉ាស៊ីនកុំព្យូទ័រដែលជាទ្រព្យសម្បត្តិរបស់ កសហវ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការពង្រឹងការប្រើប្រាស់ឧបករណ៍របស់អ្នកប្រើប្រាស់បន្តទៀត ។

### ២.៥.២.បញ្ហាប្រឈមពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានរៀបចំ និង កសាងឡើងជាច្រើនទៅតាមតម្រូវការរបស់អង្គភាពនីមួយៗ រួមទាំង ក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ប្រព័ន្ធ IT ធំៗមួយចំនួនត្រូវបានប្រើប្រាស់ផលិតផលដែលមានស្រាប់របស់ក្រុមហ៊ុនធំៗនៅក្នុងទីផ្សារអន្តរជាតិ និង ប្រព័ន្ធ IT មួយចំនួនទៀតត្រូវបានរៀបចំ និង អភិវឌ្ឍដោយប្រើប្រាស់ធនធានមនុស្សរបស់អង្គភាពផ្ទាល់ ។ ប្រភេទនៃប្រព័ន្ធ IT នេះសុទ្ធតែមានបញ្ហាប្រឈមរៀងៗខ្លួនគឺ៖

**បញ្ហាប្រឈមពាក់ព័ន្ធនឹងប្រព័ន្ធ IT ដែលប្រើប្រាស់ផលិតផលស្រាប់**

- ភាពស្មុគស្មាញក្នុងការធ្វើទំនើបកម្មលើកម្មវិធី IT ទៅកាន់ជំនាន់ថ្មី ដែលត្រូវមានការរៀបចំ និង ធ្វើឡើងដោយហ្មត់ចត់បំផុត
- ភាពខ្វះចន្លោះលើព័ត៌មានពាក់ព័ន្ធនឹងប្រភេទអាជ្ញាបណ្ណនៃកម្មវិធី IT នីមួយៗ
- កំណើននៃការបង់ថ្លៃអាជ្ញាបណ្ណថែទាំ និង គាំទ្រជាប្រចាំឆ្នាំ
- ភាពទន់ភ្លន់ក្នុងការកែប្រែប្រព័ន្ធឱ្យស្របតាមការផ្លាស់ប្តូរបទដ្ឋានគតិយុត្ត នៅមានកំណត់
- ប្រើប្រាស់មុខងារមិនទាន់អស់សមត្ថភាពដែលប្រព័ន្ធមាន ។

ជាដំណោះស្រាយ គឺត្រូវសិក្សាស្វែងយល់លម្អិតឱ្យបានច្បាស់លាស់អំពីផលិតផលដែលបានទិញមកស្រាប់ ទាំងផ្នែកមុខងារ, ផ្នែកបច្ចេកទេស, ផ្នែករចនាសម្ព័ន្ធទិន្នន័យ ជាដើម ដើម្បីចៀសវាងនូវការកេងបន្លំនានាពីម្ចាស់កម្មវិធី IT និង ចៀសវាងហានិភ័យនានាដែលអាចកើតមានឡើងដោយថាហេតុ ។

**បញ្ហាប្រឈមពាក់ព័ន្ធនឹងប្រព័ន្ធ IT ដែលផលិតដោយខ្លួនឯង**

- ខ្វះឯកសារគោលស្តីអំពីប្លង់និម្មាបនកម្មនៃការអភិវឌ្ឍប្រព័ន្ធ IT ដែលត្រូវរក្សាទុក និង តម្កល់ជាទ្រព្យឯកសាររបស់ កសហវ សម្រាប់ជាគោលក្នុងការបន្តអភិវឌ្ឍនៅគ្រប់ជំនាន់
- ខ្វះយន្តការក្នុងការគ្រប់គ្រងកូដដើម (Source Code) នៃកម្មវិធីបច្ចេកវិទ្យាព័ត៌មាននីមួយៗដែលបានផលិតឡើងដោយធនធានមនុស្សរបស់អង្គភាព នាំឱ្យ "បុគ្គលិកលាឈប់ពីការងារ, ការអភិវឌ្ឍកម្មវិធី IT មានការលំបាកក្នុងការបន្តការអភិវឌ្ឍ"
- ខ្វះការគិតគូរជាក្របខណ្ឌរួម និង រៀបចំឡើងនូវប្រព័ន្ធតូចៗដាច់ដោយឡែកៗពីគ្នា និង អាចមានស្ទួនគ្នាពីអង្គភាពមួយទៅអង្គភាពមួយ
- ខ្វះយន្តការ និង ឧបករណ៍សម្រាប់ជាជំនួយក្នុងការគ្រប់គ្រងការអភិវឌ្ឍកម្មវិធី IT

ជាដំណោះស្រាយ គឺត្រូវរៀបចំនូវវិធាន និង យន្តការក្នុងការគ្រប់គ្រងកូដដើម នៃកម្មវិធីបច្ចេកវិទ្យាព័ត៌មាននានារបស់ កសហវ, រៀបចំនូវគោលការណ៍ និង វិធានពាក់ព័ន្ធនឹងការគ្រប់គ្រងលើការរៀបចំ និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយខ្លួនឯង ជាដើម ។

**បញ្ហាប្រឈមជារួមពាក់ព័ន្ធនឹងប្រព័ន្ធ IT**

- ខ្វះក្របខណ្ឌរួមក្នុងការគ្រប់គ្រងប្រព័ន្ធ IT របស់ កសហវ បានធ្វើឱ្យការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រើប្រាស់នូវបច្ចេកវិទ្យា និង វិធីសាស្ត្រផ្សេងៗគ្នា នាំឱ្យមានតម្រូវការការធនធានមនុស្សមានជំនាញខុសៗគ្នា និង ប្រើប្រាស់អាជ្ញាបណ្ណកម្មវិធីផ្សេងៗគ្នា ដែលជាកត្តានាំឱ្យមានការចំណាយខ្ពស់ផងដែរ
- ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងផ្ទៃក្នុង នៅតាមអគ្គនាយកដ្ឋានមួយចំនួន គឺប្រហាក់ប្រហែលគ្នា ដូចជា ប្រព័ន្ធគ្រប់គ្រងបុគ្គលិក, ប្រព័ន្ធគ្រប់គ្រងឯកសារ, ប្រព័ន្ធគ្រប់គ្រងកាលវិភាគការងារ ជាដើម ដែលត្រូវបានបង្កើតឡើងជាច្រើនកន្លែងក្នុងខណៈដែលប្រព័ន្ធទាំងនេះអាចរៀបចំ អភិវឌ្ឍ និង ប្រើប្រាស់ជារួមបាន ដើម្បីមានផលចំណេញទាំងធនធាន និង ពេលវេលា ។

ជាដំណោះស្រាយ គឺត្រូវរៀបចំនូវក្របខណ្ឌរួមសម្រាប់ការគ្រប់គ្រងដល់ការរៀបចំ និង អភិវឌ្ឍប្រព័ន្ធ IT របស់ កសហវ រួម ជាមួយនឹងការពិនិត្យឡើងវិញនូវការប្រើប្រាស់ប្រព័ន្ធ IT ដើម្បីបម្រើកិច្ចការងារទំនាក់ទំនង និង រដ្ឋបាល ។

### ២.៥.៣.បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មាន

ផ្អែកតាមរចនាសម្ព័ន្ធអង្គភាពដែលមានធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មាន ដូចមានក្នុងរូបភាពទី ២.១២ ខាងលើ, កសហវ មានធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មានជាច្រើនរូប ស្ថិតក្នុងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ឬ អង្គភាពទទួលបន្ទុកការងារបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋាននីមួយៗ ដើម្បីធ្វើទំនើបកម្មកិច្ចការងាររបស់អគ្គនាយកដ្ឋាន និង អង្គភាពឱ្យបានឆាប់រហ័ស និង ដោះស្រាយបញ្ហាបានលឿន ។ កត្តាដែលមានធនធានមនុស្សច្រើនសម្រាប់ការងារបច្ចេកវិទ្យាព័ត៌មាននេះ អាចចាត់ទុកថាជាកត្តាល្អសម្រាប់ការពន្លឿនការធ្វើទំនើបកម្មនានារបស់ កសហវ ប៉ុន្តែក៏ជួបប្រទះបញ្ហាមួយចំនួនដូចតទៅៈ

- អតុល្យភាពនៃការឧបត្ថម្ភលើកទឹកចិត្ត ដល់ធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈ IT ក្នុងកម្រិតប្រហាក់ប្រហែលគ្នា
- ខ្វះមន្ត្រីជំនាញជាន់ខ្ពស់ផ្នែកវិស្វកម្មបច្ចេកវិទ្យាព័ត៌មាន (Software Engineer) ឬ អ្នកវិភាគលើប្រព័ន្ធ (System Analyst)
- ការទាក់ទាញរបស់វិស័យឯកជនទៅលើមន្ត្រីជំនាញជាន់ខ្ពស់ តាមរយៈការផ្តល់នូវបៀវត្សខ្ពស់
- ខ្វះក្របខណ្ឌរួមក្នុងការគ្រប់គ្រងធនធានមនុស្សផ្នែក IT ដើម្បីពិនិត្យលទ្ធភាពចែករំលែកនូវកម្លាំងនៃធនធានដែលមានជំនាញ និង លក្ខខណ្ឌការងារដូចគ្នា
- ចំណាយច្រើនទៅលើការបណ្តុះបណ្តាលមួយចំនួនដែលអាចបណ្តុះបណ្តាលជារួមបាន ។

ជាដំណោះស្រាយ ត្រូវរៀបចំនូវផែនការធនធានមនុស្សជំនាញជាន់ខ្ពស់ផ្នែក IT និង កំណត់នូវតម្រូវការនៃការបណ្តុះបណ្តាលជូនមន្ត្រីបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន ដើម្បីពិនិត្យលទ្ធភាពក្នុងរៀបចំការបណ្តុះបណ្តាល ជារួមបាន ។

### ២.៥.៤.បញ្ហាប្រឈមផ្នែកគោលការណ៍ណែនាំ ស្តង់ដារ និង សន្តិសុខបច្ចេកវិទ្យាព័ត៌មាន

កសហវ មិនទាន់មានជាគោលការណ៍ណែនាំរួមលើការប្រើប្រាស់ឧបករណ៍ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានានូវសុវត្ថិភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង សន្តិសុខព័ត៌មាន របស់ កសហវ នៅឡើយ ។ គោលការណ៍, ស្តង់ដារ និង ប្រព័ន្ធសន្តិសុខសម្រាប់បច្ចេកវិទ្យាព័ត៌មានក្នុង កសហវ ត្រូវតែធ្វើការរៀបចំ និង ដាក់ឱ្យអនុវត្តជារួម ក្នុងខណៈពេលដែលមានការកើនឡើងកាន់ច្រើនលើការប្រើប្រាស់ប្រព័ន្ធ IT និង ប្រព័ន្ធឌីជីថល គាំទ្រដល់ការគ្រប់គ្រង និង ដំណើរការការងារប្រចាំថ្ងៃ ដែលបានបង្កើននូវប្រកហានិភ័យថ្មីបន្ថែមពាក់ព័ន្ធនឹងនិរន្តរភាពនៃប្រតិបត្តិការការងារប្រចាំថ្ងៃ និង សន្តិសុខព័ត៌មាន ។

### ២.៥.៥.បញ្ហាប្រឈមលើការប្រើប្រាស់កម្មវិធីសម្រាប់ទំនាក់ទំនងក្នុងការងារ និង កិច្ចប្រជុំ

បច្ចុប្បន្ន មន្ត្រី និង បុគ្គលិក កសហវ មិនទាន់ប្រើប្រាស់ទូលំទូលាយនៅឡើយនូវអ៊ីមែលរបស់ កសហវ ក្នុងការទំនាក់ទំនងការងារជាផ្លូវការ, នេះអាចបណ្តាលមកពីកត្តាប្រឈមមួយចំនួនដូចជា ១-ការទម្លាប់ប្រើប្រាស់កម្មវិធីមិនគិតថ្លៃមួយចំនួន ដូចជា Telegram, Signal, WhatsApp, Viber ជាដើម ដែលមានសមត្ថភាពខ្ពស់ស្រាប់ក្នុងការជជែកពិភាក្សាផ្ទាល់ ឬ ជាក្រុម, ផ្ញើឯកសារឌីជីថល, សំឡេង, វីដេអូ ទៅវិញ

ទៅមក យ៉ាងងាយស្រួល, ២-សមត្ថភាពនៃប្រព័ន្ធអ៊ីមែល កសហវ នៅមានកម្រិត, ៣-មិនទាន់មានកម្មវិធីផ្ទៃក្នុង កសហវ សម្រាប់ការដេដែកពិភាក្សាការងារ ឬ ចែករំលែកឯកសារឌីជីថល នៅឡើយ ។

## ២.៦.ការវិភាគភាពខ្លាំង, ភាពខ្សោយ, កាលានុវត្តភាព និង ការគំរាមកំហែង

យោងលើស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ IT នៅក្នុង កសហវ ដូចមានរៀបរាប់ខាងលើ រួមទាំងការគាំទ្រ, ការផ្តល់អាទិភាព និង ការផ្តល់ការយកចិត្តទុកដាក់លើការងារ IT និង ការធ្វើទំនើបកម្មការងារផ្សេងៗ ជាពិសេសការផ្តល់សេវាសាធារណៈរបស់ថ្នាក់ដឹកនាំនៃ កសហវ, គឺបានផ្តល់នូវមូលដ្ឋានក្នុងការវិភាគចេញជាភាពខ្លាំង, ភាពខ្សោយ, កាលានុវត្តភាព និង ការគំរាមកំហែង ដូចខាងក្រោម៖

| ភាពខ្លាំង | ភាពខ្សោយ |
|---|---|
| ↗ មានធនធាន IT ជាច្រើន ដូចជា ម៉ាស៊ីនមេ, ឧបករណ៍ទុកទិន្នន័យ, មជ្ឈមណ្ឌលទិន្នន័យ ជាដើម គាំទ្រដល់ការធ្វើទំនើបកម្ម និង បរិវត្តកម្មឌីជីថល<br>↗ មានបណ្តាញតភ្ជាប់ IT ច្រើនកន្លែងទាំងផ្ទៃក្នុង និង ទូទាំងប្រទេស<br>↗ មានអត្រានៃការប្រើប្រាស់ឧបករណ៍ IT ច្រើនសម្រាប់អ្នកប្រើប្រាស់<br>↗ មានការប្រើប្រាស់ទូរសព្ទឆ្លាតវៃស្ទើរគ្រប់គ្នា<br>↗ មានធនធានមនុស្សផ្នែក IT ជំនាញៗ<br>↗ មានមន្ត្រីទូទៅជាច្រើនដែលមានបទពិសោធន៍ប្រើប្រាស់ប្រព័ន្ធ IT ដែលផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធ IT ផ្សេងទៀត<br>↗ បានដាក់ដំណើរការប្រព័ន្ធ IT ជាច្រើន ដោយជោគជ័យ និង មានបទពិសោធន៍ច្រើន<br>↗ មានការគាំទ្រខ្លាំងពីថ្នាក់ដឹកនាំកំពូល និង ថ្នាក់ដឹកនាំអង្គភាព ព្រមទាំងដៃគូអភិវឌ្ឍន៍លើការងារ IT<br>↗ មានការគាំទ្រផ្នែកធនធានថវិកា និង មានថវិកាពីច្រើនប្រភព | ↘ ការគ្រប់គ្រងបញ្ជីសារពើភណ្ឌឧបករណ៍ IT នៅមានកម្រិត នាំឱ្យការបំពាក់ឧបករណ៍ស្ទួនជូនអ្នកប្រើប្រាស់តែមួយ ក្នុងក្របខណ្ឌគម្រោងប្រព័ន្ធ IT ផ្សេងគ្នា<br>↘ ការប្រើប្រាស់ឧបករណ៍ IT ភាគច្រើនសម្រាប់តែការងាររដ្ឋបាល និង ការទំនាក់ទំនង<br>↘ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ IT ដោយឡែកៗពីគ្នានៅតាមអង្គភាពនីមួយៗ នាំឱ្យមានផលលំបាកក្នុងការតភ្ជាប់គ្នា (ខ្វះក្របខណ្ឌរួមសម្រាប់បណ្តាញតភ្ជាប់)<br>↘ ការរៀបចំប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្សេងៗគ្នា ដែលមានកម្មវត្ថុ, គោលបំណង និង សណ្ឋានស្រដៀង ឬ ដូចគ្នា<br>↘ គោលការណ៍ ឬ ស្តង់ដារនៃការប្រើប្រាស់ឧបករណ៍ ឬ ប្រព័ន្ធ IT មិនទាន់មានជារួម<br>↘ ការយល់ដឹងផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន នៅមានកម្រិតសម្រាប់មន្ត្រីទូទៅ<br>↘ ការផ្សារភ្ជាប់ផែនការ IT និង មុខងារស្នូលនៃអង្គភាពនីមួយៗមិនទាន់បន្សុីគ្នាពេញលេញ<br>↘ ខ្វះធនធានមនុស្សជំនាញវិជ្ជាជីវៈជាន់ខ្ពស់ ជាពិសេសវិស្វកម្ម IT និង ការវិភាគប្រព័ន្ធ IT |

| កាលានុវត្តភាព | ការគំរាមកំហែង |
|---|---|
| ↗ ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងរួមគ្នា<br>↗ ការចែករំលែកការប្រើប្រាស់ធនធានម៉ាស៊ីនមេ និង មជ្ឈមណ្ឌលទិន្នន័យរួម<br>↗ ការប្រើប្រាស់ឧបករណ៍ IT រួមគ្នាសម្រាប់ប្រព័ន្ធ IT ផ្សេងគ្នា (ឧបករណ៍ដែលស្ថិតក្នុងក្របខណ្ឌគម្រោង IT ១ អាចប្រើប្រាស់សម្រាប់គម្រោង IT ផ្សេងទៀត)<br>↗ ការបណ្តុះបណ្តាលរួមគ្នាលើជំនាញដូចគ្នា<br>↗ ការផ្តល់សេវាសាធារណៈបែបអេឡិចត្រូនិក<br>↗ ការធ្វើបរិវត្តកម្មឌីជីថល<br>↗ ការធ្វើការងារពីចម្ងាយក្នុងពេលមានការហាមឃាត់ដោយការរីករាលដាលនូវជំងឺឆ្លងផ្សេងៗ ។ | ↘ ការផ្លាស់ប្តូរទម្លាប់ និង នីតិវិធីអនុវត្តការងាររបស់មន្ត្រី និង បុគ្គលិកទូទៅ ដែលតម្រូវឱ្យមានការខិតខំ និង រៀនសូត្របន្ថែម<br>↘ ការវាយប្រហារតាមបណ្តាញអ៊ីនធឺណិត និងសន្តិសុខព័ត៌មាន<br>↘ ការផ្លាស់ប្តូរយ៉ាងលឿននៃបច្ចេកវិទ្យាព័ត៌មាន<br>↘ តម្រូវការចំណាយលើសេវាថែទាំ និង គាំទ្រមានការកើនឡើង ជាពិសេស អាជ្ញាបណ្ណថែទាំ និង គាំទ្រកម្មវិធី IT<br>↘ ការប្រកួតប្រជែងបៀវត្សមន្ត្រី ឬ បុគ្គលិកជំនាញវិជ្ជាជីវៈ IT ជាន់ខ្ពស់ជាមួយនឹងវិស័យឯកជន ជាពិសេស ធនាគារ ។ |

# ៣.ផែនការមេបច្ចេកវិទ្យាព័ត៌មាន

ផ្អែកលើស្ថានភាពបច្ចុប្បន្ន, បញ្ហាប្រឈម, ការវិភាគលើភាពខ្លាំង និង ភាពខ្សោយលើបច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ផ្អែកលើនិន្នាការនៃការរីកចម្រើនក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និង បច្ចេកវិទ្យាឌីជីថលនៅលើសាកលលោក, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានដាក់ចេញនូវផែនការមេបច្ចេកវិទ្យាព័ត៌មានរយៈពេល ៥ ឆ្នាំ (២០២១-២០២៥) ដែលនឹងមានកំណត់នូវចក្ខុវិស័យ, គោលបំណង, គោលដៅ និង សកម្មភាពគន្លឹះដូចមានរៀបរាប់ខាងក្រោម ។ ផែនការមេ IT របស់ កសហវ មានវិសាលភាពគ្របដណ្តប់នូវរាល់ការងារពាក់ព័ន្ធនឹងវិស័យ IT ទាំងអស់ ក្នុងក្របខណ្ឌ កសហវ ដោយរួមបញ្ចូលទាំងនៅទីស្តីការ កសហវ, អង្គភាពក្រោមឱវាទ កសហវ នៅថ្នាក់កណ្តាល, អង្គភាពក្រោមឱវាទ កសហវ នៅថ្នាក់មូលដ្ឋាន និង គម្រោង IT នានាដែលរៀបចំ និង គ្រប់គ្រងដោយ កសហវ ។

## ៣.១.ចក្ខុវិស័យ

ផែនការមេបច្ចេកវិទ្យាព័ត៌មានរយៈពេល ៥ ឆ្នាំ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានចក្ខុវិស័យ *"កសាង និង អភិវឌ្ឍមូលដ្ឋានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលរឹងមាំ មានសុវត្ថិភាព និង មានស្ថិរភាពខ្ពស់ និង ជំរុញការចាប់យកឌីជីថល ដើម្បីបង្កើនផលិតភាព, ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិនៃការងារ និង ការផ្តល់សេវាសាធារណៈ គាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ"* ។

## ៣.២.គោលបំណង

ផែនការមេបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានគោលបំណងកំណត់ឱ្យមាននូវក្របខណ្ឌ និង ផែនទីចង្អុលផ្លូវរួមមួយរយៈពេល ៥ ឆ្នាំ លើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយជានាបាននូវភាពសុខដុមរមនា, ការវិនិយោគចំគោលដៅ, ការចែករំលែក និង ប្រើប្រាស់ធនធានបច្ចេកវិទ្យាព័ត៌មានរួមឱ្យអស់សក្តានុពល ទាំងធនធានមនុស្សផ្នែក IT និង ទាំងធនធានឧបករណ៍សម្ភារៈ IT ទាំងផ្នែករឹង និង ទាំងផ្នែកទន់ ។

## ៣.៣.គោលដៅ និង សកម្មភាពគន្លឹះ

ដើម្បីសម្រេចនូវចក្ខុវិស័យ និង គោលបំណងខាងលើ ផែនការមេ IT របស់ កសហវ បានដាក់ចេញនូវគោលដៅចំនួន ៦ ដោយបែងចែកជាសកម្មភាពគន្លឹះចំនួន ២៣ ដូចតទៅៈ

- **ពង្រឹង និង បង្កើនសមត្ថភាព និង ស្ថិរភាពនៃហេដ្ឋារចនាសម្ព័ន្ធ និង ធនធានបច្ចេកវិទ្យាព័ត៌មាន**
  - ផ្តួចផ្តើមក្នុងការរៀបចំសហមជ្ឈមណ្ឌលទិន្នន័យចែករំលែក
  - បង្កើនធនធានប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ, ម៉ាស៊ីនមេ និង ឃ្លាំងផ្ទុកទិន្នន័យ
  - បង្កើនវិសាលភាព និង ភាពងាយស្រួលនៃការតភ្ជាប់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន
  - ពង្រឹងការគ្រប់គ្រង និង បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍របស់អ្នកប្រើប្រាស់
  - ផ្តួចផ្តើមក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដសម្រាប់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន

- **បង្កើនការអភិវឌ្ឍ, នវានុវត្តន៍ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មាន**
  - រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគាំទ្រការងារកែទម្រង់ និង មុខងារស្នូលនៃ កសហវ
  - រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងកិច្ចការបុគ្គលិក, រដ្ឋបាល និង បណ្តុះបណ្តាល
  - រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងការទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការរួម
  - រៀបចំប្រព័ន្ធអេកូឡូស៊ី និង ពង្រឹងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធ IT នីមួយៗ
  - ពង្រឹងការគ្រប់គ្រងលើដំណើរការរៀបចំ, អភិវឌ្ឍ និង កែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- **ផ្តួចផ្តើម និង សហការបង្កើនការផ្តល់សេវាបែបអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម**
  - កសាងមូលដ្ឋានគ្រឹះគាំទ្រការផ្តល់សេវាបែបអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម
  - ផ្តួចផ្តើមក្នុងការបង្កើនការដាក់ឱ្យដំណើរការ ការផ្តល់សេវាបែបអេឡិចត្រូនិក
  - រៀបចំអង្គភាពការងារបែបអេឡិចត្រូនិក និង ឌីជីថលជាគំរូ
  - ចាប់យកនិន្នាការ និង បច្ចេកវិទ្យាព័ត៌មានថ្មីៗគាំទ្រដល់ការធ្វើឌីជីថលូបនីយកម្ម
- **ពង្រឹងប្រព័ន្ធសន្តិសុខព័ត៌មាន និង ធានានិរន្តរភាពដំណើរការបច្ចេកវិទ្យាព័ត៌មាន**
  - រៀបចំប្រព័ន្ធការពារការវាយប្រហារ និង ការជ្រៀតចូលប្រព័ន្ធ IT កសហវ
  - បង្កើនសណ្តាប់ធ្នាប់នៃការគ្រប់គ្រង និង ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន
  - ពង្រឹងនិរន្តរភាពនៃប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មាន
- **អភិវឌ្ឍសមត្ថភាព និង ពង្រឹងការគ្រប់គ្រងធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មាន**
  - កសាងសមត្ថភាពជំនាញវិជ្ជាជីវៈ IT ដល់មន្ត្រី និង បុគ្គលិកបច្ចេកទេសផ្នែក IT
  - កសាងសមត្ថភាព IT និង ឌីជីថលកម្រិតមូលដ្ឋានដល់មន្ត្រី និង បុគ្គលិកទូទៅ
  - រៀបចំ និង ពង្រឹងយន្តការគ្រប់គ្រង និង ធានានិរន្តរភាពនៃធនធានមនុស្សផ្នែក IT
- **ពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន**
  - រៀបចំក្របខណ្ឌអភិបាលកិច្ចបច្ចេកវិទ្យាព័ត៌មាន
  - បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងវដ្តអាយុកាល, កិច្ចលទ្ធកម្ម និង ក្រុមហ៊ុនផ្គត់ផ្គង់ ផ្នែក IT
  - ពង្រឹងការគ្រប់គ្រងការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT ។




**រូបភាពទី ៣.១**: គំនូសបំព្រួញផែនការមេបច្ចេកវិទ្យាព័ត៌មាន កសហវ

## ៣.៤.ពង្រឹង និង បង្កើនសមត្ថភាព និង ស្ថិរភាពនៃហេដ្ឋារចនាសម្ព័ន្ធ និង ធនធាន IT

ហេដ្ឋារចនាសម្ព័ន្ធ IT គ្របដណ្តប់លើធាតុចំនួន ៣ ក្រុមធំៗ គឺ ១-មជ្ឈមណ្ឌលទិន្នន័យ និង ប្រព័ន្ធប្រតិបត្តិការម៉ាស៊ីនមេ/ឃ្លាំងផ្ទុកទិន្នន័យ, ២-បណ្តាញតភ្ជាប់/អ៊ីនត្រាណិត/អ៊ីនធឺណិត, ៣-ឧបករណ៍ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មាន ។ ហេដ្ឋារចនាសម្ព័ន្ធ IT មានសារសំខាន់ណាស់សម្រាប់ទ្រទ្រង់ និង គាំទ្រដល់ដំណើរការប្រព័ន្ធ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មាននានា ។




**រូបភាពទី ៣.២**: ក្របខណ្ឌហេដ្ឋារចនាសម្ព័ន្ធ IT

ក្នុងគោលដៅពង្រឹង និង បង្កើនសមត្ថភាព និង ស្ថិរភាពនៃហេដ្ឋារចនាសម្ព័ន្ធ និង ធនធាន IT, សកម្មភាពគន្លឹះចំនួន ៥ ត្រូវបានដាក់ចេញគឺ ១-ការផ្តួចផ្តើមក្នុងការរៀបចំសហមជ្ឈមណ្ឌលទិន្នន័យចែក-រំលែក, ២-ការបង្កើនធនធានប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ, ម៉ាស៊ីនមេ និង ឃ្លាំងផ្ទុកទិន្នន័យ, ៣-ការបង្កើនវិសាលភាព និង ភាពងាយស្រួលនៃការតភ្ជាប់ការប្រើប្រាស់ IT, ៤-ការពង្រឹងការគ្រប់គ្រង និង បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍របស់អ្នកប្រើប្រាស់ និង ៥-ការផ្តួចផ្តើមក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដសម្រាប់សេវាហេដ្ឋារចនាសម្ព័ន្ធ IT ។

### ៣.៤.១.ការផ្តួចផ្តើមក្នុងការរៀបចំសហមជ្ឈមណ្ឌលទិន្នន័យចែករំលែក

ផ្អែកតាមស្ថានភាពបច្ចុប្បន្ន មជ្ឈមណ្ឌលទិន្នន័យមេចំនួន ៤ រួមទាំង មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យចំនួន ២ ត្រូវបានកសាងឡើង និង កំពុងដំណើរការនៅក្នុងក្របខណ្ឌ កសហវ ដែលផ្តល់ជាមូលដ្ឋានមួយក្នុងការពិនិត្យលទ្ធភាពនៃការចែករំលែក និង ធ្វើសមាហរណកម្មធនធានប្រតិបត្តិការ IT នានា ដើម្បីគាំទ្រដល់គម្រោង IT ជារួមរបស់ កសហវ ។ សកម្មភាពសំខាន់ៗមួយចំនួន ត្រូវបានដាក់ចេញដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ ចែករំលែកធនធានមជ្ឈមណ្ឌលទិន្នន័យដែលមានស្រាប់របស់ កសហវ ក្នុងស្មារតីសុខដុមនីយកម្ម និង ផលចំណេញរបស់ស្ថាប័ន រួមមាន៖

- សម្រង់ព័ត៌មានលម្អិតស្ដីពីធនធាននៃមជ្ឈមណ្ឌលទិន្នន័យនីមួយៗ
- រៀបចំក្របខណ្ឌនៃសហាមជ្ឈមណ្ឌលទិន្នន័យរួមរបស់ កសហវ
- រៀបចំ និង អនុវត្តផែនការសកម្មភាពសម្រាប់ការរៀបចំសហាមជ្ឈមណ្ឌលទិន្នន័យ
- រៀបចំឯកសារទស្សនាទាននៃការរៀបចំសហប្រព័ន្ធប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ ។

### ៣.៤.២.បង្កើនធនធានប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ, ម៉ាស៊ីនមេ និង ឃ្លាំងផ្ទុកទិន្នន័យ

អគ្គនាយកដ្ឋានធំៗនៃ កសហវ រួមមាន អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ និង ក្រុមការងារគ្រប់គ្រងគម្រោង FMIS បានរៀបចំនូវផែនការពង្រីកសមត្ថភាពធនធានប្រតិបត្តិ-ការមជ្ឈមណ្ឌលទិន្នន័យរៀងៗខ្លួន ដើម្បីធានានូវភាពគ្រប់គ្រាន់ នៃតម្រូវការកើនឡើងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន សម្រាប់រយៈពេលពី ៣ ឆ្នាំ ដល់ ៥ ឆ្នាំ ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ កសហវ ផ្សេងទៀត ក៏មានតម្រូវការផងដែរក្នុងការរៀបចំ និង ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ IT សម្រួលដល់ការគ្រប់គ្រងផ្ទៃក្នុង និង ការផ្ដល់សេវាសាធារណៈរបស់ខ្លួន ដែលទាមទារជាចាំបាច់ក្នុងការបង្កើនធនធានមជ្ឈមណ្ឌលទិន្នន័យ ក្នុងក្របខណ្ឌរួម កសហវ ដើម្បីចៀសវាងនូវការស្នើសុំរៀបចំ និង កសាងមជ្ឈមណ្ឌលទិន្នន័យបន្ថែមដោយឡែកផ្សេងទៀត ។ ជាមួយគ្នានេះ មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យគួរតែត្រូវបានសាងសង់ជារួមសម្រាប់ កសហវ ដោយគោរពនូវលក្ខខណ្ឌបទដ្ឋានបច្ចេកទេស ។

សកម្មភាពសំខាន់ៗមួយចំនួន ត្រូវបានដាក់ចេញ ដើម្បីធានានូវការបង្កើនធនធាននៃប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ, ម៉ាស៊ីនមេ និង ឃ្លាំងផ្ទុកទិន្នន័យ ដែលរួមមានៈ

- អនុវត្តផែនការអភិវឌ្ឍ និង ពង្រីកសមត្ថភាពមជ្ឈមណ្ឌលទិន្នន័យរបស់គម្រោង FMIS
- អនុវត្តផែនការអភិវឌ្ឍ និង បង្កើនធនធានមជ្ឈមណ្ឌលទិន្នន័យរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អនុវត្តផែនការបង្កើនសមត្ថភាពមជ្ឈមណ្ឌលទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ
- រៀបចំ និង អនុវត្តផែនការពង្រីកសមត្ថភាព និង ធនធាននៃមជ្ឈមណ្ឌលទិន្នន័យរួមរបស់ កសហវ
- រៀបចំ និង កសាងមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យរួមមួយសម្រាប់ កសហវ ដោយនឹងកាត់បន្ថយនូវការពង្រីកមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យផ្សេងៗដែលមានស្រាប់ ។




**រូបភាពទី ៣.៣**: ផែនការមជ្ឈមណ្ឌលទិន្នន័យ កសហវ

### ៣.៤.៣.បង្កើនវិសាលភាព និង ភាពងាយស្រួលនៃការតភ្ជាប់ការប្រើប្រាស់ IT

បណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មាន រួមមាន បណ្តាញតភ្ជាប់ផ្ទៃក្នុងបន្ទប់នៃអគារ (Local Area Network – LAN), បណ្តាញតភ្ជាប់អ៊ីនត្រាណិត និង បណ្តាញតភ្ជាប់អ៊ីនធឺណិត ។ ទោះបីជាបច្ចុប្បន្ន កសហវ បានបំពាក់ស្ទើរតែទាំងស្រុងនូវបណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានស្ទើរគ្រប់ទីកន្លែង, ក៏ភាពខ្វះ-ចន្លោះនៅមាននៅឡើយសម្រាប់ការប្រើប្រាស់ជាក្រុបខណ្ឌរួមក្នុង កសហវ តែមួយ ។ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដើម្បីបង្កើនការប្រើប្រាស់ និង ផ្តល់ភាពងាយស្រួលក្នុងការតភ្ជាប់ទៅកាន់ប្រព័ន្ធ IT នានារបស់ កសហវ ពីគ្រប់អង្គភាពក្រោមឱវាទ និង មន្ត្រី កសហវ រួមមាន៖

- សិក្សាវាយតម្លៃ និង រៀបចំនូវទិដ្ឋភាពរួមផ្នែកបច្ចេកទេសនៃបណ្តាញតភ្ជាប់ កសហវ នៅទូទាំងប្រទេស
- ត្រួតពិនិត្យ និង ធ្វើការកែលម្អបណ្តាញតភ្ជាប់ផ្ទៃក្នុងនៃអគារនីមួយៗ
- ពង្រីកបន្ថែមបណ្តាញតភ្ជាប់ឆ្អឹងខ្នងទៅកាន់អង្គភាពក្រោមឱវាទ កសហវ និង អង្គភាពរដ្ឋដែលមានការពាក់ព័ន្ធជាមួយ កសហវ
- រៀបចំ និង អនុវត្តផែនការបង្កើនសមត្ថភាព និង ពង្រីកវិសាលភាពសេវាអ៊ីនធឺណិតរួម
- រៀបចំយន្តការ និង វិធាន នៃការតភ្ជាប់ការប្រើប្រាស់ប្រព័ន្ធ IT កសហវ តាមបណ្តាញអ៊ីនធឺណិត ។

### ៣.៤.៤.ពង្រឹងការគ្រប់គ្រង និង បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍របស់អ្នកប្រើប្រាស់

ការគ្រប់គ្រងលើការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ដែលប្រើប្រាស់សម្រាប់ភ្ជាប់ជាមួយប្រព័ន្ធ IT របស់ កសហវ គឺជាការចាំបាច់បំផុត ដើម្បីធានាដល់ភាពគ្រប់គ្រាន់នៃការប្រើប្រាស់ និង រួមចំណែកក្នុងការបង្កើនសន្តិសុខនៃទិន្នន័យ និង បណ្តាញ IT របស់ កសហវ ។ ឧបករណ៍របស់អ្នកប្រើប្រាស់អាចជា ម៉ាស៊ីនកុំព្យូទ័រ, ទូរសព្ទដៃ, ម៉ាស៊ីនបោះពុម្ព ជាដើម ដែលបំពាក់ដោយ កសហវ, គម្រោងណាមួយ ឬ ឧបករណ៍ផ្ទាល់ខ្លួន ។ ដើម្បីចូលរួមចំណែកក្នុងការពង្រឹងការគ្រប់គ្រងឧបករណ៍របស់អ្នកប្រើប្រាស់ផ្សារភ្ជាប់ទៅនឹងការរៀបចំយន្តការ និង គោលការណ៍មួយចំនួននៅក្នុងការពង្រឹងអភិបាលកិច្ចនៃ IT និង ពង្រឹងសន្តិសុខនៃ IT, សកម្មភាពចំនួន ៤ ត្រូវបានដាក់ចេញ ដូចខាងក្រោម៖

- រៀបចំចំណាត់ថ្នាក់នៃឧបករណ៍ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់អ្នកប្រើប្រាស់
- រៀបចំ និង ដាក់ឱ្យដំណើរការកម្មវិធី IT គ្រប់គ្រងការប្រើប្រាស់ឧបករណ៍អ្នកប្រើប្រាស់
- រៀបចំ និង អនុវត្តផែនការបំពាក់កម្មវិធីកម្ចាត់មេរោគ IT នៅលើកុំព្យូទ័រ
- រៀបចំ និង អនុវត្តផែនការបំពាក់អាជ្ញាបណ្ណកម្មវិធី IT ដែលប្រើប្រាស់ក្នុង កសហវ ។

### ៣.៤.៥.ផ្តួចផ្តើមក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដសម្រាប់សេវាហេដ្ឋារចនាសម្ព័ន្ធ IT

បច្ចេកវិទ្យាក្លោដ (Cloud Technology) នឹងត្រូវផ្តួចផ្តើមក្នុងការទាញយកនូវអត្ថប្រយោជន៍ជាអតិបរមាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ IT មកបម្រើដល់សេចក្តីត្រូវការរបស់ កសហវ ក្នុងការធ្វើឌីជីថលូបនីយកម្ម និង ការវិភាគទិន្នន័យកម្រិតខ្ពស់ ។ ក្នុងខណៈដែល កសហវ មានមជ្ឈមណ្ឌលទិន្នន័យស្រាប់ ការប្រើប្រាស់ក្លោដឯកជន (Private Cloud) គឺជាជម្រើសមួយដ៏ល្អក្នុងការសម្រួលបន្ថែមដល់ការគ្រប់គ្រងធនធាន និង ផ្តល់សេវា IT ដែលមានស្រាប់ ជូនអង្គភាពក្រោមឱវាទ កសហវ ។ ចំណែកឯ ក្លោដសាធារណៈ (Public Cloud) ក៏អាចគិតគូរក្នុងការប្រើប្រាស់ដើម្បីដំណើរការគណនា ឬ វិភាគទិន្នន័យដែលមានទ្រង់ទ្រាយធំ (Big Data) ឆ្លើយតបទៅនឹងការធ្វើស្វ័យប្រវត្តិកម្មការព្យាករណ៍, ការប្រើប្រាស់បញ្ញាសប្បនិម្មិត (Artificial Intelligent – AI) ជាដើម ក្នុងករណីដែលកម្រិតធនធាននៃមជ្ឈមណ្ឌលទិន្នន័យរបស់ កសហវ មិនមានលទ្ធភាពក្នុងការគណនា ឬ ប្រតិបត្តិការបាន ។ ដូចនេះ កសហវ នឹងអាចចាប់យកប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាក្លោដក្នុងជម្រើសទាំងពីរ ទៅតាមតម្រូវការជាក់ស្តែង ។ សកម្មភាពមួយចំនួន ត្រូវបានដាក់ចេញ ដើម្បីគាំទ្រដល់ការពិនិត្យលទ្ធភាពក្នុងចាប់យកបច្ចេកវិទ្យាក្លោដមកប្រើប្រាស់ រួមមាន៖

- សិក្សាវាយតម្លៃអំពីលទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាក្លោដនៅក្នុង កសហវ
- រៀបចំក្របខណ្ឌគតិយុត្តក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដ ប្រទាក់ក្រឡានឹងក្របខណ្ឌថ្នាក់ជាតិ
- រៀបចំ និង អនុវត្តផែនការក្នុងការសាកល្បងប្រើប្រាស់បច្ចេកវិទ្យាក្លោដជាជំហានៗ សម្រាប់មជ្ឈមណ្ឌលទិន្នន័យរួម កសហវ ។




**រូបភាពទី ៣.៤**: ហេដ្ឋារចនាសម្ព័ន្ធ IT ឆ្នាំ ២០២៥

## ៣.៥.បង្កើនការអភិវឌ្ឍ, នវានុវត្តន៍ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធ និង កម្មវិធី IT

យោងតាមស្ថានភាពជាក់ស្តែងបច្ចុប្បន្ន កសហវ បានដាក់ឱ្យដំណើរការនូវប្រព័ន្ធ IT ធំៗមួយចំនួនក្នុងការគាំទ្រដល់កិច្ចដំណើរការមុខងារស្នូលរបស់ កសហវ ជាពិសេសគាំទ្រដល់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ទោះជាយ៉ាងនេះ មុខងារស្នូលរបស់ កសហវ មួយចំនួនក៏នៅមិនទាន់បានដាក់ឱ្យដំណើរការនូវប្រព័ន្ធ IT នៅឡើយ រួមជាមួយនឹងការគ្រប់គ្រងប្រតិបត្តិការការងារ និង ការទំនាក់ទំនងការងារផ្ទៃក្នុង ។ម្យ៉ាងទៀត បើទោះបីជាកិច្ចការងារមួយចំនួនត្រូវបានដំណើរការដោយប្រព័ន្ធ IT រួចហើយក្តី ក៏មិនមានន័យថាល្អប្រសើរគ្រប់គ្រាន់នោះទេ គឺទាមទារនូវការធ្វើទំនើបកម្ម និង អភិវឌ្ឍកែលម្អជាបន្តបន្ទាប់បន្ថែមទៀត ដើម្បីឆ្លើយតបបានទាន់ពេលវេលាទៅនឹងការកើនឡើងនូវតម្រូវការនៃការប្រើប្រាស់ និង ការផ្លាស់ប្តូររបៀបរបបការងារ ។

ស្របពេលដែលហេដ្ឋារចនាសម្ព័ន្ធ IT ត្រូវបានពង្រឹង និង ពង្រីកសមត្ថភាព សកម្មភាពគន្លឹះមួយចំនួនត្រូវបានដាក់ចេញ ដើម្បីបង្កើនការអភិវឌ្ឍ, នវានុវត្តន៍ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធ IT នៅក្នុង កសហវ រួមមាន ១-ការរៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគាំទ្រការងារកែទម្រង់ និង មុខងារស្នូលនៃ កសហវ, ២-ការរៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងកិច្ចការបុគ្គលិក, រដ្ឋបាល និង បណ្តុះ-បណ្តាល, ៣-ការរៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងការទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការរួម,

៤-ការរៀបចំប្រព័ន្ធអេកូឡូស៊ី និង ពង្រឹងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធ IT នីមួយៗ, ៥-ការពង្រឹងការគ្រប់គ្រងលើដំណើរការរៀបចំ, អភិវឌ្ឍ និង កែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

## ៣.៥.១.រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគាំទ្រការងារកែទម្រង់ និង មុខងារស្នូល កសហវ

ក្នុងការគាំទ្រការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនត្រូវបានផ្តួចផ្តើមរៀបចំ, កសាង និង ដាក់ឱ្យដំណើរការអនុវត្តរួចរាល់ រួមមាន ប្រព័ន្ធ FMIS, ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ, ប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបំណុលសាធារណៈ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ជាដើម ។ ក្នុងចំណោមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានខាងលើនេះ ប្រព័ន្ធមួយចំនួនទើបតែបានចាប់ផ្តើមដាក់ឱ្យដំណើរការអនុវត្ត, មួយចំនួនកំពុងតែអភិវឌ្ឍមុខងារបន្ថែមថ្មី និង មួយចំនួនទៀតបានគ្រោងនឹងធ្វើទំនើបកម្មបន្ថែម ។ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដើម្បីបន្តអភិវឌ្ឍ, កែលម្អ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅក្នុង កសហវ គាំទ្រដល់ការងារកែទម្រង់ និង មុខងារស្នូលនៃ កសហវ រួមមាន៖

- ពង្រីកវិសាលភាពនៃការប្រើប្រាស់ និង អភិវឌ្ឍមុខងារថ្មីបន្ថែមក្នុងប្រព័ន្ធ FMIS (ផ្អែកលើផែនការពង្រីកការអនុវត្តគម្រោង FMIS ដំណាក់ទី៣ ២០២១-២០២៥)
- រៀបចំ និង អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និង ការធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS (Public Investment Management System - PIMS)
- ធ្វើសមាហរណកម្មប្រែក្លាយប្រព័ន្ធចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋបច្ចុប្បន្ន ទៅជាមុខងារមួយនៅក្នុងប្រព័ន្ធ FMIS
- សិក្សា, រៀបចំ, កសាង និង ដាក់ឱ្យដំណើរការជាដំណាក់ៗ កម្មវិធីបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងការអនុវត្តថវិកា និង ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សមាហរណកម្មជាមួយប្រព័ន្ធ FMIS
- ពង្រីកវិសាលភាពការប្រើប្រាស់ និង អភិវឌ្ឍមុខងារបន្ថែមលើប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករ
- ពង្រីកវិសាលភាពការប្រើប្រាស់ និង អភិវឌ្ឍបន្ថែមមុខងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់-គ្រងទិន្នន័យពន្ធដារ
- ធ្វើទំនើបកម្ម និង ពង្រីកវិសាលភាពការប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)
- ពង្រីកវិសាលភាពការប្រើប្រាស់ និង ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ
- ធ្វើទំនើបកម្មប្រព័ន្ធ IT គ្រប់គ្រងទិន្នន័យស្ថិតិសេដ្ឋកិច្ច
- រៀបចំឯកសារទស្សនាទានក្នុងការរៀបចំ និង កសាងប្រព័ន្ធស្វ័យប្រវត្តិកម្មព្យាករណ៍ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ។

### ៣.៥.២.រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងកិច្ចការបុគ្គលិក, រដ្ឋបាល និង បណ្តុះបណ្តាល

បច្ចុប្បន្ន អគ្គនាយកដ្ឋានធំៗ បានរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងការងារផ្ទៃក្នុងរៀងៗខ្លួន ក្នុងខណៈដែលប្រព័ន្ធមួយចំនួនមានសណ្ឋាន, លក្ខណៈ និង គោលបំណងស្ទើរតែដូចគ្នាទាំងស្រុង ដូចជា ប្រព័ន្ធគ្រប់គ្រងឯកសារអេឡិចត្រូនិក, ប្រព័ន្ធគ្រប់គ្រងបុគ្គលិក, ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌ, ប្រព័ន្ធគ្រប់គ្រងកាលវិភាគការងារ ជាដើម ។ ដើម្បីពង្រឹងនូវការរៀបចំប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរួម សកម្មភាពចម្បងមួយចំនួនត្រូវបានដាក់ចេញ រួមមាន៖

- ធ្វើទំនើបកម្ម និង ពង្រីកមុខងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យមន្ត្រី និង បុគ្គលិក
- រៀបចំ និង អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសកម្មភាពការងារ និង សមិទ្ធកម្មការងារ ដោយធ្វើសមាហរណកម្មជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រី និង បុគ្គលិក កសហវ ដោយរួមបញ្ចូលនូវមុខងារបេសកកម្ម និង កិច្ចប្រជុំ
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលមន្ត្រី និង បុគ្គលិក
- រៀបចំ និង កសាងប្រព័ន្ធ IT គ្រប់គ្រងឯកសារអេឡិចត្រូនិក និង រំហូរនៃឯកសារ
- ធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិ និង បញ្ជីសារពើភណ្ឌលម្អិតផ្ទៃក្នុង កសហវ សមាហរណកម្មជាមួយប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ
- បង្កើតកម្មវិធីទូរសព្ទដៃ ឬ ឧបករណ៍ឆ្លាតវៃគាំទ្រដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានា ។

### ៣.៥.៣.រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងការទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការរួម

ស្ថិតក្នុងស្ថានភាពនៃការរីករាលដាលនូវជំងឺកូវីដ-១៩ ការធ្វើការងារពីចម្ងាយ គឺជាមធ្យោបាយមួយដ៏ប្រសើរ ក្នុងការបន្តនិរន្តរភាពការងារផ្អែកតាមផែនការដែលបានដាក់ចេញ ដើម្បីចៀសវាងការជាប់គាំងណាមួយបណ្តាលមកពីការរីករាលដាលនៃជំងឺនេះ ។ ដើម្បីបង្ការក្នុងករណីមានការកើតឡើងព្រឹត្តិការណ៍ណាមួយ ក្នុងទ្រង់ទ្រាយស្រដៀងគ្នានឹងការរីករាលដាលជំងឺកូវីដ-១៩ នេះ ទៅថ្ងៃអនាគត, ការរៀបចំ និង ពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់ការទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការការងារផ្ទៃក្នុងគឺជាការចាំបាច់បំផុត ។ ការទំនាក់ទំនង និង សហប្រតិបត្តិការនៅក្នុងការងារបច្ចុប្បន្ន អនុវត្តទៅតាមតម្រូវការជាក់ស្តែង ដែលរួមមាន ការទំនាក់ទំនងតាមសារអេឡិចត្រូនិក, ការផ្ញើសារជជែកពិភាក្សាគ្នា, ការហៅទូរសព្ទ, ការប្រជុំពីចម្ងាយ, ការកំណត់កាលវិភាគរួមគ្នា, ការរៀបចំ និង ពិនិត្យឯកសាររួមគ្នា ជាដើម ។ សកម្មភាពចម្បងដើម្បីសម្រេចនូវគោលដៅដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទំនាក់ទំនង និង កិច្ចសហ-ប្រតិបត្តិការ រួមមាន៖

- បង្កើនសមត្ថភាពប្រព័ន្ធគ្រប់គ្រងសារអេឡិចត្រូនិក កសហវ និង ពង្រឹងការប្រើប្រាស់សម្រាប់ការទំនាក់ទំនងការងារផ្លូវការ ( MEF Email )
- រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការប្រព័ន្ធជជែកពិភាក្សាផ្ទៃក្នុង ( Chatting / Forum )

- ពង្រីកសមត្ថភាព និង វិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធសន្និសីទវីដេអូ និង សំឡេង ( Voice/Video Conferencing )
- រៀបចំ និង ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងការចែករំលែក និង ការរក្សាទុកឯកសារអេឡិចត្រូនិក ( File Store/Sync/Share )
- អភិវឌ្ឍ និង ប្រែក្លាយប្រព័ន្ធជំនួយគាំទ្រលើការប្រើប្រាស់ប្រព័ន្ធ FMIS ដែលមានបច្ចុប្បន្ន ជាប្រព័ន្ធគ្រប់គ្រងការផ្ដល់សេវា IT រួមសម្រាប់ កសហវ
- អភិវឌ្ឍកម្មវិធីប្រតិទិនអេឡិចត្រូនិក កសហវ សមាហរណកម្មជាមួយកាលវិភាគការងាររបស់មន្ត្រី និង ក្រុមការងារ ។

## ៣.៥.៤.រៀបចំប្រព័ន្ធអេកូឡូស៊ី និង ពង្រឹងការផ្លាស់ប្ដូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

កសហវ បានរៀបចំ និង ដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើនគាំទ្រដល់ការគ្រប់គ្រងមុខងារស្នូលរបស់ខ្លួន និង គ្រប់គ្រងប្រតិបត្តិការការងារផ្ទៃក្នុង ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ កសហវ មួយចំនួនត្រូវបានធ្វើសន្ទានកម្មផ្លាស់ប្ដូរទិន្នន័យរវាងគ្នារួចហើយ ព្រមទាំងបានធ្វើសន្ទានកម្មផ្លាស់ប្ដូរទិន្នន័យ ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នខាងក្រៅ រួមទាំង ធនាគារជាដៃគូផងដែរ ។ សកម្មភាពមួយចំនួនបានដាក់ចេញ ដើម្បីពង្រឹងការផ្លាស់ប្ដូរទិន្នន័យរវាងប្រព័ន្ធនីមួយៗ រួមមាន៖

- រៀបចំក្របខណ្ឌប្រព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ កសហវ រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័នពាក់ព័ន្ធខាងក្រៅ អនុលោមតាមក្របខណ្ឌនៃថ្នាលផ្លាស់-ប្ដូរទិន្នន័យកម្ពុជា ( CamDX )
- រៀបចំនូវវិធាន និង បទដ្ឋានបច្ចេកទេសសម្រាប់ការផ្លាស់ប្ដូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ
- រៀបចំ និង អភិវឌ្ឍនូវច្រកផ្លាស់ប្ដូរទិន្នន័យនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ កសហវ រួម ( API Gateway ) ជាមួយប្រព័ន្ធខាងក្រៅ ។

## ៣.៥.៥.ពង្រឹងការគ្រប់គ្រងលើដំណើរការរៀបចំ, អភិវឌ្ឍ និង កែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

អគ្គនាយកដ្ឋានធំៗរបស់ កសហវ មានធនធានមនុស្សផ្នែកបច្ចេកវិទ្យាព័ត៌មានជាច្រើនរូប ដែលអាចរៀបចំ និង បង្កើតកម្មវិធីបច្ចេកវិទ្យាព័ត៌មាន ឆ្លើយតបនឹងតម្រូវការការងារទៅតាមមុខងារភារកិច្ចរបស់ខ្លួនដែល កសហវ បានកំណត់ ។ ជាមួយគ្នានេះ បើទោះបីជាកម្មវិធីបច្ចេកវិទ្យាមួយចំនួនត្រូវបានទិញពីក្រុមហ៊ុននៅក្រៅស្រុក ក៏ការកែសម្រួល និង អភិវឌ្ឍបន្ថែមមុខងារមួយចំនួនធំ ត្រូវបានធ្វើឡើងដោយធនធានមនុស្សរបស់ កសហវ ផងដែរ ដូចជាករណី ប្រព័ន្ធ FMIS និង ប្រព័ន្ធ ASYCUDA ជាដើម ។ ដើម្បីបង្កើនប្រសិទ្ធភាព និង អនុវត្តវិធានការសហប្រតិបត្តិការបង្កើត អភិវឌ្ឍ និង កែលម្អ លើកម្មវិធីបច្ចេក-វិទ្យាព័ត៌មាន, សកម្មភាពមួយចំនួនត្រូវបានផ្ដួចផ្ដើមក្នុងការអនុវត្ត រួមមាន៖

- រៀបចំក្របខណ្ឌនៃការគ្រប់គ្រងដំណើរការរៀបចំ និង កសាងកម្មវិធី ឬ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

- រៀបចំវិធាន និង យន្តការក្នុងការគ្រប់គ្រងប្រភពកូដដើម (Source Code) នៃកម្មវិធីបច្ចេកវិទ្យាព័ត៌មាននានារបស់ កសហវ
- ផ្តួចផ្តើមក្នុងការប្រើប្រាស់ថ្នាលបច្ចេកវិទ្យាព័ត៌មានរួមក្នុង កសហវ សម្រាប់ការគ្រប់គ្រងវដ្តនៃដំណើរការនៃការអភិវឌ្ឍ, ការកែលម្អ និង ការដាក់ឱ្យដំណើរការប្រព័ន្ធ IT ។

## ៣.៦.ផ្តួចផ្តើម និង សហការបង្កើនការផ្តល់សេវាអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម

ស្របពេលដែល កសហវ បានដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើន កសហវ ក៏បានដាក់ឱ្យដំណើរការជាបណ្តើរៗនូវការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក, ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ជាដើម ដែលបានជំរុញឱ្យមានការគិតគូរបន្ថែមក្នុងការពង្រីកការផ្តល់សេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក និង ការធ្វើការងារតាមបែបឌីជីថល ជាពិសេសនៅក្នុងស្ថានភាពនៃការរីករាលដាលនូវជំងឺកូវីដ-១៩ តែម្តង ។ ដើម្បីសម្រេចនូវគោលដៅនៃការពង្រីកការផ្តល់សេវាបែបអេឡិចត្រូនិក និង ការអនុវត្តការងារបែបឌីជីថល សកម្មភាពគន្លឹះមួយចំនួន ត្រូវបានដាក់ចេញដើម្បីអនុវត្ត រួមមាន ១-ការកសាងមូលដ្ឋានគ្រឹះគាំទ្រការផ្តល់សេវាបែបអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម, ២-ការផ្តួចផ្តើមក្នុងការបង្កើនការផ្តល់សេវាបែបអេឡិចត្រូនិករបស់ កសហវ, ៣-ការផ្តួចផ្តើមក្នុងការធ្វើឌីជីថលូបនីយកម្ម និង ៤-ការចាប់យកនិន្នាការ និង បច្ចេកវិទ្យាព័ត៌មានថ្មីៗ ។

### ៣.៦.១.កសាងមូលដ្ឋានគ្រឹះគាំទ្រការផ្តល់សេវាបែបអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម

ក្នុងបេសកកម្មឆ្ពោះទៅការបង្កើនការផ្តល់សេវាបែបអេឡិចត្រូនិក និង លើកកម្ពស់ការប្រើប្រាស់ទិន្នន័យ និង ប្រតិបត្តិការឌីជីថល មូលដ្ឋានគ្រឹះមួយចំនួនត្រូវតែធ្វើការរៀបចំ និង កសាងឱ្យបានរួចរាល់ ។ បន្ថែមលើការបង្កើនសមត្ថភាព និង ស្ថិរភាពនៃហេដ្ឋារចនាសម្ព័ន្ធ IT និង ការរៀបចំ និង កសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, មូលដ្ឋានគ្រឹះមួយចំនួនផ្សេងទៀតក៏ត្រូវតែគិតគូរ, រៀបចំ និង កសាងឡើងដើម្បីគាំទ្រឱ្យបានរឹងមាំបន្ថែមដល់ការផ្តល់សេវាបែបអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម តាមរយៈការអនុវត្តសកម្មភាព ដូចខាងក្រោម៖

- រៀបចំ និង កសាងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណឌីជីថល កសហវ ផ្សារភ្ជាប់នឹងប្រព័ន្ធគ្រប់គ្រងមន្ត្រី និង បុគ្គលិក របស់ កសហវ និង ថ្នាល CamDigiKey
- រៀបចំ និង កសាងថ្នាលបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងគណនីរួមសម្រាប់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់ កសហវ (Single Sign-on Platform)
- រៀបចំឯកសារទស្សនាទាន និង ក្របខណ្ឌគតិយុត្តក្នុងការប្រើប្រាស់ហត្ថលេខាឌីជីថល
- រៀបចំ និង កសាងប្រព័ន្ធគ្រប់គ្រងហត្ថលេខាឌីជីថល កសហវ
- រៀបចំថ្នាលទូទាត់អេឡិចត្រូនិករួមសម្រាប់ការទូទាត់ជាមួយគណនីទោលរតនាគារ
- រៀបចំឯកសារមគ្គុទេសក៍ក្នុងការធ្វើឌីជីថលូបនីយកម្មសម្រាប់អង្គភាពក្រោមឱវាទ កសហវ
- បន្តអនុវត្តផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS

- រៀបចំផែនការយុទ្ធសាស្ត្រ តម្រង់ទិសនីតិវិធីអនុវត្តការងារប្រតិបត្តិការផ្ទៃក្នុង កសហវ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រៀបចំផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារសម្រាប់ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

### ៣.៦.២.ផ្តួចផ្តើមក្នុងការបង្កើនការផ្តល់សេវាបែបអេឡិចត្រូនិក

បច្ចុប្បន្ន កសហវ បានផ្តល់សេវាសាធារណៈមួយចំនួនជូនដល់ប្រជាពលរដ្ឋ និង ធុរជន រួមមាន សេវាពន្ធដារ, សេវាគយ និង រដ្ឋាករ, សេវាឧស្សាហកម្មហិរញ្ញវត្ថុ, សេវាគណនេយ្យ និង សវនកម្ម និង សេវាលទ្ធកម្មសាធារណៈ ។ ក្នុងចំណោមសេវាសាធារណៈទាំងអស់របស់ កសហវ មានតែសេវាក្នុងរង្វង់ប្រមាណ ២០% ប៉ុណ្ណោះដែលបានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រងប្រតិបត្តិការការងារ និង ប្រមាណ ៥% តែប៉ុណ្ណោះដែលបានផ្តល់ជូនធុរជន ឬ សាធារណជនតាមបែបអេឡិចត្រូនិក គឺ សេវាពន្ធដារ និង សេវាគយ និង រដ្ឋាករ, តាមរយៈការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង ប្រព័ន្ធស្វ័យប្រវត្តិកម្មពន្ធដារ ។

ការផ្តល់សេវាតាមបែបអេឡិចត្រូនិក នឹងផ្តល់នូវផលចំណេញជាច្រើនសម្រាប់អ្នកផ្តល់សេវា និង អ្នកទទួលសេវា, ដោយអ្នកផ្តល់សេវា និង អ្នកទទួលសេវា មិនចាំបាច់ជួបគ្នាផ្ទាល់, កាត់បន្ថយការធ្វើដំណើរ, កាត់បន្ថយប្រតិបត្តិការរដ្ឋបាល, ចំណេញពេលវេលា, បង្កើននូវតម្លាភាព និង បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា ។ បន្ទាប់ពីបានកសាងនូវហេដ្ឋារចនាសម្ព័ន្ធ IT ប្រកបដោយសមត្ថភាព និង មានគុណភាព រួមទាំង ការដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើន ក្នុងការគ្រប់គ្រងប្រតិបត្តិការការងារលើផ្តល់សេវា, ការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក ក៏គួរត្រូវលើកយកមកគិតគូរដាក់ឱ្យអនុវត្តជាជំហានៗ ដើម្បីផ្តល់នូវតម្លៃបន្ថែមសម្រាប់ការវិនិយោគក្នុងវិស័យ IT ដែលមានស្រាប់ ព្រមទាំង ដើម្បីបំពេញចិត្តអ្នកទទួលសេវាដែលជាធុរជន និង សាធារណជនទូទៅ ។ ក្នុងការផ្តួចផ្តើមបង្កើននូវការផ្តល់សេវាសាធារណៈបែបអេឡិចត្រូនិក, សកម្មភាពមួយចំនួននឹងត្រូវអនុវត្ត រួមមាន៖

- ធ្វើបច្ចុប្បន្នភាពបញ្ជីសេវាសាធារណៈរបស់ កសហវ និង វាយតម្លៃលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈតាមបែបអេឡិចត្រូនិក
- រៀបចំផែនការ និង ផែនទីចង្អុលផ្លូវរួមសម្រាប់ការពង្រីកការផ្តល់សេវាសាធារណៈតាមបែបអេឡិចត្រូនិក
- រៀបចំផតថលអនឡាញ (Online Portal) រួមរបស់ កសហវ សម្រាប់ប្រមូលផ្តុំនូវសេវាសាធារណៈទាំងអស់ដែលអាចផ្តល់តាមបែបអេឡិចត្រូនិក ។

### ៣.៦.៣.រៀបចំអង្គភាពការងារបែបអេឡិចត្រូនិក និង ឌីជីថលគំរូ

ដោយមានការកើនឡើងនៃការរៀបចំ និង កសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការប្រើប្រាស់ក្នុងការគ្រប់គ្រងកិច្ចការងារផ្ទៃក្នុង ដូចជា កិច្ចការបុគ្គលិក, កិច្ចការរដ្ឋបាល, ការផ្តល់សេវាផ្ទៃក្នុង, ការទំនាក់ទំនង និង សហប្រតិបត្តការការងារ, បានផ្តល់នូវមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការពង្រីកមុខងារប្រព័ន្ធ

ទាំងនោះឱ្យឆ្លើយតបនឹងវំហូរការងារដែលមានស្រាប់ រួមមាន ការស្នើសុំ, ការត្រួតពិនិត្យ និង ការអនុម័ត តាមប្រព័ន្ធទាំងស្រុងតែម្តង ដែលអាចប្រែក្លាយរបៀបនៃការធ្វើការងារតាមប្រព័ន្ធអេឡិចត្រូនិក ជាជំហានៗ ដោយនឹងកាត់បន្ថយការប្រើប្រាស់ឯកសារជាក្រដាស, ចំណេញពេលវេលា, បង្កើនបន្ថែមនូវប្រសិទ្ធភាព និង តម្លាភាពនៅក្នុងការងារ ។ កត្តាទាំងនេះ បានផ្តល់នូវមូលដ្ឋានដែលជាជំហាននៃការរៀបចំអង្គភាព បែបអេឡិចត្រូនិក ដោយចាប់ផ្តើមចេញពីការរៀបចំអង្គភាពអេឡិចត្រូនិកគំរូ តាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម ៖

- រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការទម្រង់ស្នើសុំនានាជាអេឡិចត្រូនិក (e-Forms) សម្រាប់ការងារផ្ទៃក្នុង
- រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការមុខងារវំហូរការងារផ្ទៃក្នុងអេឡិចត្រូនិកនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងកិច្ចការបុគ្គលិក និង រដ្ឋបាល
- រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការថ្នាលបណ្តុះបណ្តាលអេឡិចត្រូនិក (e-Learning)
- រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការបណ្ណាល័យអេឡិចត្រូនិក កសហវ (e-Library)
- រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការផតថលអនឡាញ កសហវ រួមសម្រាប់ប្រតិបត្តិការ និង ការងារផ្ទៃក្នុង ។

### ៣.៦.៤.ចាប់យកនិន្នាការបច្ចេកវិទ្យាព័ត៌មានថ្មីៗគាំទ្រដល់ការធ្វើឌីជីថលូបនីយកម្ម

និន្នាការបច្ចេកវិទ្យាព័ត៌មាន និង បច្ចេកវិទ្យាឌីជីថលសាកល មានការរីកចម្រើន និង អភិវឌ្ឍជាលំដាប់ ដែលបង្កើតនូវឱកាសនៃការប្រកួតប្រជែង និង ការផ្លាស់ប្តូរជាច្រើន ទាំងវិស័យសាធារណៈ និង វិស័យឯកជន ។ ការចាប់យកឱកាសនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានថ្មីៗបានឆាប់រហ័ស គឺជាការរួមចំណែកដ៏ធំធេងក្នុងការជំរុញការអភិវឌ្ឍស្ថាប័ន និង សង្គម ។ ជាក់ស្តែង ស្ថានភាពរបស់ កសហវ គឺអាចពិនិត្យលទ្ធភាព ក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗបន្ថែមមួយចំនួនទៀត ដែលនឹងអាចជួយដល់ការវិភាគ, ការព្យាករណ៍ និង ការផ្តល់ព័ត៌មានក្នុងការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ ។ សកម្មភាពមួយចំនួនដែលត្រូវធ្វើការស្រាវជ្រាវ និង សាកល្បងអនុវត្ត រួមមាន៖

- រៀបចំឯកសារទស្សនាទានការប្រើប្រាស់បច្ចេកវិទ្យាទិន្នន័យធំ (Big Data), វិទ្យាសាស្ត្រទិន្នន័យ (Data Science), បច្ចេកវិទ្យាបញ្ញាសប្បនិម្មិត (Artificial Intelligent - AI / Machine Learning - ML), បច្ចេកវិទ្យាក្លោដ (Cloud Technology) ជាដើម គាំទ្រដល់ការងារស្ថិតិ, វិភាគ និង ព្យាករណ៍, ការធ្វើស្វ័យប្រវត្តិកម្មការងារ ឬ ថ្នាលបច្ចេកវិទ្យាព័ត៌មាននានា
- ស្រាវជ្រាវទៅលើបច្ចេកវិទ្យាព័ត៌មាន និង បច្ចេកវិទ្យាឌីជីថលថ្មីៗ ដែលជាប្រយោជន៍នៃការប្រែក្លាយការងារបែបឌីជីថល ។

## ៣.៧.ពង្រឹងប្រព័ន្ធសន្តិសុខព័ត៌មាន និង ធានានិរន្តរភាពប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មាន

ក្នុងពេលដែល កសហវ មានការប្រើប្រាស់ច្រើននូវហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គាំទ្រដល់ការងារស្នូល និង ការងារផ្ទៃក្នុង, មានន័យថា ទិន្នន័យ និង ព័ត៌មានអេឡិចត្រូនិកជាច្រើនត្រូវបានធ្វើចរាចរនៅលើបណ្តាញបច្ចេកវិទ្យាព័ត៌មាន ទាំងបណ្តាញអ៊ីនត្រាណិត និង អ៊ីនធឺណិត ហើយទិន្នន័យទាំងនោះនឹងរក្សាទុកនៅក្នុងមជ្ឈមណ្ឌលទិន្នន័យរបស់ កសហវ, និង មួយចំនួនរក្សានៅក្នុងឧបករណ៍បច្ចេកវិទ្យាព័ត៌មានរបស់មន្ត្រី និង បុគ្គលិកម្នាក់ៗ ឬ រក្សាទុកនៅក្នុងមជ្ឈមណ្ឌលទិន្នន័យនៅក្រៅ កសហវ ។ ទិន្នន័យ និង ព័ត៌មានឌីជីថលទាំងនេះ រួមមាន ទាំងទិន្នន័យចំហរ និង ទិន្នន័យសើបដែលប្រើប្រាស់សម្រាប់តែផ្ទៃក្នុង កសហវ តែប៉ុណ្ណោះ, ហើយក្នុងករណីមិនអាចប្រើប្រាស់ទិន្នន័យទាំងនោះបានទេ គឺមិនអាចបំពេញការងារបានតែម្តង ។ ក្នុងន័យនេះ ទិន្នន័យឌីជីថលគឺជាទ្រព្យសម្បត្តិដ៏មានតម្លៃរបស់ស្ថាប័ន ដែលត្រូវការនូវប្រព័ន្ធការពារដ៏រឹងមាំ និង ធានានូវការប្រើប្រាស់បានគ្រប់ពេលវេលា ជាពិសេសនៅក្នុងម៉ោងបំពេញការងារ ចៀសវាងការវាយប្រហារធ្វើឱ្យខូចខាត ឬ ការលួចយកទិន្នន័យទៅបម្រើការងារមួយចំនួនរបស់ក្រុមសង្គមងងឹត ។

ទន្ទឹមនឹងនេះ ហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក៏ជាធាតុដ៏ចាំបាច់សម្រាប់ធ្វើប្រតិបត្តិការ និង បញ្ជូន/ទទួលទិន្នន័យឌីជីថល គាំទ្រដល់ការធ្វើប្រតិបត្តិការការងារប្រចាំថ្ងៃរបស់មន្ត្រី និង បុគ្គលិកក្នុងការផ្តល់សេវា, ការទំនាក់ទំនងការងារ និង ការកត់ត្រាផ្សេងៗ ។ ហេតុនេះ ប្រព័ន្ធការពារសុវត្ថិភាពលើហេដ្ឋារចនាសម្ព័ន្ធ, ឧបករណ៍ និង ប្រព័ន្ធ IT ត្រូវការការរៀបចំឱ្យបានគត់មត់ និង រឹងមាំ ដើម្បីធានានូវសុវត្ថិភាព ពីសំណាក់ក្រុមវាយប្រហារ (Hacker) ក្នុងការព្យាយាមបង្អាក់នូវដំណើរការណាមួយរបស់ប្រព័ន្ធ IT ឬ បំផ្លាញនូវឧបករណ៍ IT របស់ កសហវ ។

ដើម្បីពង្រឹងប្រព័ន្ធសន្តិសុខព័ត៌មាន និង ធានានិរន្តរភាពនៃដំណើរការបច្ចេកវិទ្យាព័ត៌មាន, ចាំបាច់ត្រូវអនុវត្តនូវសកម្មភាពការងារមួយចំនួន រួមមាន ១-ការរៀបចំប្រព័ន្ធការពារការវាយប្រហារ និង ការជ្រៀតចូលប្រព័ន្ធ IT កសហវ, ២-ការបង្កើនសណ្តាប់ធ្នាប់នៃការគ្រប់គ្រង និង ប្រើប្រាស់ IT, ៣-ការពង្រឹងនូវនិរន្តរភាពនៃប្រតិបត្តិការ IT ។

### ៣.៧.១.រៀបចំប្រព័ន្ធការពារការវាយប្រហារ និង ការជ្រៀតចូលប្រព័ន្ធ IT កសហវ

ប្រព័ន្ធ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មានជាច្រើនត្រូវបានដាក់ឱ្យដំណើរការនៅក្នុង កសហវ ដែលទាមទារឱ្យមានការគិតគូរ និង យកចិត្តទុកដាក់ខ្ពស់ទៅលើការការពារពីការវាយប្រហារ ក្នុងគោលបំណងបង្អាក់ដំណើរការរបស់ប្រព័ន្ធ ឬ ការព្យាយាមចូលលុកលុយដើម្បីលួចទិន្នន័យ ជាដើម ។ ការរៀបចំប្រព័ន្ធការពារពីការវាយប្រហារ និង ការជ្រៀតចូលលួចទិន្នន័យក្នុងប្រព័ន្ធ IT របស់ កសហវ រួមមាន៖

- ធ្វើបច្ចុប្បន្នភាព និង បំពាក់បន្ថែមនូវឧបករណ៍ និង កម្មវិធី IT សម្រាប់ពង្រឹងសន្តិសុខ IT
- ធ្វើតេស្ត និង វាយតម្លៃជាប្រចាំលើចំណុចខ្សោយ, ភាពងាយរងគ្រោះ និង ហានិភ័យ IT
- រៀបចំ និង កសាងបន្ទប់មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ IT

- រៀបចំយន្តការ និង នីតិវិធីក្នុងការឆ្លើយតបទៅនឹងការវាយប្រហារ ឬ ឧប្បត្តិហេតុនានាដែលកើតឡើងមកលើ IT កសហវ
- រៀបចំ និង ដាក់ដំណើរការប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន និង ឧប្បត្តិហេតុ IT (Security Information and Event Management)
- គិតគូររៀបចំ និង ដាក់ដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មតាមដាន, វិភាគ និង ឆ្លើយតបឧប្បត្តិហេតុនៃសន្តិសុខ IT (Security Orchestration, Automation and Response) ។

### ៣.៧.២.បង្កើនសណ្តាប់ធ្នាប់នៃការគ្រប់គ្រង និង ប្រើប្រាស់ IT

ទន្ទឹមនឹងការរៀបចំនូវប្រព័ន្ធការពារ IT, សណ្តាប់ធ្នាប់នៃការប្រើប្រាស់ និង គ្រប់គ្រង IT ក៏គួរតែត្រូវបានបង្កើនបន្ថែម ដើម្បីកាត់បន្ថយនូវហានិភ័យពាក់ព័ន្ធនឹងសន្តិសុខផ្ទៃក្នុង នៃដំណើរការប្រព័ន្ធ IT របស់ កសហវ ផងដែរ ។ ការប្រើប្រាស់ឧបករណ៍ IT ដោយអាណាធិបតេយ្យគឺជាហានិភ័យដ៏ធ្ងន់ធ្ងរ ដែលអាចធ្វើឱ្យបណ្តាញ ឬ ប្រព័ន្ធ IT ទាំងមូលមិនដំណើរការ ឬ ខូចខាតទិន្នន័យ ដែលអាចបណ្តាលមកពីការរាលដាល ឬ វាយលុកនៃមេរោគបច្ចេកវិទ្យាព័ត៌មាន ឬ កម្មវិធីចារកម្មបង្កប់នានា ។ សកម្មភាពសំខាន់ៗមួយចំនួនត្រូវអនុវត្ត ដើម្បីបង្កើននូវសណ្តាប់ធ្នាប់នៃការប្រើប្រាស់ និង គ្រប់គ្រង IT មានដូចខាងក្រោម៖

- រៀបចំ, ធ្វើបច្ចុប្បន្នភាព និង ដាក់ឱ្យអនុវត្តគោលការណ៍ពាក់ព័ន្ធនឹងសន្តិសុខ IT ទូទៅ
- រៀបចំ, ធ្វើបច្ចុប្បន្នភាព និង ដាក់ឱ្យអនុវត្តគោលការណ៍ពង្រឹងប្រព័ន្ធសន្តិសុខ IT សម្រាប់មជ្ឈមណ្ឌលទិន្នន័យ កសហវ
- រៀបចំនីតិវិធីស្តង់ដារក្នុងការគ្រប់គ្រងប្រតិបត្តិការសន្តិសុខ IT
- រៀបចំក្របខណ្ឌចំណាត់ថ្នាក់ទិន្នន័យក្នុងកម្មវត្ថុនៃសន្តិសុខព័ត៌មានឌីជីថល
- រៀបចំ និង អនុវត្តផែនការបញ្ជ្រាបការយល់ដឹងអំពីមូលដ្ឋាននៃសន្តិសុខ IT ជូនដល់មន្ត្រី និង បុគ្គលិកទូទៅ ។

### ៣.៧.៣.ពង្រឹងនិរន្តរភាពនៃប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មាន

ការរៀបចំនូវប្រព័ន្ធការពារសុវត្ថិភាពទិន្នន័យ និង ប្រព័ន្ធ IT រួមទាំងការរៀបចំ និង បង្កើនសណ្តាប់ធ្នាប់នៃការគ្រប់គ្រង និង ប្រើប្រាស់ IT បានផ្តល់នូវកត្តាគន្លឹះមួយចំនួនរួចជាស្រេចក្នុងការធានានូវនិរន្តរភាពនៃប្រតិបត្តិការ IT របស់ កសហវ ។ ដើម្បីពង្រឹងបន្ថែមលើនិរន្តរភាពនៃដំណើរការ IT, សកម្មភាពមួយចំនួនបន្ថែមទៀតត្រូវរៀបចំ និង អនុវត្ត រួមមាន៖

- រៀបចំផែនការពង្រឹងនិរន្តរភាពនៃប្រតិបត្តិការ IT របស់ កសហវ
- រៀបចំ និង អនុវត្តផែនការគ្រប់គ្រង និង ទប់ស្កាត់ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខ IT
- រៀបចំផែនការស្តារគ្រោះមហន្តរាយនៃហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធ IT
- រៀបចំគោលការណ៍ និង វិធានសម្រាប់ដំណើរការប្រព័ន្ធ IT នៅមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ ។

## ៣.៨.អភិវឌ្ឍសមត្ថភាព និង ពង្រឹងការគ្រប់គ្រងធនធានមនុស្សផ្នែក IT

ជាការចាំបាច់បំផុតក្នុងការត្រៀមខ្លួនជាប់ជានិច្ចសម្រាប់ការផ្លាស់ប្តូររបៀបនៃការធ្វើការងារ នៅក្នុងអង្គភាព និង ស្ថាប័ននីមួយៗ ផ្អែកទៅតាមនិន្នាការសាកលនៅក្នុងយុគសម័យឌីជីថល ។ ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សផ្នែក IT និង ឌីជីថល គឺជាកត្តាគន្លឹះដ៏សំខាន់សម្រាប់ត្រៀមខ្លួនក្នុងការផ្លាស់ប្តូរ ដើម្បីបង្កើនសមត្ថភាពក្នុងការគ្រប់គ្រង និង ការប្រតិបត្តិនូវដំណើរការនៃហេដ្ឋារចនាសម្ព័ន្ធ, ប្រព័ន្ធ និង សន្តិសុខបច្ចេកវិទ្យាព័ត៌មាន គាំទ្រដល់ការងាររបស់ កសហវ ដែលរួមមានទាំង ការកសាងធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈផ្នែក IT កម្រិតខ្ពស់ និង ការកសាងសមត្ថភាពកម្រិតមូលដ្ឋានផ្នែក IT និង ឌីជីថលជូនដល់មន្ត្រី និង បុគ្គលិកទូទៅក្នុងការចាប់យកបរិបទការងារថ្មីតាមប្រព័ន្ធឌីជីថល ។ សកម្មភាពគន្លឹះមួយចំនួនត្រូវបានដាក់ចេញគឺ ១-ការកសាងសមត្ថភាពជំនាញវិជ្ជាជីវៈផ្នែក IT ដល់មន្ត្រី និង បុគ្គលិកបច្ចេកទេសផ្នែក IT, ២-ការកសាងសមត្ថភាព IT និង ឌីជីថលកម្រិតមូលដ្ឋានដល់មន្ត្រី និង បុគ្គលិកទូទៅ, និង ៣-ការរៀបចំ និង ពង្រឹងយន្តការគ្រប់គ្រង និង ធានានិរន្តរភាពនៃធនធានមនុស្សផ្នែក IT ។

### ៣.៨.១.កសាងសមត្ថភាពជំនាញវិជ្ជាជីវៈ IT ដល់មន្ត្រី និង បុគ្គលិកបច្ចេកទេសផ្នែក IT

ក្នុងការធានានូវនិរន្តរភាពនៃដំណើរការប្រព័ន្ធ និង ហេដ្ឋារចនាសម្ព័ន្ធ IT គឺចាំបាច់បំផុតត្រូវមានធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈផ្នែក IT គ្រប់គ្រាន់ ។ ផ្អែកលើនិន្នាការនៃការរីកចម្រើនបច្ចេកវិទ្យា IT ពីមួយថ្ងៃទៅថ្ងៃឥតឈប់ឈរ និង យ៉ាងរហ័ស ជំនាញវិជ្ជាជីវៈផ្នែក IT ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំដើម្បីពង្រឹង និង កសាងសមត្ថភាពមន្ត្រី និង បុគ្គលិក ក្នុងការត្រៀមខ្លួនផ្លាស់ប្តូរ ឬ ចាប់យកបច្ចេកវិទ្យាថ្មីៗ រួមទាំងការធ្វើបច្ចុប្បន្នភាពនៃប្រព័ន្ធប្រតិបត្តិការ IT ជាដើម ។ សកម្មភាពមួយចំនួនត្រូវអនុវត្តដើម្បីគាំទ្រដល់សកម្មភាពគន្លឹះនេះ រួមមាន៖

- វាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្នែក IT
- រៀបចំកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំសម្រាប់ជំនាញវិជ្ជាជីវៈផ្នែក IT
- រៀបចំក្របខណ្ឌតម្រូវការជំនាញវិជ្ជាជីវៈ និង តម្រូវការវិញ្ញាបនបត្រជំនាញវិជ្ជាជីវៈ IT ។

### ៣.៨.២.កសាងសមត្ថភាព IT និង ឌីជីថលកម្រិតមូលដ្ឋានដល់មន្ត្រី និង បុគ្គលិកទូទៅ

ទន្ទឹមនឹងការកសាងសមត្ថភាពធនធានមនុស្សជំនាញវិជ្ជាជីវៈផ្នែក IT ការកសាងសមត្ថភាពកម្រិតមូលដ្ឋានជូនដល់មន្ត្រី/បុគ្គលិកទូទៅក៏ត្រូវតែអនុវត្តផងដែរ ដើម្បីគាំទ្រដល់ការអនុវត្តគម្រោង IT នានារបស់ កសហវ ។ ជំនាញ IT កម្រិតមូលដ្ឋានរួមបញ្ចូលនូវ ជំនាញប្រើប្រាស់កុំព្យូទ័រ, ការប្រើប្រាស់កម្មវិធីបម្រើការងារក្នុងការិយាល័យ ( Microsoft Office ), ការប្រើប្រាស់អ៊ីនធឺណិត/អ៊ីមែល ជាដើម ។ សកម្មភាពមួយចំនួនត្រូវបានដាក់ចេញដើម្បីគាំទ្រដល់សកម្មភាពគន្លឹះនេះ រួមមាន៖

- វាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល IT កម្រិតមូលដ្ឋាន
- រៀបចំកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំសម្រាប់ IT កម្រិតមូលដ្ឋាន
- រៀបចំកម្មវិធីបញ្ជ្រាបការយល់ដឹងគន្លឹះៗលើ IT និង ឌីជីថលកម្រិតមូលដ្ឋាន ។

### ៣.៨.៣.រៀបចំ និង ពង្រឹងយន្តការគ្រប់គ្រង និង ធានានិរន្តរភាពធនធានមនុស្សផ្នែក IT

កន្លងមក ធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈ IT កម្រិតខ្ពស់ មានការលំបាកក្នុងការជ្រើសរើស ព្រមទាំងមានភាពផុយស្រួយក្នុងការហូរចេញទៅវិស័យឯកជនវិញ ប្រកបដោយការប្រកួតប្រជែងខ្លាំង ។ បញ្ហាប្រឈមធំបំផុត គឺបៀវត្សប្រចាំខែ និង ការលើកទឹកចិត្តផ្សេងៗរបស់វិស័យសាធារណៈនៅមានកម្រិត បើប្រៀបធៀបនឹងវិស័យឯកជន ។ ធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈផ្នែក IT គួរទទួលបានបៀវត្ស ឬ ការឧបត្ថម្ភមួយសមរម្យដែលអាចប្រកួតប្រជែងក្នុងកម្រិតមួយ ជាមួយវិស័យឯកជន ដោយត្រូវធ្វើការបែងចែកយ៉ាងហ្មត់ចត់ ទៅតាមកម្រិតនៃជំនាញវិជ្ជាជីវៈផ្នែកបច្ចេកទេសគន្លឹះៗ ដើម្បីធានានិរន្តរភាពនៃការងារបច្ចេកទេស ។ សកម្មភាពមួយចំនួនត្រូវអនុវត្ត រួមមាន៖

- រៀបចំផែនការគ្រប់គ្រង និង អភិវឌ្ឍធនធានមនុស្សជំនាញវិជ្ជាជីវៈផ្នែក IT
- រៀបចំផែនការ និង យន្តការផ្តល់ការលើកទឹកចិត្ត និង រង្វាន់សម្រាប់ធនធានមនុស្សជំនាញផ្នែក IT និង ដែលមានស្នាដៃ ។

## ៣.៩.ពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន

វិស័យបច្ចេកវិទ្យាព័ត៌មាន (IT) បានដើរតួនាទីដ៏សកម្ម និង ជាកម្លាំងជំរុញ យ៉ាងសំខាន់នៅក្នុងការចូលរួមចំណែកគាំទ្រដល់ការសម្រេចនូវចក្ខុវិស័យ និង គោលដៅរបស់ កសហវ ។ IT ត្រូវបានចាប់យកមកប្រើប្រាស់ និង វិនិយោគយ៉ាងច្រើនទៅតាមគម្រោង និង តម្រូវការរបស់អគ្គនាយកដ្ឋាន និង អង្គភាពនៅក្រោមឱវាទ កសហវ ដោយប្រើប្រាស់ទាំងថវិកាចរន្ត, ថវិកាមូលធន, ថវិកាអង្គភាពផ្ទាល់ និង ថវិការបស់ដៃគូអភិវឌ្ឍន៍ ។ ប្រការនេះ គឺទាមទារឱ្យមានចាំបាច់នូវការគ្រប់គ្រងមួយច្បាស់លាស់ជាក្របខណ្ឌរួមរបស់ កសហវ លើវិស័យ IT ជាពិសេសប្រសិទ្ធភាពនៃការវិនិយោគដែលចំគោលដៅ និង ចក្ខុវិស័យរបស់ស្ថាប័ន ។

ហេតុនេះ ការពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងលើវិស័យ IT របស់ កសហវ គឺជាគោលដៅដ៏សំខាន់ក្នុងការធានានូវប្រសិទ្ធភាពនៃការប្រើប្រាស់ IT តាមរយៈការអនុវត្តសកម្មភាពគន្លឹះមួយចំនួនគឺ ១-ការរៀបចំក្របខណ្ឌអភិបាលកិច្ចបច្ចេកវិទ្យាព័ត៌មាន, ២-ការបង្កើនប្រសិទ្ធភាពការគ្រប់គ្រងវដ្តអាយុកាល, កិច្ចលទ្ធកម្ម និង ក្រុមហ៊ុនផ្គត់ផ្គង់ ផ្នែក IT និង ៣-ការពង្រឹងលើការគ្រប់គ្រងការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT ។

### ៣.៩.១.រៀបចំក្របខណ្ឌអភិបាលកិច្ចបច្ចេកវិទ្យាព័ត៌មាន

ក្របខណ្ឌអភិបាលកិច្ចបច្ចេកវិទ្យាព័ត៌មាន គ្របដណ្តប់លើការគ្រប់គ្រង, គោលការណ៍, នីតិវិធី និង ស្តង់ដារ, ផែនការយុទ្ធសាស្ត្រ, ហានិភ័យ IT និង គុណភាព IT ។ ការគ្រប់គ្រងការងារ IT បច្ចុប្បន្ន គឺស្ថិតនៅតាមអង្គភាពទទួលបន្ទុក IT នៃអគ្គនាយកដ្ឋានធំៗ និង មួយចំណែកធំនៅនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋាន កសហវ ។ ដើម្បីឱ្យការគ្រប់គ្រងការងារ IT មានភាពប្រសើរឡើង គឺចាំបាច់អនុវត្តសកម្មភាពមួយចំនួន រួមមាន៖

- រៀបចំយន្តការស្ថាប័ន និង បង្កើតក្រុមប្រឹក្សា IT រួម របស់ កសហវ

- រៀបចំគោលការណ៍ក្នុងការគ្រប់គ្រង និង ការផ្តល់សេវា IT ផ្ទៃក្នុង កសហវ
- រៀបចំ និង ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ IT និង ឌីជីថលនៅអង្គភាពនៅក្រោមឱវាទ
- រៀបចំផែនការគ្រប់គ្រងហានិភ័យ IT របស់ កសហវ
- រៀបចំ អនុវត្ត និង ធ្វើបច្ចុប្បន្នភាពគោលការណ៍ នីតិវិធី និង ស្តង់ដារ IT ។

### ៣.៩.២.បង្កើនប្រសិទ្ធភាពការគ្រប់គ្រងវដ្តអាយុកាល, លទ្ធកម្ម និង ក្រុមហ៊ុនផ្គត់ផ្គង់ផ្នែក IT

ឧបករណ៍ និង កម្មវិធី IT ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ នៅគ្រប់អង្គភាពក្រោមឱវាទនៃ កសហវ ក្នុងគោលបំណងផ្សេងៗគ្នា រួមមាន ការប្រើប្រាស់សម្រាប់កិច្ចការងាររដ្ឋបាល, កិច្ចការងារស្រាវជ្រាវ, ការទំនាក់ទំនង, ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាដើម ។ ការទិញឧបករណ៍ និង កម្មវិធី IT កន្លងមកអាចត្រូវបានគ្រោងឡើយដោយអង្គភាពសាមី ឬ ដោយគម្រោងណាមួយ ដោយមិនមានការវាយតម្លៃអំពីស្ថានភាពនៃការប្រើប្រាស់ឧបករណ៍ ឬ កម្មវិធីទាំងនោះនៅឡើយ ដែលអាចបង្កឱ្យមានការវិនិយោគស្ទួន និង ខ្ជះខ្ជាយលើការប្រើប្រាស់ថវិកា ។ បញ្ហានេះ ទាមទារនូវការគិតគូរជាក្របខណ្ឌរួម ក្នុងការវិនិយោគ ឬ ការទិញឧបករណ៍ ឬ កម្មវិធី IT យកមកប្រើប្រាស់ តាមរយៈការដាក់ចេញនូវ សកម្មភាពមួយចំនួនដែលត្រូវអនុវត្ត ដូចខាងក្រោម៖

- សិក្សាវាយតម្លៃលើស្ថានភាពនៃការប្រើប្រាស់ឧបករណ៍ និង កម្មវិធី IT ក្នុង កសហវ
- រៀបចំ និង អនុវត្តផែនការគ្រប់គ្រងបញ្ជីសារពើភណ្ឌ IT រួមរបស់ កសហវ
- រៀបចំវិធាន និង នីតិវិធីក្នុងការវាយតម្លៃកិច្ចលទ្ធកម្មលើឧបករណ៍, កម្មវិធី និង គម្រោង IT
- រៀបចំក្របខណ្ឌរួមលើការប្រើប្រាស់សេវាថែទាំ និង គាំទ្រឧបករណ៍ និង កម្មវិធី IT
- រៀបចំយន្តការសម្រាប់ការទំនាក់ទំនងធ្វើការងារជាមួយក្រុមហ៊ុនផ្គត់ផ្គង់ IT ។

### ៣.៩.៣.គ្រប់គ្រងការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT

ការអនុវត្តប្រព័ន្ធ IT ឬ ប្រព័ន្ធឌីជីថល នឹងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនបណ្តាលមកពីការផ្លាស់ប្តូរបរិបទការងារ ដែលអាចប៉ះពាល់តិចក្តី ច្រើនក្តីទៅលើមន្ត្រី និង ថ្នាក់ដឹកនាំនៃអង្គភាពនីមួយៗ ដែលកំពុងតែបំពេញការងារនៅក្នុងតំបន់សុខស្រួល, ទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗ និង កំពុងតែស្ទាត់ជំនាញនៅក្នុងការងារបច្ចុប្បន្ន ។ ការផ្លាស់ប្តូរដែលអាចនឹងកើតមានឡើងរួមមាន ការកែសម្រួលរចនាសម្ព័ន្ធអង្គភាព, ការកែសម្រួលលក្ខខណ្ឌការងារ, ការកែសម្រួលនីតិវិធីនៃការអនុវត្តការងារ, ការកំណត់តម្រូវការឱ្យមានការបណ្តុះបណ្តាលបន្ថែម ជាដើម ។ ហេតុដូចនេះ ការគ្រប់គ្រងការផ្លាស់ប្តូរត្រូវតែអនុវត្តនូវសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- រៀបចំប្លង់គំរូសម្រាប់ការវិភាគអ្នកពាក់ព័ន្ធនឹងការផ្លាស់ប្តូរ
- រៀបចំប្លង់គំរូសម្រាប់ការវាយតម្លៃលើការត្រៀមលក្ខណៈក្នុងការផ្លាស់ប្តូរ
- រៀបចំប្លង់គំរូសម្រាប់ការវាយតម្លៃលើផលប៉ះពាល់ពីការផ្លាស់ប្តូរ
- រៀបចំប្លង់គំរូសម្រាប់ផែនការកៀរគរការគាំទ្រ និង ទំនាក់ទំនងផ្សព្វផ្សាយពីការផ្លាស់ប្តូរ
- រៀបចំប្លង់គំរូសម្រាប់ផែនការតាមដាន និង ធានានិរន្តរភាពនៃការផ្លាស់ប្តូរ ។

## ៤.ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ

ផែនការមេបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានវិសាលភាពគ្របដណ្តប់ការងារបច្ចេកវិទ្យាព័ត៌មាន និង ការធ្វើឌីជីថលូបនីយកម្ម របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អាចបន្តបញ្ចូលបន្ថែមនូវការងារបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ននានាដែលស្ថិតក្រោមឆត្រនៃការគ្រប់គ្រងរបស់រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុផងដែរ ។ ដើម្បីសម្របសម្រួល និង ជំរុញឱ្យការអនុវត្តផែនការមេនេះដំណើរការដោយរលូន និង សម្រេចបានជោគជ័យ គឺចាំបាច់ត្រូវរៀបចំនូវក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ ដ៏សមស្របមួយ ។

### ៤.១.ការរៀបចំក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួល

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានផ្តល់អាទិភាពទៅលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីជាការរួមចំណែកក្នុងការអភិវឌ្ឍស្ថាប័ន, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង កិច្ចការងារផ្សេងៗទៀត ។ អង្គភាពក្រោមឱវាទ កសហវ មួយចំនួនត្រូវបានបង្កើតឱ្យមាននូវអង្គភាពក្រោមឱវាទរបស់ខ្លួនក្នុងការទទួលបន្ទុកសម្របសម្រួល និង គ្រប់គ្រងការងារបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង ដែលមានទាំងកម្រិតនាយកដ្ឋាន និង កម្រិតការិយាល័យ ។ ហេតុនេះ ការងារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មានក្នុងក្របខណ្ឌរួមរបស់ កសហវ គឺមានលក្ខណៈដាច់ដោយឡែកពីគ្នា, គ្រប់គ្រងតែក្នុងក្របខណ្ឌនៃអង្គភាពរៀងខ្លួន និង មិនមានព័ត៌មានរួមមួយអំពីបច្ចេកវិទ្យាព័ត៌មាន របស់ កសហវ នោះទេ ។

ដើម្បីពង្រឹងសង្គតិភាព, បង្កើននូវភាពប្រទាក់ក្រឡាគ្នា និង បង្កើនកិច្ចសហការស៊ីជម្រៅលើការអនុវត្តការងារបច្ចេកវិទ្យាព័ត៌មាន ប្រកបដោយប្រសិទ្ធភាព និង ភាពរលូន, គឺចាំបាច់ត្រូវបង្កើតឱ្យមាននូវក្របខណ្ឌស្ថាប័នមួយដូចរូបខាងក្រោម៖




**រូបភាពទី ៤.១**: ក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួលការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មាន

<u>ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ</u>: បង្កើតឡើងដើម្បីពង្រឹង និង សម្របសម្រួលការអនុវត្ត ផែនការមេបច្ចេកវិទ្យាព័ត៌មាន ដែលមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាប្រធាន**, រដ្ឋលេខាធិការនៃ កសហវ ជាអនុប្រធាន, រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការដែលទទួលបន្ទុកកិច្ចការងារបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថល ០១ រូប ជាអនុប្រធានប្រចាំការ, អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ជាអនុប្រធាន, និង អនុរដ្ឋលេខាធិការពាក់ព័ន្ធមួយចំនួននៃក្រសួងសដ្ឋកិច្ច និង ហិរញ្ញវត្ថុ, អគ្គលេខាធិការ, អគ្គនាយក, អគ្គាធិការ, ប្រធានអង្គភាព និង នាយកវិទ្យាស្ថាន ជាសមាជិក ។ ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននេះ មានតួនាទី និង ភារកិច្ចដឹកនាំសម្របសម្រួល និង ជំរុញការកសាង និង ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុប្រកបដោយជវភាព, សង្គតិភាព និង សុខដុមភាព សំដៅកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងចូលរួមចំណែកដល់ការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ។

ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ មានក្រុមការងារបច្ចេកទេសមួយដែលជាសេនាធិការនៅក្នុងការបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ជាពិសេសសម្របសម្រួលការងារបច្ចេកទេសនៃបច្ចេកវិទ្យាព័ត៌មានជាមួយនឹងប្រធាននាយកដ្ឋាន ឬ ប្រធានអង្គភាពដែលទទួលបន្ទុកការងារបច្ចេកវិទ្យាព័ត៌មាននៃអង្គភាពក្រោមឱវាទ កសហវ ព្រមទាំង មានលេខាធិការដ្ឋានមួយសម្រាប់ជួយលើកិច្ចការងាររដ្ឋបាល និង បច្ចេកទេស ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។ ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ មានតួនាទី និង ភារកិច្ចដូចតទៅ៖

- កំណត់ចក្ខុវិស័យ និង គោលការណ៍អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ដឹកនាំ និង តម្រង់ទិសលើការរៀបចំផែនការមេ, យុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដើម្បីកសាង និង អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ដឹកនាំ និង ជំរុញការកសាង និង ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ដឹកនាំ និង ជំរុញការកសាង និង ការអភិវឌ្ឍភាពជាអ្នកដឹកនាំ និង អភិបាលកិច្ចឌីជីថលនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សម្រេច និង ដាក់ឱ្យអនុវត្តស្តង់ដារបច្ចេកទេស, ស្តង់ដារសន្តិសុខឌីជីថល, ស្តង់ដារនីតិវិធីប្រតិបត្តិ និង សេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ដឹកនាំ, សម្របសម្រួល និង ដោះស្រាយការងារ និង បញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរអង្គភាពពាក់ព័ន្ធនឹងគម្រោងបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- កៀរគរធនធានហិរញ្ញវត្ថុ, ធនធានបច្ចេកទេស និង ធនធានមនុស្ស ក្នុងបុព្វហេតុអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ពិនិត្យ និង សម្រេចលើការស្នើសុំថវិកាគាំទ្រគម្រោងបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ជំរុញ, លើកទឹកចិត្ត និង គាំទ្រការចូលរួមលើកស្ទួយការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បំពេញតួនាទី និង ភារកិច្ចដទៃទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

<u>**ក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ**</u>: គឺជាសេនាធិការបច្ចេកទេសផ្ទាល់របស់ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ ដែលមានថ្នាក់ដឹកនាំ កសហវ ជារដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ០១ រូប ទទួលបន្ទុកកិច្ចការងារបច្ចេកវិទ្យាព័ត៌មាន ជាប្រធាន, មានប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋាន កសហវ ជាអនុប្រធានប្រចាំការ, ប្រធាននាយកដ្ឋាន ឬ ប្រធានអង្គភាពដែលទទួលបន្ទុកការងារបច្ចេកវិទ្យាព័ត៌មានអគ្គនាយកដ្ឋាន, អគ្គាធិការដ្ឋាន, វិទ្យាស្ថាន, អង្គភាពពាក់ព័ន្ធផ្សេងទៀតក្រោមឆត្រនៃការគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអនុប្រធាន ឬ សមាជិក ។ ក្រុមការងារបច្ចេកទេស នៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ មានតួនាទី និង ភារកិច្ចដូចតទៅ៖

- សម្របសម្រួលលើការងារអនុវត្តផែនការមេ, យុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដើម្បីកសាង និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សហការការងារជាមួយនឹងអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពាក់ព័ន្ធការកសាង និង ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- កសាង, អភិវឌ្ឍ និង គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ថ្នាលឌីជីថលសម្រាប់ការប្រើប្រាស់រួម
- រៀបចំស្តង់ដារបច្ចេកទេស, ស្តង់ដារសន្តិសុខឌីជីថល, ស្តង់ដារនីតិវិធីប្រតិបត្តិ និង សេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ផ្តួចផ្តើម និង កំណត់កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ និង រៀបចំទស្សនកិច្ចសិក្សាទាំងក្នុងប្រទេស និង ក្រៅប្រទេស ដើម្បីទាញយកបទពិសោធន៍ និង ប្រមូលជាតុចូលសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថល
- រៀបចំឱ្យមានការបណ្តុះបណ្តាល, ការពង្រឹងសមត្ថភាព និង ការចែករំលែកចំណេះដឹងទៅលើការអភិវឌ្ឍ, ការប្រតិបត្តិ និង ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថលនានារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រៀបចំផែនការវិនិយោគដើម្បីគាំទ្រដល់ការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថល

- ពិនិត្យ, ពិភាក្សា, វាយតម្លៃ និង ធ្វើអាទិភាពរូបនីយកម្មគម្រោងបច្ចេកវិទ្យាព័ត៌មានដែលបានស្នើក្នុងក្របខណ្ឌការងាររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពនៃថវិកា និង សង្គតិភាពជាមួយផែនការមេបច្ចេកវិទ្យាព័ត៌មាន និង ឱជីថល
- តាមដាន, ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនការមេ, យុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដោយត្រូវរៀបចំរបាយការណ៍ជូនក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បំពេញតួនាទី និង ភារកិច្ចដទៃទៀត តាមការប្រគល់របស់ប្រធានក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

<u>**លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ**</u>: មានភារកិច្ចជាសេនាធិការផ្ទាល់ជូនក្រុមការងារបច្ចេកទេស នៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន កសហវ លើកិច្ចការងាររដ្ឋបាល និង បច្ចេកទេស ជាពិសេស រៀបចំ និង អនុវត្តការងារបច្ចេកវិទ្យាព័ត៌មានមួយចំនួនដែលមានលក្ខណៈជាក្របខណ្ឌរួម និង សម្របសម្រួលក្នុងការបូកសរុបផែនការសកម្មភាព, បូកសរុបរបាយការណ៍វឌ្ឍនភាព និង រៀបចំកិច្ចប្រជុំនានារបស់ក្រុមការងារបច្ចេកទេស និង កិច្ចប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ ។

<u>**នាយកដ្ឋាន ឬ អង្គភាពបច្ចេកវិទ្យាព័ត៌មាន**</u>

បច្ចុប្បន្ន, អគ្គនាយកដ្ឋាន ឬ អង្គភាពក្រោមឱវាទ កសហវ ដែលមានអង្គភាពក្រោមឱវាទរបស់ខ្លួនផ្ទាល់ ទទួលបន្ទុកលើការងារបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង និង ដែលស្ថិតនៅក្នុងកម្រិតជានាយកដ្ឋាន រួមមាន អគ្គលេខាធិការដ្ឋាន កសហវ, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ។ ជាមួយគ្នានេះ, អង្គភាពក្រោមឱវាទ កសហវ មួយចំនួនទៀត ក៏មានអង្គភាពទទួលបន្ទុកការងារបច្ចេកវិទ្យាព័ត៌មានដែរ ដែលមានកម្រិតត្រឹមការិយាល័យ ។ ហេតុនេះ, ប្រធាននាយកដ្ឋាន និង ប្រធានអង្គភាព ទាំងក្នុងកម្រិតនាយកដ្ឋាន និង កម្រិតការិយាល័យ ដែលមានលក្ខខណ្ឌយោងការងារ ទទួលខុសត្រូវលើបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុង គឺអាចក្លាយជាសមាជិក នៃក្រុមការងារបច្ចេកទេស នៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ ។

ដោយឡែក ក្រុមការងារ ឬ គណៈកម្មការមួយចំនួនដែលបានបង្កើតឡើងស្ថិតក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ដែលទទួលបន្ទុកការងារអនុវត្តគម្រោងបច្ចេកវិទ្យាព័ត៌មាននានា, ក៏ត្រូវស្ថិតក្រោមការគ្រប់គ្រង, ត្រួតពិនិត្យ និង សម្របសម្រួលរបស់ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ ផងដែរ ។ បច្ចុប្បន្ន មានគម្រោងបច្ចេកវិទ្យាព័ត៌មានមួយចំនួន ត្រូវបានរៀបចំឱ្យមាននូវក្រុមការងារអន្តរអគ្គនាយកដ្ឋាន ឬ អង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើការសម្របសម្រួល, សហការ និង អនុវត្តគម្រោង រួមមាន ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និង ក្រុមការងារបច្ចេកទេសដើម្បីសម្រួលនីតិវិធីកត់ត្រាចំណូលមិនមែនសារពើពន្ធ (NRMIS) ជាដើម ។

## ៤.២.ការតាមដាន និង វាយតម្លៃការអនុវត្តផែនការមេ IT

### ៤.២.១.ការរៀបចំផែនការសកម្មភាព

ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មាន របស់ កសហវ សម្រេចតាមគោលដៅ ចាំបាច់ត្រូវរៀបចំនូវផែនការសកម្មភាពលម្អិតទៅតាមសកម្មភាពគន្លឹះនៃគោលដៅនីមួយៗ ។ ផែនការសកម្មភាព ត្រូវរៀបចំឡើងដោយរួមមានសមាសធាតុសំខាន់ៗ ដូចជា ការកំណត់គោលដៅ, សកម្មភាពគន្លឹះ ឬ ចង្កោមសកម្មភាព និង សកម្មភាពអនុវត្ត ដោយផ្សារភ្ជាប់ជាមួយនឹងការកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ និង គោលដៅសូចនាករសមិទ្ធកម្មគន្លឹះប្រចាំត្រីមាស និង ប្រចាំឆ្នាំ អនុលោមតាមតារាងម៉ាទ្រីស នៃផែនការសកម្មភាពគន្លឹះនៅក្នុងផែនការមេបច្ចេកវិទ្យាព័ត៌មាន ដូចមាននៅក្នុងឧបសម្ព័ន្ធនៃផែនការមេនេះ ។

ផែនការសកម្មភាពលម្អិត នៃផែនការមេបច្ចេកវិទ្យាព័ត៌មានរបស់ កសហវ ត្រូវរៀបចំប្រកបដោយភាពប្រទាក់ក្រឡាគ្នាជាមួយនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា, ផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យុទ្ធសាស្ត្រនានារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, និង ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្រុមការងារ, អគ្គនាយកដ្ឋាន ឬ អង្គភាពដែលស្ថិតក្រោមឱវាទ កសហវ ត្រូវរៀបចំផែនការសកម្មភាពលម្អិតដែលពាក់ព័ន្ធនឹងការងារបច្ចេកវិទ្យាព័ត៌មានប្រចាំឆ្នាំ រួចបញ្ជូនទៅលេខាធិការដ្ឋាន នៃក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ ដើម្បីធ្វើការត្រួតពិនិត្យ, បូកសរុប និង ដាក់ជូនក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន កសហវ ពិនិត្យ និង សម្រេច ស្របពេលជាមួយគ្នានឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំផងដែរ ។

ដោយឡែក ស្ថាប័នដែលស្ថិតក្រៅរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប៉ុន្តែស្ថិតក្រោមឆត្រនៃការគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលរួមមាន សហគ្រាសសាធារណៈដែលមានលក្ខណៈរដ្ឋបាល, សហគ្រាសសាធារណៈ និង និយតករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នឹងត្រូវធ្វើការពិនិត្យលទ្ធភាពបន្ថែមទៀតអំពីក្របខណ្ឌនៃការគ្រប់គ្រង និង ការអនុវត្តការងារបច្ចេកវិទ្យាព័ត៌មាន ។




**រូបភាពទី ៤.២**: ការរៀបចំផែនការសកម្មភាព, ការតាមដាន និង ការវាយតម្លៃ

### ៤.២.២.ការតាមដាន និង ការវាយតម្លៃ

ការតាមដាន គឺជាដំណើរការដែលមានលក្ខណៈជាប្រព័ន្ធ សម្រាប់អង្កេត និង ត្រួតពិនិត្យលើដំណើរការនៃការអនុវត្តផែនការសកម្មភាព នៅក្នុងក្របខណ្ឌផែនការមេបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានាបានថាការអនុវត្តផែនការសកម្មភាពទាំងនោះ សមស្របតាមការគ្រោង និង ទទួលបានលទ្ធផលតាមគោលដៅដែលបានកំណត់នៅក្នុងត្រីមាស ឬ អាចជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលទាមទារឱ្យមានការដោះស្រាយទាំងកម្រិតក្រុមការងារបច្ចេកទេស និង ទាំងកម្រិតក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ។ ការតាមដាន គឺផ្អែកទៅលើផែនការសកម្មភាពដែលបានគ្រោងនៅក្នុងឆ្នាំ ជាមួយនឹងគោលដៅសូចនាករសមិទ្ធកម្មគន្លឹះប្រចាំត្រីមាសនីមួយៗ ដោយត្រូវអនុវត្តសកម្មភាពចំនួន ២ គឺ ១-ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស បញ្ជូនទៅលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេស, និង ២-ការរៀបចំកិច្ចប្រជុំតាមដាន និង ត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មានប្រចាំត្រីមាសរបស់ក្រុមការងារបច្ចេកទេស ។

<u>**ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស**</u>

ក្រុមការងារ ឬ អង្គភាពទទួលបន្ទុកអនុវត្តការងារពាក់ព័ន្ធនឹង IT ត្រូវអនុវត្តសកម្មភាពឱ្យសម្រេចបានទៅតាមគោលដៅសូចនាករដែលបានដាក់ចេញនៅក្នុងសកម្មភាពនីមួយៗ និង ត្រូវរៀបចំជារបាយ-ការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការ, លើកឡើងបញ្ហាប្រឈម និង សំណើដំណោះស្រាយ នៅរៀងរាល់ត្រីមាស និង បញ្ជូនទៅលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន កសហវ ដើម្បីធ្វើការបូកសរុប និង ត្រួតពិនិត្យ ។ លេខាធិការដ្ឋាន មានភារកិច្ចក្នុងការត្រួតពិនិត្យ, ផ្តល់យោបល់ និង សម្របសម្រួលកិច្ចពិភាក្សាកម្រិតបច្ចេកទេស ទៅលើលទ្ធផលនៃការអនុវត្តផែនការសកម្មភាព ដោយធ្វើការសំយោគជាសេចក្តីសន្និដ្ឋានដើម្បីដាក់ជូនក្រុមការងារបច្ចេកទេសធ្វើការពិនិត្យ និង វាយតម្លៃ និង អាចជាកម្មវត្ថុសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ នៅរៀងរាល់ត្រីមាសផងដែរ ។

<u>**ការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន**</u>

ក្រុមការងារបច្ចេកទេស នៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ ត្រូវរៀបចំកិច្ចប្រជុំតាមដាន និង ត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្តផែនការសកម្មភាពបច្ចេកវិទ្យាព័ត៌មានប្រចាំត្រីមាស នៅរៀងរាល់ខែទី ១ នៃត្រីមាសបន្ទាប់ ដើម្បីពិភាក្សាទៅលើលទ្ធផលនៃគោលដៅសូចនាករសមិទ្ធកម្មគន្លឹះដែលបានដាក់ចេញទៅតាមផែនការសកម្មភាពនីមួយៗដែលបានគ្រោង ដោយផ្អែកលើរបាយការណ៍បូកសរុប និង សេចក្តីសន្និដ្ឋានរបស់លេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាន ។

## ៤.៣.អភិក្រម និង គោលការណ៍អនុវត្ត

ផែនការមេបច្ចេកវិទ្យាព័ត៌មានរបស់ កសហវ ត្រូវចូលរួមសហការអនុវត្តដោយអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសកម្មភាពខ្លះត្រូវអនុវត្តរួម និង សកម្មភាពខ្លះអនុវត្តដោយឡែក ផ្អែកលើ**អភិក្រមប្រមូលផ្តុំខ្លះ ពង្រាយខ្លះ** (Hybrid Decentralized Approach) ដោយហេតុថាអគ្គនាយកដ្ឋានធំៗមួយចំនួននៃ កសហវ មានសមត្ថភាព និង ធនធានមនុស្សគ្រប់គ្រាន់ និង បាន

រៀបចំនូវប្រព័ន្ធ និង ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនធំរួចហើយសម្រាប់គាំទ្រដល់ដំណើរ-ការការងាររបស់ខ្លួន ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋាន និង អង្គភាពក្រោមឱវាទ កសហវ មួយចំនួនធំនៅមិនទាន់មានធនធាន និង សមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំការងារបច្ចេកវិទ្យាព័ត៌មាន ដោយខ្លួនឯងនៅឡើយ, ដែលទាមទារឱ្យមាននូវការសម្របសម្រួល និង ជំនួយផ្នែកបច្ចេកទេសបច្ចេកវិទ្យាព័ត៌មាននេះជាចាំបាច់ ទៅតាមតម្រូវការនៃការធ្វើទំនើបកម្មការគ្រប់គ្រងកិច្ចការងាររបស់ខ្លួន ។ ជាមួយគ្នានេះ ការរៀបចំកម្មវិធីបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់មុខងារស្នូល (Specialized Business Application) និង ការធ្វើឌីជីថលូបនីយកម្មការងារដែលមានលក្ខណៈដោយឡែក ជាពិសេសក្នុងគោលបំណងគាំទ្រដល់ការផ្តល់សេវាសាធារណៈបែបឌីជីថល ត្រូវបានលើកទឹកចិត្តឱ្យមានការគិតគូរ នៅក្នុងអង្គភាពនីមួយៗទៅតាមមុខងារភារកិច្ចរបស់ខ្លួន, ប៉ុន្តែត្រូវស្ថិតនៅក្នុងក្របខណ្ឌនៃការត្រួតពិនិត្យ និង វាយតម្លៃពីក្រុមការងារបច្ចេកទេស នៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន ។ ដោយឡែក ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមមានមជ្ឈមណ្ឌលទិន្នន័យ, ធនធានម៉ាស៊ីនមេ, ធនធានរក្សាទុកទិន្នន័យ, បណ្តាញតភ្ជាប់ ជាដើម និង ប្រព័ន្ធ ឬថ្នាលបច្ចេកវិទ្យាព័ត៌មានរួមមួយចំនួនដែលបម្រើឱ្យការងារដែលមានចរិតលក្ខណៈ និង គោលបំណងរួមនឹងត្រូវតម្រង់ទិសឱ្យមានការរៀបចំជាក្របខណ្ឌរួមរបស់ កសហវ និង ដែលត្រូវសម្របសម្រួលរៀបចំ និងគ្រប់គ្រងដោយលេខាធិការដ្ឋានរបស់ក្រុមការងារបច្ចេកទេស ។

ម្យ៉ាងទៀត ការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មានរបស់ កសហវ គឺអនុលោមតាមអភិក្រម និងគោលការណ៍ដែលមានស្រាប់នៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រួមទាំង នៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ។ អភិក្រមរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺ ១-អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និង គោរពក្រមសីលធម៌វិជ្ជាជីវៈ, ២-អនុវត្តការងារជាក្រុម, ៣-អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និង គោលការណ៍ប្រសិទ្ធភាពថវិកា និង ៤-មិនត្រូវមើលរំលងកំហុសខ្លួនឯង ។

ទន្ទឹមនឹងនេះ នៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ក៏បានដាក់ចេញនូវគោលការណ៍សម្រាប់ការអនុវត្តរដ្ឋាភិបាលឌីជីថល រួមមាន ៣ ចំណុច អាចយកមកប្រើប្រាស់សម្រាប់ជាគោលការណ៍អនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មានរបស់ កសហវ ផងដែរ គឺ ១-គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក (The Only-Once Principle), ២-គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ (Interoperability as an Ecosystem) និង ៣-គោលការណ៍ផ្តួចផ្តើម និង ពង្រីកដើម្បីប្រសិទ្ធភាព (Land and Expand for Efficiency) ។

# ឧបសម្ព័ន្ធទី ១: តារាងសកម្មភាពគន្លឹះ និង លទ្ធផលរំពឹងទុក

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 1 | ពង្រឹង និង បង្កើនសមត្ថភាព និង ស្ថិរភាពនៃហេដ្ឋារចនាសម្ព័ន្ធ និង ធនធាន IT | | | |
| 1.1 | ការផ្តួចផ្តើមក្នុងការរៀបចំសហមជ្ឈមណ្ឌលទិន្នន័យចែករំលែក | | | |
| 1.1.1 | សម្រង់ព័ត៌មានលម្អិតស្តីពីធនធាននៃមជ្ឈមណ្ឌលទិន្ន-ន័យនីមួយៗ | -បញ្ចប់របាយការណ៍លទ្ធផលនៃការបូកសរុបសម្រង់ធនធានលម្អិតរបស់មជ្ឈ-មណ្ឌលទិន្នន័យ នៃ កសហវ<br>-មានឯកសារគោលស្តីអំពីធនធានមជ្ឈ-មណ្ឌលទិន្នន័យ | 2021-2022 | GS-ITD, GDT, GDCE, FMWG, GDs |
| 1.1.2 | រៀបចំក្របខណ្ឌសហមជ្ឈ-មណ្ឌលទិន្នន័យរួមរបស់ កសហវ | មានឯកសារស្តីពីក្របខណ្ឌនៃសហ-មជ្ឈមណ្ឌលទិន្នន័យរួមរបស់ កសហវ | 2022 | GS-ITD |
| 1.1.3 | រៀបចំ និង អនុវត្តការផែន-ការសកម្មភាពសម្រាប់ការរៀបចំសហមជ្ឈមណ្ឌលទិន្នន័យ | -មានផែនការសកម្មភាពនៃការរៀបចំសហមជ្ឈមណ្ឌលទិន្នន័យ<br>-មជ្ឈមណ្ឌលទិន្នន័យទាំងអស់របស់ កសហវ បានតភ្ជាប់គ្នា និង បំពេញធនធានឱ្យគ្នាទៅវិញទៅមកប្រកបដោយភាពប្រទាក់ក្រឡា | 2022-2024 | GS-ITD, GDT, GDCE, FMWG, GDs |
| 1.1.4 | រៀបចំឯកសារទស្សនាទាននៃការរៀបចំសហប្រព័ន្ធប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ (Distributed Computing Data Center) | មានឯកសារទស្សនាទានស្តីពីការរៀបចំសហប្រព័ន្ធប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ ជាគោលសម្រាប់ការរៀបចំផែនការជំហានបន្ទាប់ ២០២៦-២០៣០ | 2025 | GS-ITD |
| 1.2 | បង្កើនធនធានប្រតិបត្តិការមជ្ឈមណ្ឌលទិន្នន័យ, ម៉ាស៊ីនមេ និង ឃ្លាំងផ្ទុកទិន្នន័យ | | | |
| 1.2.1 | អនុវត្តផែនការអភិវឌ្ឍ និង ពង្រីកសមត្ថភាពមជ្ឈមណ្ឌលទិន្នន័យរបស់គម្រោង FMIS | មជ្ឈមណ្ឌលទិន្នន័យគម្រោង FMIS មានសមត្ថភាពកើនឡើងឆ្លើយតបនឹងតម្រូវការសម្រាប់ផែនការពង្រីកការអនុវត្តគម្រោង FMIS គិតត្រឹមឆ្នាំ ២០២៥ ផ្អែកតាមផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី៣ | 2022-2024 | FMWG, GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 1.2.2 | អនុវត្តផែនការអភិវឌ្ឍ និង បង្កើនធនធានមជ្ឈមណ្ឌលទិន្នន័យរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា | មជ្ឈមណ្ឌលទិន្នន័យរបស់អគ្គនាយក-ដ្ឋានគយ និង រដ្ឋាករកម្ពុជាមានសមត្ថ-ភាពកើនឡើង ឆ្លើយតបនឹងតម្រូវការទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មប្រតិបត្តិ-ការគយ និង សហប្រតិបត្តិការគយ ផ្អែកតាមយុទ្ធសាស្ត្របច្ចេកវិទ្យាគមនា-គមន៍ និង ព័ត៌មានរបស់ អគ្គនាយក-ដ្ឋានគយ និង រដ្ឋាករកម្ពុជា | 2021-2024 | GDCE |
| 1.2.3 | អនុវត្តផែនការបង្កើនសមត្ថ-ភាពមជ្ឈមណ្ឌលទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ | មជ្ឈមណ្ឌលទិន្នន័យរបស់អគ្គនាយក-ដ្ឋានពន្ធដារមានសមត្ថភាពកើនឡើង ឆ្លើយតបនឹងតម្រូវការពង្រីកវិសាលភាពនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ | 2021-2024 | GDT |
| 1.2.4 | រៀបចំ និង អនុវត្តផែនការពង្រីកសមត្ថភាព និង ធន-ធានមជ្ឈមណ្ឌលទិន្នន័យរួមរបស់ កសហវ | -មានផែនការពង្រីកសមត្ថភាពធនធានមជ្ឈមណ្ឌលទិន្នន័យរួម កសហវ<br>-មជ្ឈមណ្ឌលទិន្នន័យរួម កសហវ មានសមត្ថភាព និង ធនធានកើនឡើងសម្រាប់ត្រៀមទ្រទ្រង់ដល់តម្រូវការរបស់អង្គភាពក្រោមឱវាទ កសហវ និង អាចផ្តល់នូវធនធានមួយចំនួនសម្រាប់អគ្គនាយកដ្ឋានដែលមិនមានមជ្ឈ-មណ្ឌលទិន្នន័យផ្ទាល់ខ្លួនផងដែរ | 2021-2024 | GS-ITD |
| 1.2.5 | រៀបចំ និង កសាងមជ្ឈ-មណ្ឌលសង្គ្រោះទិន្នន័យរួមសម្រាប់ កសហវ | មានមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យរួមរបស់ កសហវ ដែលនឹងប្រើប្រាស់ជារួមសម្រាប់ផ្គត់ផ្គង់ដល់គ្រប់អង្គភាពក្រោមឱវាទ កសហវ ទាំងអស់ | 2022-2024 | GS-ITD, GDT, GDCE, FMWG |
| **1.3** | **បង្កើនវិសាលភាព និង ភាពងាយស្រួលនៃការតភ្ជាប់ការប្រើប្រាស់ IT** | | | |
| 1.3.1 | សិក្សាវាយតម្លៃ និង រៀបចំនូវទិដ្ឋភាពរួមផ្នែកបច្ចេកទេសនៃបណ្តាញតភ្ជាប់ កសហវ នៅទូទាំងប្រទេស | មានឯកសារស្តីពីទិដ្ឋភាពបច្ចេកទេសនៃបណ្តាញតភ្ជាប់រួម កសហវ ទាំងបច្ចុប្បន្ន និង សំណើថ្មី ដែលទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធ និង សេវា IT នានាដែលរៀបចំដោយ កសហវ ដែល | 2021-2022 | GS-ITD, GDs |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | | រួមមានទាំង បណ្ដាញឆ្អឹងខ្នងខ្សែកាប៊ីអុបទិច បណ្ដាញផ្ទៃក្នុង និងបណ្ដាញអ៊ីនធឺណិត | | |
| 1.3.2 | ត្រួតពិនិត្យ និង ធ្វើការកែលម្អបណ្ដាញតភ្ជាប់ផ្ទៃក្នុងនៃអគារនីមួយៗ | បណ្ដាញតភ្ជាប់ផ្ទៃក្នុងអគារនីមួយៗនៃទីស្ដីការ កសហវ រួមទាំងអង្គភាពក្រោមឱវាទត្រូវបានត្រួតពិនិត្យ, វាយតម្លៃ និង កែលម្អទៅតាមបទដ្ឋានបច្ចេកទេស | 2021-2023 | GS-ITD, GDs |
| 1.3.3 | ពង្រីកបន្ថែមបណ្ដាញតភ្ជាប់ឆ្អឹងខ្នង ទៅកាន់អង្គភាពក្រោមឱវាទ កសហវ និងអង្គភាពរដ្ឋដែលមានការពាក់ព័ន្ធជាមួយ កសហវ | បណ្ដាញតភ្ជាប់ឆ្អឹង កសហវ បានភ្ជាប់ទៅកាន់គ្រប់អង្គភាពក្រោមឱវាទ ទាំងនៅក្នុងរាជធានីភ្នំពេញ និង នៅតាមបណ្ដាខេត្ត | 2021-2025 | GS-ITD, GDs |
| 1.3.4 | រៀបចំ និង អនុវត្តផែនការបង្កើនសមត្ថភាព និង ពង្រីកវិសាលភាពសេវាអ៊ីនធឺណិតរួមរបស់ កសហវ | -មានផែនការបង្កើនសមត្ថភាព និងពង្រីកវិសាលភាពសេវា អ៊ីនធឺណិត<br>-សេវាអ៊ីនធឺណិត កសហវ ត្រូវបានផ្ដល់ទៅកាន់អង្គភាពក្រោម ឱវាទដែលស្ថិតនៅក្រៅទីស្ដីការ កសហវ ជាជំហានៗ | 2021-2025 | GS-ITD |
| 1.3.5 | រៀបចំយន្តការ និង វិធាន នៃការតភ្ជាប់ការប្រើប្រាស់ប្រព័ន្ធ IT កសហវ តាមបណ្ដាញអ៊ីនធឺណិត | មានឯកសារយន្តការ និង វិធានបច្ចេក-ទេសផ្លូវការ សម្រាប់ការតភ្ជាប់ប្រើប្រាស់ប្រព័ន្ធ IT នានារបស់កសហវ តាមបណ្ដាញអ៊ីនធឺណិត | 2021-2023 | GS-ITD, GDT, GDCE, FMWG |
| **1.4** | **ពង្រឹងការគ្រប់គ្រង និង បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍របស់អ្នកប្រើប្រាស់** | | | |
| 1.4.1 | រៀបចំចំណាត់ថ្នាក់ឧបករណ៍ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់អ្នកប្រើប្រាស់ | មានឯកសារគោលស្ដីអំពីការបែងចែកនូវចំណាត់ថ្នាក់កម្មវិធី IT មូលដ្ឋាន និងឧបករណ៍ IT សម្រាប់ដំឡើងជូនមន្ត្រី និង បុគ្គលិក របស់ កសហវ | 2021-2022 | GS-ITD, GDT, GDCE, FMWG |
| 1.4.2 | រៀបចំ និង ដាក់ឱ្យដំណើរការកម្មវិធី IT គ្រប់គ្រងការប្រើប្រាស់ឧបករណ៍អ្នកប្រើ-ប្រាស់ | ឧបករណ៍ IT របស់ កសហវ ដែលប្រើ-ប្រាស់ដោយមន្ត្រី/បុគ្គលិក កសហវ ត្រូវបានភ្ជាប់បញ្ចូលក្នុងក្របខណ្ឌនៃប្រព័ន្ធគ្រប់គ្រងឧបករណ៍រួម កសហវ និង | 2021-2024 | GS-ITD, GDs |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | | អនុវត្តជាជំហានៗតាមគោលការណ៍រួមរបស់ កសហវ ដូចជា ការប្រើប្រាស់កម្មវិធី Active Directory ដែលមានស្រាប់នៅក្នុងប្រព័ន្ធប្រតិបត្តិការមេរបស់ក្រុមហ៊ុន Microsoft ជាដើម | | |
| 1.4.3 | រៀបចំ និង អនុវត្តផែនការបំពាក់កម្មវិធីកម្ចាត់មេរោគ IT នៅលើកុំព្យូទ័រ | -មានផែនការក្នុងការដំឡើងកម្មវិធីកម្ចាត់មេរោគ IT នៅលើម៉ាស៊ីនកុំព្យូទ័រ<br>-កុំព្យូទ័ររបស់ កសហវ ត្រូវបានដំឡើងកម្មវិធីកម្ចាត់មេរោគ IT ជាជំហានៗ | 2021-2025 | GS-ITD, GDs |
| 1.4.4 | រៀបចំ និង អនុវត្តផែនការបំពាក់អាជ្ញាបណ្ណកម្មវិធី IT ដែលប្រើប្រាស់ក្នុង កសហវ | -មានផែនការក្នុងការពង្រីកការបំពាក់អាជ្ញាបណ្ណកម្មវិធី IT នៅលើ ម៉ាស៊ីនកុំព្យូទ័ររបស់ កសហវ<br>-កម្មវិធី IT ដែលប្រើប្រាស់ក្នុងម៉ាស៊ីនកុំព្យូទ័រ កសហវ បានដាក់អាជ្ញាបណ្ណត្រឹមត្រូវជាជំហានៗស្របតាមបទដ្ឋានបច្ចេកទេស | 2021-2025 | GS-ITD, GDs |
| **1.5** | **ផ្តួចផ្តើមក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដសម្រាប់សេវាហេដ្ឋារចនាសម្ព័ន្ធ IT** | | | |
| 1.5.1 | សិក្សាវាយតម្លៃអំពីលទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាក្លោដនៅក្នុង កសហវ | មានរបាយការណ៍លទ្ធផលស្តីអំពីការសិក្សាលទ្ធភាពនៃការប្រើប្រាស់បច្ចេក-វិទ្យាក្លោដនៅក្នុង កសហវ | 2022 | GS-ITD |
| 1.5.2 | រៀបចំក្របខណ្ឌគតិយុត្តក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្លោដប្រទាក់ក្រឡានឹងក្របខណ្ឌថ្នាក់ជាតិ | មានលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាក្លោដដោយមានភាពប្រទាក់ក្រឡាគ្នាជាមួយក្របខណ្ឌថ្នាក់ជាតិ | 2022-2023 | GS-ITD |
| 1.5.3 | រៀបចំ និង អនុវត្តផែនការក្នុងការសាកល្បងប្រើប្រាស់បច្ចេកវិទ្យាក្លោដជាជំហានៗសម្រាប់មជ្ឈមណ្ឌលទិន្នន័យរួម កសហវ | -មានផែនការ ឬ យុទ្ធសាស្ត្រចាប់យកបច្ចេកវិទ្យាក្លោដមកប្រើប្រាស់នៅក្នុងមជ្ឈមណ្ឌលទិន្នន័យរួមរបស់ កសហវ<br>-បច្ចេកវិទ្យាក្លោដត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការជាជំហានៗ | 2022-2025 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 2 | បង្កើនការអភិវឌ្ឍ, នវានុវត្តន៍ និង ពង្រីកការប្រើប្រាស់ប្រព័ន្ធ និង កម្មវិធី IT | | | |
| 2.1 | រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគាំទ្រការងារកែទម្រង់ និង មុខងារស្នូល កសហវ | | | |
| 2.1.1 | ពង្រីកវិសាលភាពនៃការប្រើ-ប្រាស់ និង អភិវឌ្ឍមុខងារថ្មីបន្ថែមក្នុងប្រព័ន្ធ FMIS (ផ្អែកលើផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី៣ ២០២១-២០២៥) | -មុខងារ BP, PR បានពង្រីកការប្រើ-ប្រាស់ជាជំហានៗ រហូតគ្រប់ក្រសួង-ស្ថាប័ន, មន្ទីរ សហវ, រដ្ឋបាលរាជ-ធានី-ខេត្ត, រដ្ឋបាលក្រុង-ខណ្ឌ, និង មន្ទីរជំនាញមួយចំនួន<br>-មុខងារស្នូល FMIS បានពង្រីកការប្រើប្រាស់ទៅការដ្ឋានថ្មី រួមមាន រដ្ឋបាលរាជធានី-ខេត្ត, រដ្ឋបាល ក្រុង-ខណ្ឌ, រដ្ឋបាលស្រុក ២, មន្ទីរជំនាញ ២ នៃរាជធានី-ខេត្តទាំងអស់, គ្រឹះស្ថានសា-ធារណៈលក្ខណៈរដ្ឋបាល ចំនួន ៣០<br>-ដាក់ឱ្យដំណើរការប្រព័ន្ធរបាយការណ៍ការងារឆ្លាតវៃ (Business Intelligent Reports)<br>-បញ្ចប់ការអភិវឌ្ឍមុខងារ ២ ថ្មីបន្ថែមគឺ មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង បញ្ជីសារពើភណ្ឌ<br>-អភិវឌ្ឍមុខងារសន្ទានកម្មជាមួយប្រព័ន្ធផ្សេងៗ | 2021-2025 | FMWG, GS-ITD, GDs, DEFs, PTs |
| 2.1.2 | រៀបចំ និង អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និង ការធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈ (PIMS) ត្រូវបានរៀបចំរួចរាល់ និង ដាក់ឱ្យដំណើរការជាជំហានៗ ដែលចាប់ផ្តើមពីការស្នើគម្រោង រហូតដល់ដំណាក់កាលត្រួតពិនិត្យ និង វាយតម្លៃ (M&E) ចុងក្រោយ ដោយត្រូវធ្វើសន្ទានកម្មផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធ FMIS ដើម្បីបំពេញព័ត៌មានឱ្យគ្នាទៅវិញទៅមកផងដែរ | 2022-2025 | GDB, GDICDM, GDP, FMWG, GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 2.1.3 | ធ្វើសមាហរណកម្មប្រែក្លាយប្រព័ន្ធចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋបច្ចុប្បន្ន ទៅជាមុខងារមួយនៅក្នុងប្រព័ន្ធ FMIS | ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរៀបចំ និង អភិវឌ្ឍរួចរាល់នៅក្នុងមុខងារមួយរបស់ប្រព័ន្ធ FMIS ដោយប្រើប្រាស់ថ្នាល IT រួមជាមួយប្រព័ន្ធ FMIS ស្រប នឹងផែនការជំហានទី៣ នៃគម្រោង FMIS | 2023-2025 | FMWG, GDSPNTR, GS-ITD, GS-AFD |
| 2.1.4 | សិក្សា, រៀបចំ, កសាង និង ដាក់ដំណើរការជាជំហានៗ កម្មវិធីបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងការអនុវត្តថវិកា និង ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់-ក្រោមជាតិ សមាហរណកម្មជាមួយប្រព័ន្ធ FMIS | មានកម្មវិធីបច្ចេកវិទ្យាព័ត៌មាន ដែលអាចប្រើប្រាស់ដោយមន្ត្រីឃុំ ឬ ស្រុក (ជាពិសេសនៅឆ្ងាយពីទីរួមខេត្ត) ជាជំហានៗ ក្នុងការគ្រប់គ្រង និង តាម-ដានការអនុវត្តថវិកា និង ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន | 2021-2025 | FMWG, GDNT, GDSNAF, GS-ITD, PTs |
| 2.1.5 | ពង្រីកវិសាលភាពការប្រើ-ប្រាស់ និង អភិវឌ្ឍមុខងារបន្ថែមលើប្រព័ន្ធស្វ័យប្រវត្តិ-កម្មគយ និង រដ្ឋាករ | ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និង រដ្ឋាករត្រូវបានធ្វើទំនើបកម្ម និង អភិវឌ្ឍមុខ-ងារបន្ថែមរួចរាល់ ដូចមានលម្អិតក្នុងយុទ្ធសាស្ត្រ ICT ២០២០-២០២៤ របស់ អគរ | 2021-2025 | GDCE |
| 2.1.6 | ពង្រីកវិសាលភាពការប្រើ-ប្រាស់ និង អភិវឌ្ឍបន្ថែមមុខងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យពន្ធដារ | -មុខងារស្នូលនៃប្រព័ន្ធពន្ធដារ ត្រូវបានធ្វើបច្ចុប្បន្នភាព និង ទំនើបកម្មបន្ថែម រួមមាន ការចុះបញ្ជីសហគ្រាស, ពន្ធ VAT, ពន្ធលើការផ្ទេរកម្មសិទ្ធិយានយន្ត, សន្លឹកតែមប្រ៊ី, ពន្ធលើអចលនទ្រព្យ, ពន្ធប្រភេទផ្សេងទៀត, ការគ្រប់គ្រងបំណុល, ការទូទាត់ ជាដើម<br>-មុខងារសន្ទានកម្មជាមួយប្រព័ន្ធខាងក្រៅត្រូវបានធ្វើបច្ចុប្បន្នភាព និង អភិ-វឌ្ឍបន្ថែម | 2021-2025 | GDT |
| 2.1.7 | ធ្វើទំនើបកម្ម និង ពង្រីកវិសាលភាពការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | -ប្រព័ន្ធ NRMIS បានពង្រីកការប្រើ-ប្រាស់ទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី- ខេត្ត, រដ្ឋបាលក្រុង- | 2021-2025 | GDSPNTR, GDNT, GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) | ស្រុក-ខណ្ឌ, រដ្ឋបាលឃុំ-សង្កាត់)<br>-ប្រព័ន្ធ NRMIS បានធ្វើទំនើបកម្មជំនាន់ទី ២ រួមទាំងការអភិវឌ្ឍមុខងារថ្មីបន្ថែម រួមមាន ការគ្រប់គ្រងបំណុល និង ការធ្វើសន្ទានកម្មជាមួយប្រព័ន្ធប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ន | | |
| 2.1.8 | ពង្រីកវិសាលភាពការប្រើ-ប្រាស់ និង ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ | ប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានធ្វើបច្ចុប្បន្នភាពជំនាន់ថ្មី និង ពង្រីកការប្រើប្រាស់មុខងារថ្មីៗ | 2021-2025 | GDICDM |
| 2.1.9 | ធ្វើទំនើបកម្មប្រព័ន្ធ IT គ្រប់-គ្រងទិន្នន័យស្ថិតិសេដ្ឋកិច្ច | ប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិសេដ្ឋកិច្ចត្រូវបានធ្វើបច្ចុប្បន្នភាព និង ទំនើបកម្ម | 2021-2025 | GDP, GS-ITD |
| 2.1.10 | រៀបចំឯកសារទស្សនាទាននៃការកសាងប្រព័ន្ធស្វ័យ-ប្រវត្តិកម្មព្យាករណ៍ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច | មានឯកសារទស្សនាទានសម្រាប់ជាមាគ៌ាក្នុងការគិតគូរបន្តរៀបចំ និង អភិ-វឌ្ឍប្រព័ន្ធ IT ជួយដល់ការព្យាករណ៍ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ការងារពាក់ព័ន្ធ | 2023-2025 | GS-ITD, GDP |
| **2.2** | **រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងកិច្ចការបុគ្គលិក, រដ្ឋបាល និង បណ្តុះបណ្តាល** | | | |
| 2.2.1 | ធ្វើទំនើបកម្ម និង ពង្រីកមុខ-ងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យមន្ត្រី និង បុគ្គលិក | -ប្រព័ន្ធគ្រប់គ្រងមន្ត្រី/បុគ្គលិកត្រូវបានធ្វើបច្ចុប្បន្នភាពមុខងារដែលមានស្រាប់ និង អភិវឌ្ឍបន្ថែមមុខងារថ្មី<br>-ប្រព័ន្ធគ្រប់គ្រងមន្ត្រី/បុគ្គលិកបានពង្រីកវិសាលភាពនៃការប្រើប្រាស់ ទៅដល់អង្គភាពក្រោមឱវាទ កសហវ | 2021-2025 | GS-PD, GS-ITD |
| 2.2.2 | រៀបចំ និង អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសកម្មភាព និង សមិទ្ធកម្មការងារ ដោយធ្វើសមាហរណកម្មជាមួយប្រព័ន្ធគ្រប់គ្រងមន្ត្រី និង បុគ្គលិក កសហវ រួមបញ្ចូលនូវមុខងារបេសកកម្ម និង កិច្ចប្រជុំ | ប្រព័ន្ធគ្រប់គ្រងសកម្មភាពការងារ និង សមិទ្ធកម្មការងាររបស់មន្ត្រី/បុគ្គលិក ត្រូវបានសិក្សា, រៀបចំ, អភិវឌ្ឍ និង ដាក់ឱ្យដំណើរការជាជំហានៗ ដែលនឹងផ្តល់ជាមូលដ្ឋានសម្រាប់ការវាយតម្លៃលទ្ធផលការងារ និង ការលើកទឹកចិត្តផ្សេងៗ | 2022-2025 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 2.2.3 | ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលមន្ត្រី និង បុគ្គលិក | មានប្រព័ន្ធ IT សម្រាប់គ្រប់គ្រងទិន្នន័យនៃការបណ្តុះបណ្តាលមន្ត្រី/បុគ្គលិករបស់ កសហវ ត្រូវបានរៀបចំ និង អភិវឌ្ឍរួចរាល់ និង ដាក់ឱ្យដំណើរ-ការជាជំហាន | 2022-2025 | GS-PD, EFI, GS-ITD, GDs |
| 2.2.4 | រៀបចំ និង កសាងប្រព័ន្ធ IT គ្រប់គ្រងឯកសារអេឡិចត្រូ-និក និង រំហូរនៃឯកសារ | មានថ្នាលបច្ចេកវិទ្យាព័ត៌មានរួមមួយសម្រាប់អង្គភាពក្រោមឱវាទ កសហវ ប្រើប្រាស់ក្នុងការគ្រប់គ្រងឯកសារអេ-ឡិចត្រូនិក និង រំហូរនៃឯកសារដែលនឹងកាត់បន្ថយការប្រើប្រាស់ឯកសារជាក្រដាស ចំណេញពេលវេលា និង សម្រួចទៅកាន់ការធ្វើបរិវត្តកម្មឌីជីថលផ្ទៃក្នុង | 2022-2025 | GS-ITD, GDs |
| 2.2.5 | ធ្វើទំនើបកម្មនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិ និង បញ្ជីសារពើភណ្ឌលម្អិតផ្ទៃ-ក្នុង កសហវ សមាហរណ-កម្មជាមួយប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ | -ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង បញ្ជីសារពើភណ្ឌផ្ទៃក្នុង កសហវ ត្រូវបានអភិវឌ្ឍមុខងារបន្ថែម ជាមួយនឹងការពង្រីកវិសាលភាពនៃការប្រើប្រាស់ទៅកាន់ការដ្ឋានផ្សេងៗទៀត<br>-រៀបចំសន្ធានកម្ម ឬ សមាហរណកម្មមុខងារជាមួយប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង បញ្ជីសារពើភណ្ឌថ្នាក់ជាតិ | 2022-2025 | GS-AFD, GS-ITD, GDSPNTR |
| 2.2.6 | បង្កើតកម្មវិធីលើទូរសព្ទដៃ ឬ ឧបករណ៍ឆ្លាតវៃគាំទ្រដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានា | មានកម្មវិធីទូរសព្ទជាច្រើន បង្កើតឡើងបំពាក់នូវមុខងារចាំបាច់មួយចំនួនគាំទ្រដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានាដែលមានស្រាប់របស់ កសហវ | 2021-2025 | GS-ITD, GDT, GDCE, LCS, |
| **2.3** | **រៀបចំ, អភិវឌ្ឍ និង នវានុវត្តប្រព័ន្ធគ្រប់គ្រងការទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការរួម** | | | |
| 2.3.1 | បង្កើនសមត្ថភាពប្រព័ន្ធគ្រប់គ្រងសារអេឡិចត្រូនិក កសហវ និង ពង្រឹងការប្រើ-ប្រាស់សម្រាប់ការទំនាក់ទំនង | -មានប្រព័ន្ធគ្រប់គ្រងសារអេឡិចត្រូនិកផ្ទាល់ខ្លួនរបស់ កសហវ ដំណើរការនៅក្នុងមជ្ឈមណ្ឌលទិន្នន័យ កសហវ ប្រកបដោយភាពទុកចិត្ត និង សុវត្ថិភាព | 2022-2023 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | ការងារផ្លូវការ ( MEF Email ) | -មានគោលការណ៍ និង វិធាននៃការប្រើប្រាស់សារអេឡិចត្រូនិក កសហវ សម្រាប់ការទំនាក់ទំនងផ្លូវការ | | |
| 2.3.2 | រៀបចំ, អភិវឌ្ឍ និង ដាក់ឱ្យដំណើរការប្រព័ន្ធជជែកពិភាក្សាផ្ទៃក្នុង ( Chatting / Forum ) | មានថ្នាលបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់ការជជែកពិភាក្សាការងារផ្ទៃក្នុង កសហវ ( MEF Chat Application ) | 2022-2024 | GS-ITD |
| 2.3.3 | ពង្រីកសមត្ថភាព និង វិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធសន្និសីទវីដេអូ និង សំឡេង ( Voice/Video Conferencing ) | -មានឯកសារក្របខណ្ឌនៃការប្រើប្រាស់ប្រព័ន្ធសន្និសីទវីដេអូ និង សំឡេងរបស់ កសហវ<br>-ប្រព័ន្ធសន្និសីទវីដេអូ និង សំឡេងរបស់ កសហវ ត្រូវបានពង្រីកសមត្ថ-ភាពមុខងារ និង ពង្រីកវិសាលភាពបន្ថែមទៅកាន់ការដ្ឋានដែលជាអង្គភាពក្រោមឱវាទ កសហវ | 2022-2024 | GS-ITD |
| 2.3.4 | រៀបចំ និង ដាក់ឱ្យដំណើរ-ការប្រព័ន្ធគ្រប់គ្រងការចែករំលែក និង ការរក្សាទុកឯក-សារអេឡិចត្រូនិក ( File Store/Sync/Share ) | មានប្រព័ន្ធគ្រប់គ្រង និង រក្សាទុកឯក-សារឌីជីថល និង ការចែករំលែករបស់ កសហវ | 2022-2024 | GS-ITD |
| 2.3.5 | អភិវឌ្ឍ និង ប្រែក្លាយប្រព័ន្ធជំនួយគាំទ្រលើការប្រើប្រាស់ប្រព័ន្ធ FMIS ដែលមានបច្ចុប្បន្នជាប្រព័ន្ធគ្រប់គ្រងការផ្តល់សេវា IT រួមសម្រាប់ កសហវ | អភិវឌ្ឍរួចរាល់នូវប្រព័ន្ធ IT សម្រាប់គាំទ្រការដោះស្រាយបញ្ហានានា និង ការផ្តល់សេវាផ្នែក IT នៅក្នុង កសហវ និង ពង្រីកការដាក់ឱ្យប្រើប្រាស់ផ្លូវការជាជំហានៗ | 2022-2024 | GS-ITD |
| 2.3.6 | អភិវឌ្ឍកម្មវិធីប្រតិទិនអេឡិច-ត្រូនិក កសហវ សមាហរណ-កម្មជាមួយកាលវិភាគការងាររបស់មន្ត្រី និង ក្រុមការងារ | មានកម្មវិធីប្រតិទិនអេឡិចត្រូនិក របស់ កសហវ សម្រាប់ជាជំនួយក្នុងការគ្រប់-គ្រងកាលវិភាគការងាររបស់មន្ត្រីម្នាក់ៗ ផ្សារភ្ជាប់នឹងប្រព័ន្ធគ្រប់គ្រងសកម្មភាពការងារមន្ត្រី | 2022-2024 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| **2.4** | **រៀបចំប្រព័ន្ធអេកូឡូស៊ី និង ពង្រឹងការ ផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** | | | |
| 2.4.1 | រៀបចំក្របខណ្ឌប្រព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ កសហវ រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័នពាក់ព័ន្ធខាងក្រៅ អនុលោមតាមក្របខណ្ឌនៃថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) | មានឯកសារក្របខណ្ឌប្រព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់នៃ កសហវ និង ការភ្ជាប់ជាមួយប្រព័ន្ធខាងក្រៅនានា ស្របតាមក្របខណ្ឌនៃថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា | 2022-2023 | GS-ITD |
| 2.4.2 | រៀបចំនូវវិធាន និង បទដ្ឋានបច្ចេកទេសសម្រាប់ការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ | មានឯកសារស្តីពីវិធានវិធាន និង បទដ្ឋានបច្ចេកទេស នៃការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗ | 2022-2023 | GS-ITD |
| 2.4.3 | រៀបចំ និង អភិវឌ្ឍនូវច្រកផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗរបស់ កសហវ រួម (API Gateway) ជាមួយប្រព័ន្ធខាងក្រៅ | មានច្រកបច្ចេកវិទ្យាព័ត៌មានសម្រាប់ជាគ្រប់គ្រងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យានានារបស់ កសហវ ទាំងប្រព័ន្ធផ្ទៃក្នុង និង ប្រព័ន្ធខាងក្រៅ | 2022-2024 | GS-ITD, GDs |
| **2.5** | **ពង្រឹងការគ្រប់គ្រងលើដំណើរការរៀបចំ, អភិវឌ្ឍ និង កែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** | | | |
| 2.5.1 | រៀបចំក្របខណ្ឌនៃការគ្រប់គ្រងដំណើរការនៃការរៀបចំ និង កសាងកម្មវិធី ឬ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | មានឯកសារស្តីពីក្របខណ្ឌនៃ ដំណើរការរៀបចំ និង កសាងកម្មវិធី ឬ ប្រព័ន្ធ IT នៅក្នុង កសហវ ស្របតាមបទដ្ឋានបច្ចេកទេស (System Development Life Cycle – SDLC) | 2022-2023 | GS-ITD |
| 2.5.2 | រៀបចំវិធាន និង យន្តការក្នុងការគ្រប់គ្រងប្រភពកូដដើម (Source Code) នៃកម្មវិធីបច្ចេកវិទ្យាព័ត៌មាននានារបស់ កសហវ | មានឯកសារស្តីអំពីវិធាន និង យន្តការនៃការគ្រប់គ្រងកូដដើមនៃកម្មវិធី ឬ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗរបស់ កសហវ ទាំងអស់ដែលជាទ្រព្យសម្បត្តិ កសហវ | 2022-2023 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 2.5.3 | ផ្ដួចផ្ដើមក្នុងការប្រើប្រាស់ថ្នាលបច្ចេកវិទ្យាព័ត៌មានរួមក្នុង កសហវ សម្រាប់ការគ្រប់គ្រងវដ្ដនៃដំណើរការនៃការអភិវឌ្ឍ, ការកែលម្អ និង ការដាក់ឱ្យដំណើរការប្រព័ន្ធ IT | មានឯកសារស្រាវជ្រាវស្ដីពីការប្រើប្រាស់កម្មវិធីបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដូចជា DevOps ជាដើម ក្នុងការគាំទ្រដល់ការគ្រប់គ្រងវដ្ដនៃដំណើរការនៃការអភិវឌ្ឍ, ការកែលម្អ និង ការដាក់ឱ្យដំណើរការប្រព័ន្ធ IT និង ដាក់ឱ្យប្រើប្រាស់ផ្លូវការជាជំហានៗ | 2022-2023 | GS-ITD |
| 3 | **ផ្ដួចផ្ដើម និង សហការបង្កើនការផ្ដល់សេវាអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម** | | | |
| 3.1 | **កសាងមូលដ្ឋានគ្រឹះគាំទ្រការផ្ដល់សេវាបែបអេឡិចត្រូនិក និង ការធ្វើឌីជីថលូបនីយកម្ម** | | | |
| 3.1.1 | រៀបចំ និង កសាងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណឌីជីថល កសហវ ផ្សារភ្ជាប់នឹងប្រព័ន្ធគ្រប់គ្រងមន្ត្រី និង បុគ្គលិក របស់ កសហវ និង ថ្នាល CamDigiKey | មានប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណឌីជីថលរបស់មន្ត្រី កសហវ រួម ដែលអាចយកទៅប្រើប្រាស់ជាឈ្មោះគណនីនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋាននៅក្រោមឱវាទ កសហវ ផ្សេងៗគ្នា សម្រាប់សម្គាល់ថាជាមន្ត្រី ឬ បុគ្គលិករបស់ កសហវ ដោយផ្សារភ្ជាប់នឹងការផ្ទៀតផ្ទាត់ជាមួយអត្តសញ្ញាណមន្ត្រីក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រី និង បុគ្គលិក កសហវ ព្រមទាំងពិនិត្យលើលទ្ធភាពនៃការប្រើប្រាស់ថ្នាល CamdigiKey ជាមូលដ្ឋាន | 2022-2024 | GS-ITD |
| 3.1.2 | រៀបចំ និង កសាងថ្នាលបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងគណនីរួមសម្រាប់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់ កសហវ (Single Sign-on) | មានថ្នាលបច្ចេកវិទ្យាព័ត៌មានដែលប្រើប្រាស់គណនីតែមួយ (ទាំងឈ្មោះ និង ពាក្យសម្ងាត់) ក្នុងការប្រើប្រាស់ប្រព័ន្ធ IT ច្រើនរបស់អង្គភាព ដែលនឹងជួយសម្រួលដល់ការលំបាកក្នុងការចងចាំពាក្យសម្ងាត់ ឬ ឈ្មោះគណនី | 2022-2024 | GS-ITD |
| 3.1.3 | រៀបចំឯកសារទស្សនាទាន និង ក្របខណ្ឌគតិយុត្តក្នុងការប្រើប្រាស់ហត្ថលេខាឌីជីថល | - មានឯកសារទស្សនាទានស្ដីអំពីការប្រើប្រាស់ហត្ថលេខាឌីជីថលនៅក្នុង កសហវ ផ្សារភ្ជាប់នឹងប្រព័ន្ធ IT របស់ កសហវ ដើម្បីឈានទៅការធ្វើបរិវត្តកម្ម | 2022-2024 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | | ឌីជីថលក្នុង កសហវ ជាអតិបរមា<br>-មានឯកសារក្របខណ្ឌគតិយុត្តនៅក្នុង កសហវ សម្រាប់ការប្រើប្រាស់ហត្ថលេខាឌីជីថល | | |
| 3.1.4 | រៀបចំ និង កសាងប្រព័ន្ធគ្រប់គ្រងហត្ថលេខាឌីជីថល កសហវ | មានប្រព័ន្ធ IT សម្រាប់គ្រប់គ្រងការប្រើប្រាស់ហត្ថលេខាឌីជីថល ដោយនឹងពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់ ឬផ្សារភ្ជាប់ជាមួយប្រព័ន្ធរបស់ថ្នាក់ជាតិ | 2023-2024 | GS-ITD |
| 3.1.5 | រៀបចំថ្នាលទូទាត់អេឡិចត្រូ-និករួមសម្រាប់ការទូទាត់ជាមួយគណនីទោលរតនា-គារ | មានថ្នាលបច្ចេកវិទ្យាព័ត៌មានរួមសម្រាប់ផ្តល់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកជាមួយគណនីរតនាគារទោល | 2023-2025 | GDNT, GS-ITD |
| 3.1.6 | រៀបចំឯកសារមគ្គុទេសក៍ក្នុងការធ្វើឌីជីថលូបនីយកម្មសម្រាប់អង្គភាពក្រោមឱវាទ កសហវ | មានឯកសារមគ្គុទេសក៍ក្នុងការធ្វើឌីជី-ថលូបនីយកម្មសម្រាប់អង្គភាពក្រោមឱវាទ កសហវ | 2022-2023 | GS-ITD |
| 3.1.7 | បន្តអនុវត្តផែនការយុទ្ធសា-ស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS | នីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ត្រូវបានតម្រង់ទិសទៅកាន់ការអនុវត្តទាំងស្រុងក្នុងប្រព័ន្ធ FMIS ដោយកាត់បន្ថយជំហាននៃនីតិវិធីខាងក្រៅប្រព័ន្ធ និង ឯកសារជាក្រដាសជាជំហានៗ | 2021-2025 | FMWG, GDs |
| 3.1.8 | រៀបចំផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារប្រតិបត្តិការផ្ទៃក្នុង កសហវ | -មានឯកសារផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទៃក្នុង កសហវ តាមប្រព័ន្ធ IT<br>-នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងប្រតិ-បត្តិការផ្ទៃក្នុង កសហវ ត្រូវបានតម្រង់ទិសជាជំហានៗ ទៅកាន់ការអនុវត្តតាមប្រព័ន្ធ IT ដោយនឹងកាត់បន្ថយឯក-សារជាក្រដាស និង ការងារក្រៅប្រព័ន្ធ | 2023-2025 | GS-ITD, GDs |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 3.1.9 | រៀបចំផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារសម្រាប់ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធ IT | -មានឯកសារផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារសម្រាប់ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធ IT<br>-នីតិវិធីអនុវត្តការងារសម្រាប់ការផ្តល់សេវាសាធារណៈត្រូវបានតម្រង់ទិសជាជំហានៗ ទៅកាន់ការអនុវត្តទាំងស្រុងតាមប្រព័ន្ធ IT ដោយនឹងកាត់បន្ថយឯកសារជាក្រដាស និង ការងារក្រៅប្រព័ន្ធ | 2023-2025 | GDs |
| **3.2** | **ផ្តួចផ្តើមក្នុងការបង្កើនការផ្តល់សេវាបែបអេឡិចត្រូនិក** | | | |
| 3.2.1 | ធ្វើបច្ចុប្បន្នភាពបញ្ជីសេវាសាធារណៈរបស់ កសហវ និង វាយតម្លៃលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈតាមបែបអេឡិចត្រូនិក | -មានឯកសារបច្ចុប្បន្នភាពកម្រងសេវាសាធារណៈរបស់ កសហវ<br>-មានរបាយការណ៍វាយតម្លៃស្តីអំពីការប្រើប្រាស់ផ្តល់សេវាតាមប្រព័ន្ធអេឡិច-ត្រូនិក | 2022 | GS-ITD, GDs |
| 3.2.2 | រៀបចំផែនការ និង ផែនទីចង្អុលផ្លូវរួមសម្រាប់ការពង្រីកការផ្តល់សេវាសាធារណៈតាមបែបអេឡិចត្រូនិក | មានឯកសារផែនការពង្រីកការផ្តល់សេវាសាធារណៈរបស់ កសហវ តាមបែបអេឡិចត្រូនិក | 2022-2023 | GS-ITD, GDs |
| 3.2.3 | រៀបចំផតថលអនឡាញ (Online Portal) រួមរបស់ កសហវ សម្រាប់ប្រមូលផ្តុំនូវសេវា សាធារណៈទាំងអស់ដែលអាចផ្តល់តាមបែបអេ-ឡិចត្រូនិក | មានផតថលអនឡាញរួមរបស់ កសហវ សម្រាប់ការផ្តល់សេវាបែបអេឡិចត្រូនិក | 2023-2024 | GS-ITD |
| **3.3** | **រៀបចំអង្គភាពការងារបែបអេឡិចត្រូនិក និង ឌីជីថលគំរូ** | | | |
| 3.3.1 | រៀបចំ, អភិវឌ្ឍ និង ដាក់ឱ្យដំណើរការទម្រង់នៃការស្នើសុំនានាជាអេឡិចត្រូនិក (e-Forms) សម្រាប់ការងារផ្ទៃក្នុង | គ្រប់ទម្រង់សំណើសុំសេវាផ្ទៃក្នុងនានាត្រូវបានប្រើប្រាស់តាមទម្រង់អេឡិច-ត្រូនិក នៅក្នុងប្រព័ន្ធ IT ដោយមិនមានប្រើប្រាស់ឯកសារជាក្រដាសឡើយ | 2023-2025 | GS-ITD, GDs |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 3.3.2 | រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការមុខងាររំហូរការងារផ្ទៃក្នុងអេឡិចត្រូនិកនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងកិច្ចការបុគ្គលិក និង រដ្ឋបាល | រំហូរការងារចាប់ពីការស្នើសុំ រហូតដល់ការអនុម័ត ពាក់ព័ន្ធនឹងកិច្ចការងាររដ្ឋបាល និង បុគ្គលិក ត្រូវបានរៀបចំរួចរាល់ និង ដាក់ដំណើរការជាដំណាក់កាលៗនៅក្នុងប្រព័ន្ធ IT ដោយមិនមានការបញ្ជូនឯកសារពីកន្លែងមួយទៅកន្លែងមួយទៀតឡើយ | 2023-2025 | GS-ITD, GDs |
| 3.3.3 | រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការថ្នាលបណ្តុះបណ្តាលអេឡិចត្រូនិក | មានថ្នាលបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគាំទ្រដល់ការរៀបចំការបណ្តុះបណ្តាលតាមអនឡាញ | 2022-2024 | EFI, GS-PD, GS-ITD |
| 3.3.4 | រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការបណ្ណាល័យអេឡិចត្រូនិក កសហវ ( e-Library ) | មានបណ្ណាល័យអេឡិចត្រូនិក កសហវ សម្រាប់មន្ត្រី និង បុគ្គលិក ប្រើប្រាស់ក្នុងន័យសិក្សា និង ស្រាវជ្រាវឯកសារ និង ព័ត៌មាននានាពាក់ព័ន្ធនឹងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | 2022-2023 | GS-ITD, EFI, GS-AD |
| 3.3.5 | រៀបចំ, អភិវឌ្ឍ និង ដាក់ដំណើរការផតថលអនឡាញ កសហវ រួមសម្រាប់ប្រតិបត្តិការ និង ការងារផ្ទៃក្នុង | មានផតថលអនឡាញរួមរបស់ កសហវ សម្រាប់ដំណើរការការងារផ្ទៃក្នុង ដូចជាការងាររដ្ឋបាល, ការងារបុគ្គលិក និង ការទំនាក់ទំនង ជាដើម | 2023-2024 | GS-ITD |
| **3.4** | **ចាប់យកនិន្នាការបច្ចេកវិទ្យាព័ត៌មានថ្មីៗ គាំទ្រដល់ការធ្វើឌីជីថលូបនីយកម្ម** | | | |
| 3.4.1 | រៀបចំឯកសារទស្សនាទានស្តីពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ គាំទ្រដល់ ការអភិវឌ្ឍ កសហវ នៅក្នុងផ្នែកឌីជីថល | មានឯកសារទស្សនាទានអំពីការប្រើប្រាស់បច្ចេកវិទ្យាទិន្នន័យធំ ( Big Data ), វិទ្យាសាស្ត្រទិន្នន័យ ( Data Science ), បញ្ញាសប្បនិម្មិត ( AI ), បច្ចេកវិទ្យាក្លោដ ( Cloud Technology ) សម្រាប់ជាប្រយោជន៍នៅក្នុងការធ្វើឱ្យប្រសើរឡើងនូវកិច្ចដំណើរការការងាររបស់ កសហវ | 2023 | GS-ITD |
| 3.4.2 | ស្រាវជ្រាវទៅលើបច្ចេកវិទ្យាឌីជីថលថ្មីៗ ដែលអាចផ្តល់ជាប្រយោជន៍នៃការប្រែក្លាយ | មានរបាយការណ៍ស្តីអំពីលទ្ធផលនៃការស្រាវជ្រាវផ្នែកបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថល ដែលអាចយកមកប្រើប្រាស់ជា | 2022-2025 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | ការងារបែបឌីជីថល | ប្រយោជន៍សម្រាប់ការធ្វើបរិវត្តកម្មឌីជីថល ឬ កាធ្វើឌីជីថលូបនីយកម្មនានា នៅក្នុង កសហវ | | |
| 4 | ពង្រឹងប្រព័ន្ធសន្តិសុខព័ត៌មាន និង ធានានិរន្តរភាពប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មាន | | | |
| 4.1 | រៀបចំប្រព័ន្ធការពារការវាយប្រហារ និង ការជ្រៀតចូលប្រព័ន្ធ IT កសហវ | | | |
| 4.1.1 | ធ្វើបច្ចុប្បន្នភាព និង បំពាក់បន្ថែមនូវឧបករណ៍ និង កម្មវិធី IT សម្រាប់ពង្រឹងសន្តិសុខបច្ចេកវិទ្យាព័ត៌មាន | ហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធ IT ត្រូវបានពង្រឹងបន្ថែមលើប្រព័ន្ធសន្តិសុខ | 2022-2025 | GS-ITD, GDT, GDCE, FMWG |
| 4.1.2 | ធ្វើតេស្ត និង ធ្វើការវាយតម្លៃជាប្រចាំលើចំណុចខ្សោយ, ភាពងាយរងគ្រោះ និង ហានិភ័យ IT | មានរបាយការណ៍វាយតម្លៃអំពីចំណុចខ្សោយ, ភាពងាយរងគ្រោះ និង ហានិភ័យនានា នៃហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធ IT របស់ កសហវ យ៉ាងតិច ១ ឆ្នាំម្តង | 2022-2025 | GS-ITD, GDT, GDCE, FMWG |
| 4.1.3 | រៀបចំ និង កសាងបន្ទប់មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ IT | មានបន្ទប់មជ្ឈមណ្ឌលប្រតិបត្តិការផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រង និង តាមដានការងារសន្តិសុខ IT | 2022-2025 | GS-ITD, GDT, GDCE, FMWG |
| 4.1.4 | រៀបចំយន្តការ និង នីតិវិធីក្នុងការឆ្លើយតបទៅនឹងការវាយប្រហារ ឬ ឧប្បត្តិហេតុនានាកើតឡើងមកលើ IT កសហវ | មានឯកសារស្តីពីយន្តការ និង នីតិវិធីឆ្លើយតបនឹងការវាយប្រហារ ឬ ឧប្បត្តិហេតុនានាដែលកើតមានឡើងលើហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធ IT នានា របស់ កសហវ | 2022-2025 | GS-ITD, GDT, GDCE, FMWG |
| 4.1.5 | រៀបចំ និង ដាក់ដំណើរការប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន និង ឧប្បត្តិហេតុ IT (Security Information and Event Management) | មានប្រព័ន្ធ IT ដែលដំណើរការសម្រាប់ការផ្តល់ដំណឹង និង ប្រមូលព័ត៌មានពាក់ព័ន្ធនឹងហានិភ័យនៃសន្តិសុខព័ត៌មាន និង ឧប្បត្តិហេតុ IT ដើម្បីផ្តល់មូលដ្ឋានដល់ក្រុមការងារសន្តិសុខ IT ធ្វើការការពារ និង ឆ្លើយតបការវាយប្រហារទាន់ពេលវេលា | 2023-2025 | GS-ITD, GDT, GDCE, FMWG |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 4.1.6 | គិតគូររៀបចំ និង ដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មតាមដាន, វិភាគ និង ឆ្លើយតបឧប្បត្តិហេតុនៃសន្តិសុខ IT ( Security Orchestra-tion, Automation and Response ) | មានប្រព័ន្ធ IT ដំណើរការសម្រាប់ផ្តល់ការវិភាគ និង ការកំណត់រំហូរនៃការឆ្លើយតបលើការវាយប្រហារ និង ឧប្បត្តិហេតុ IT ដោយស្វ័យប្រវត្តិ ពាក់ព័ន្ធនឹងសន្តិសុខ IT | 2023-2025 | GS-ITD, GDT, GDCE, FMWG |
| **4.2** | **បង្កើនសណ្តាប់ធ្នាប់នៃការគ្រប់គ្រង និង ប្រើប្រាស់ IT** | | | |
| 4.2.1 | រៀបចំ, ធ្វើបច្ចុប្បន្នភាព និង ដាក់អនុវត្តគោលការណ៍ពាក់ព័ន្ធនឹងសន្តិសុខ IT ទូទៅ | ឯកសារគោលការណ៍នានាពាក់ព័ន្ធនឹងសន្តិសុខ IT របស់ កសហវ ត្រូវបានរៀបចំ និង ធ្វើបច្ចុប្បន្នភាព ព្រមទាំងជំរុញការអនុវត្តជាជំហានៗ | 2022-2025 | GS-ITD, GDT, GDCE, FMWG, GDIA |
| 4.2.2 | រៀបចំ, ធ្វើបច្ចុប្បន្នភាព និង ដាក់អនុវត្តគោលការណ៍ពង្រឹងប្រព័ន្ធសន្តិសុខ IT សម្រាប់មជ្ឈមណ្ឌលទិន្នន័យ កសហវ | ឯកសារគោលការណ៍ពង្រឹងប្រព័ន្ធសន្តិសុខមជ្ឈមណ្ឌលទិន្នន័យ កសហវ ត្រូវបានរៀបចំ និង ធ្វើបច្ចុប្បន្នភាពរួចរាល់ និង ជំរុញការអនុវត្តជំហានៗ | 2022-2025 | GS-ITD, GDT, GDCE, FMWG, GDIA |
| 4.2.3 | រៀបចំនីតិវិធីស្តង់ដារក្នុងការគ្រប់គ្រងប្រតិបត្តិការសន្តិសុខ IT | មានឯកសារនីតិវិធីស្តង់ដារក្នុងការអនុវត្តប្រតិបត្តិការការងារសន្តិសុខ IT នៅក្នុង កសហវ | 2023-2024 | GS-ITD, GDT, GDCE, FMWG, GDIA |
| 4.2.4 | រៀបចំក្របខណ្ឌចំណាត់ថ្នាក់ទិន្នន័យក្នុងកម្មវត្ថុនៃសន្តិសុខព័ត៌មានឌីជីថល | មានឯកសារស្តីពីក្របខណ្ឌនៃចំណាត់ថ្នាក់ទិន្នន័យឌីជីថល សម្រាប់ផ្តល់ជាមូលដ្ឋានក្នុងគិតគូរកម្រិតអាទិភាពនៃសន្តិសុខព័ត៌មានទៅតាមចំណាត់ថ្នាក់នីមួយៗ | 2022-2023 | GS-ITD, GDIA |
| 4.2.5 | រៀបចំ និង អនុវត្តផែនការបញ្ជ្រាបការយល់ដឹងអំពីមូលដ្ឋាននៃសន្តិសុខ IT ជូនដល់មន្ត្រី និង បុគ្គលិកទូទៅ | មន្ត្រី និង បុគ្គលិក កសហវ បានទទួលនូវព័ត៌មានបញ្ជ្រាបការយល់ដឹងអំពីសន្តិសុខព័ត៌មាន ជាមូលដ្ឋានក្នុងការការពារលើការវាយប្រហារ ឬ ការបន្លំ | 2022-2025 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | | លួចទិន្នន័យផ្សេងៗ | | |
| 4.3 | ពង្រឹងនិរន្តរភាពនៃប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មាន | | | |
| 4.3.1 | រៀបចំផែនការក្នុងការពង្រឹងនិរន្តរភាពនៃប្រតិបត្តិការ IT របស់ កសហវ | មានឯកសារផែនការពង្រឹងនិរន្តរភាពនៃដំណើរការហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធ IT ក្នុង កសហវ | 2022-2023 | GS-ITD, GDT, GDCE, FMWG, GDIA |
| 4.3.2 | រៀបចំ និង អនុវត្តផែនការគ្រប់គ្រង និង ទប់ស្កាត់ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខ IT | មានឯកសារផែនការគ្រប់គ្រង និង ទប់ស្កាត់ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខ IT និង ជំរុញការអនុវត្តជាជំហានៗ | 2022-2023 | GS-ITD, GDIA, GDT, GDCE, FMWG |
| 4.3.3 | រៀបចំផែនការស្តារគ្រោះមហន្តរាយនៃហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធ IT | មានឯកសារផែនការស្តារគ្រោះមហន្តរាយនៃហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធ IT របស់ កសហវ ដែលអាចអនុវត្តបានក្នុងពេលមានបញ្ហានៅមជ្ឈមណ្ឌលមេ ឬ បណ្តាញតភ្ជាប់មេ | 2022-2023 | GS-ITD, GDIA, GDT, GDCE, FMWG |
| 4.3.4 | រៀបចំគោលការណ៍ និង វិធានសម្រាប់ដាក់ឱ្យដំណើរការប្រព័ន្ធ IT នៅមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ | មានឯកសារគោលការណ៍ និង វិធានសម្រាប់ដាក់ឱ្យដំណើរការប្រព័ន្ធ IT នៅមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ | 2022-2023 | GS-ITD, GDIA, GDT, GDCE, FMWG |
| 5 | អភិវឌ្ឍសមត្ថភាព និង ពង្រឹងការគ្រប់គ្រងធនធានមនុស្សផ្នែក IT | | | |
| 5.1 | កសាងសមត្ថភាពជំនាញវិជ្ជាជីវៈ IT ដល់មន្ត្រី និង បុគ្គលិកបច្ចេកទេសផ្នែក IT | | | |
| 5.1.1 | វាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្នែក IT | មានរបាយការណ៍ស្តីពីតម្រូវការនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្នែក IT ដើម្បីគាំទ្រដល់ដំណើរការការងារ និង ការធ្វើទំនើបកម្មការងាររបស់ កសហវ | 2022-2025 | GS-ITD |
| 5.1.2 | រៀបចំកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំសម្រាប់ជំនាញវិជ្ជាជីវៈផ្នែក IT | មន្ត្រី និង បុគ្គលិក កសហវ ដែលមានជំនាញ IT ត្រូវបានទទួលបានការបណ្តុះបណ្តាលជាប្រចាំឆ្នាំ ដើម្បីពង្រឹង និង ពង្រីកសមត្ថភាពជំនាញគាំទ្រដល់ការអភិវឌ្ឍស្ថាប័ន | 2022-2025 | GS-ITD |
| 5.1.3 | រៀបចំក្របខណ្ឌតម្រូវការ | មានឯកសារក្របខណ្ឌតម្រូវការជំនាញ | 2022- | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | ជំនាញវិជ្ជាជីវៈ និង តម្រូវការវិញ្ញាបនបត្រជំនាញវិជ្ជាជីវៈ IT | វិជ្ជាជីវៈ IT សម្រាប់គាំទ្រដល់ផែនការនិរន្តរភាពនៃដំណើរការគ្រប់គ្រង និង ធ្វើប្រតិបត្តិការការងារ IT របស់ កសហវ | 2023 | |
| **5.2** | **កសាងសមត្ថភាព IT និង ឌីជីថលកម្រិតមូលដ្ឋានដល់មន្ត្រី និង បុគ្គលិកទូទៅ** | | | |
| 5.2.1 | វាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល IT កម្រិតមូលដ្ឋាន | មានឯកសារលទ្ធផលនៃការវាយតម្លៃលើតម្រូវការនៃការបណ្តុះបណ្តាលជំនាញ IT មូលដ្ឋានទូទៅសម្រាប់គាំទ្រដល់ការងារប្រចាំថ្ងៃរបស់មន្ត្រី និង បុគ្គលិក កសហវ | 2022-2025 | EFI, GS-PD, GS-ITD |
| 5.2.2 | រៀបចំកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំសម្រាប់ IT កម្រិតមូលដ្ឋាន | មន្ត្រី និង បុគ្គលិក កសហវ ទទួលបានចំណេះដឹងជាមូលដ្ឋានលើ IT | 2022-2025 | GS-ITD, EFI |
| 5.2.3 | រៀបចំកម្មវិធីបញ្ជ្រាបការយល់ដឹងគន្លឹះៗលើ IT និង ឌីជីថលកម្រិតមូលដ្ឋាន | មន្ត្រី និង បុគ្គលិក កសហវ ទទួលបានចំណេះដឹងជាមូលដ្ឋានលើ IT | 2022-2025 | GS-ITD, EFI |
| **5.3** | **រៀបចំ និង ពង្រឹងយន្តការគ្រប់គ្រង និង ធានានិរន្តរភាពធនធានមនុស្សផ្នែក IT** | | | |
| 5.3.1 | រៀបចំផែនការគ្រប់គ្រង និង អភិវឌ្ឍធនធានមនុស្សជំនាញវិជ្ជាជីវៈផ្នែក IT | មានឯកសារផែនការសម្រាប់ការគ្រប់-គ្រង និង អភិវឌ្ឍធនធានមនុស្សជំនាញវិជ្ជាជីវៈរួម ផ្នែក IT របស់ កសហវ | 2022-2023 | GS-ITD, GDs |
| 5.3.2 | រៀបចំផែនការ និង យន្តការផ្តល់ការលើកទឹកចិត្ត និង រង្វាន់សម្រាប់ធនធានមនុស្សជំនាញផ្នែក IT និង ដែលមានស្នាដៃ | មានឯកសារផែនការ និង យន្តការផ្តល់ការលើកទឹកចិត្ត និង រង្វាន់សម្រាប់ធនធានមនុស្សផ្នែក IT ដែលមានស្នាដៃ និង ធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈជាន់ខ្ពស់ | 2022-2023 | GS-ITD, GDs |
| **6** | **ពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន** | | | |
| **6.1** | **រៀបចំក្របខណ្ឌអភិបាលកិច្ចបច្ចេកវិទ្យាព័ត៌មាន** | | | |
| 6.1.1 | រៀបចំយន្តការស្ថាប័ន និង បង្កើតក្រុមប្រឹក្សា IT រួម របស់ កសហវ | ក្រុមប្រឹក្សា IT របស់ កសហវ ត្រូវបានរៀបចំរួចរាល់ | 2021 | GDs |
| 6.1.2 | រៀបចំគោលការណ៍ក្នុងការគ្រប់គ្រង និង ការផ្តល់សេវា | មានឯកសារគោលការណ៍នានាស្តីពីការគ្រប់គ្រង និង ផ្តល់សេវាផ្នែក IT នៅក្នុង | 2022-2023 | GS-ITD, GDs |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| | IT ផ្ទៃក្នុង កសហវ | កសហវ | | |
| 6.1.3 | រៀបចំ និង ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ IT និង ឌីជីថលនៅអង្គភាពនៅក្រោមឱវាទ | មានឯកសារផែនការយុទ្ធសាស្ត្រ IT និង ឌីជីថល នៅតាម អង្គភាពនីមួយៗ នៃ កសហវ | 2022-2025 | GDs |
| 6.1.4 | រៀបចំផែនការគ្រប់គ្រងហានិភ័យ IT របស់ កសហវ | មានផែនការគ្រប់គ្រងហានិភ័យ IT របស់ កសហវ | 2022-2023 | GS-ITD, GDT, GDCE, FMWG, GDIA |
| 6.1.5 | រៀបចំ អនុវត្ត និង ធ្វើបច្ចុប្បន្នភាពគោលការណ៍ នីតិវិធី និង ស្តង់ដារ IT | មានឯកសារគោលការណ៍, នីតិវិធីអនុ-វត្ត និង ស្តង់ដារ IT របស់ កសហវ សម្រាប់អនុវត្តក្នុងក្របខណ្ឌរួម | 2022-2025 | GS-ITD, GDT, GDCE, FMWG, GDIA |
| 6.2 | បង្កើនប្រសិទ្ធភាពការគ្រប់គ្រងវដ្តអាយុកាល, លទ្ធកម្ម និង ក្រុមហ៊ុនផ្គត់ផ្គង់ផ្នែក IT | | | |
| 6.2.1 | សិក្សាវាយតម្លៃស្ថានភាពនៃការប្រើប្រាស់ឧបករណ៍ និង កម្មវិធី IT ក្នុង កសហវ | មានរបាយការណ៍ស្តីអំពីការប្រើប្រាស់ឧបករណ៍ និង កម្មវិធី IT នៅក្នុងក្រប-ខណ្ឌ កសហវ | 2021-2022 | GS-ITD |
| 6.2.2 | រៀបចំ និង អនុវត្តផែនការគ្រប់គ្រងបញ្ជីសារពើភណ្ឌ IT រួមរបស់ កសហវ | មានផែនការសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌនៃឧបករណ៍ និង កម្មវិធី IT រួម របស់ កសហវ ដោយនឹងប្រទាក់-ក្រឡាជាមួយប្រព័ន្ធគ្រប់គ្រងបញ្ជីសារ-ពើភណ្ឌរួមរបស់ កសហវ | 2021-2022 | GS-ITD, GS-AFD |
| 6.2.3 | រៀបចំវិធាន និង នីតិវិធីក្នុងការវាយតម្លៃកិច្ចលទ្ធកម្មលើឧបករណ៍, កម្មវិធី និង គម្រោង IT | មានឯកសារក្របខណ្ឌគតិយុត្តក្នុងការគ្រប់គ្រង សម្របសម្រួល និង វាយតម្លៃលើការដេញថ្លៃ/លទ្ធកម្មនៃឧបករណ៍ កម្មវិធី និង គម្រោង IT រួមក្នុង កសហវ | 2021-2022 | GS-ITD |
| 6.2.4 | រៀបចំក្របខណ្ឌរួមលើការប្រើប្រាស់សេវាថែទាំ និង គាំទ្រឧបករណ៍ និង កម្មវិធី IT | មានឯកសារក្របខណ្ឌរួមនៃឧបករណ៍ និង កម្មវិធី IT រួមរបស់ កសហវ ដែលចាំបាច់ត្រូវការនូវការថែទាំ និង គាំទ្រផ្នែកបច្ចេកទេស | 2021-2022 | GS-ITD |

| ល.រ | គោលដៅ/សកម្មភាពគន្លឹះ | លទ្ធផល | ឆ្នាំអនុវត្ត | អង្គភាព |
|---|---|---|---|---|
| 6.2.5 | រៀបចំយន្តការសម្រាប់ការទំនាក់ទំនងធ្វើការងារជាមួយក្រុមហ៊ុនផ្គត់ផ្គង់ IT | មានគោលការណ៍ណែនាំស្តីអំពីយន្តការនៃការទំនាក់ទំនងធ្វើការងារជាមួយក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍ និង កម្មវិធី IT ដែលប្រើប្រាស់ដោយ កសហវ | 2022 | GS-ITD |
| 6.3 | គ្រប់គ្រងការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT | | | |
| 6.3.1 | រៀបចំប្លង់គំរូសម្រាប់ការវិភាគអ្នកពាក់ព័ន្ធនឹងការផ្លាស់ប្តូរ ( Stakeholders Analysis ) | មានឯកសារប្លង់គោលជាគំរូសម្រាប់ធ្វើការវិភាគអ្នកពាក់ព័ន្ធនឹងការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT | 2021-2022 | GS-ITD |
| 6.3.2 | រៀបចំប្លង់គំរូសម្រាប់ការវាយតម្លៃលើការត្រៀមលក្ខណៈក្នុងការផ្លាស់ប្តូរ ( Change Readiness Assessment ) | មានឯកសារប្លង់គោលជាគំរូសម្រាប់ធ្វើការវាយតម្លៃលើការត្រៀមលក្ខណៈក្នុងការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT | 2021-2022 | GS-ITD |
| 6.3.3 | រៀបចំប្លង់គំរូសម្រាប់ការវាយតម្លៃលើផលប៉ះពាល់ពីការផ្លាស់ប្តូរ ( Impact Assessment ) | មានឯកសារប្លង់គោលជាគំរូសម្រាប់ធ្វើការវាយតម្លៃលើការផលប៉ះពាល់ ( បច្ច័យ ) ពីការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT | 2021-2022 | GS-ITD |
| 6.3.4 | រៀបចំប្លង់គំរូសម្រាប់ផែនការកៀរគរការគាំទ្រ និង ទំនាក់-ទំនងផ្សព្វផ្សាយពីការផ្លាស់-ប្តូរ ( Communication and Engagement Plan ) | មានឯកសារប្លង់គោលជាគំរូសម្រាប់រៀបចំផែនការកៀរគរការគាំទ្រ និង ទំនាក់ទំនងផ្សព្វផ្សាយពីការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT | 2021-2022 | GS-ITD |
| 6.3.5 | រៀបចំប្លង់គំរូសម្រាប់ផែនការតាមដាន និង ធានានិរន្តរ-ភាពនៃការផ្លាស់ប្តូរ | មានឯកសារប្លង់គោលជាគំរូសម្រាប់រៀបចំផែនការតាមដាន និង ធានានិរន្តរភាពនៃការផ្លាស់ប្តូរដោយសារការអនុវត្តគម្រោង IT | 2022-2023 | GS-ITD |

## ឧបសម្ព័ន្ធទី ២: បញ្ជីសេវាសាធារណៈរបស់ គសហវ ឆ្នាំ ២០២០

| ល.រ | ឈ្មោះសេវា | ប្រព័ន្ធ IT |
|---|---|---|
| I | **អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ** | |
| 1 | សេវាចុះបញ្ជីអ្នកដេញថ្លៃទទួលសាងសង់-លើកដំបូង | មិនមាន |
| 2 | សេវាចុះបញ្ជីអ្នកដេញថ្លៃទទួលសាងសង់-បន្ត | មិនមាន |
| 3 | សេវាសុំដំឡើងឋានៈប្រភេទអ្នកដេញថ្លៃទទួលសាងសង់ | មិនមាន |
| 4 | សេវាបន្ថែមឈ្មោះចំណាត់ថ្នាក់សម្រាប់អ្នកដេញថ្លៃទទួលសាងសង់ | មិនមាន |
| 5 | សេវាសុំវិញ្ញាបនបត្រថ្មីជំនួសវិញ្ញាបនបត្រចាស់ដែលបាត់សម្រាប់អ្នកដេញថ្លៃទទួលសាងសង់ | មិនមាន |
| II | **អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ** | |
| 6 | សេវាផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនធានារ៉ាប់រង ( ទូទៅ ឬអាយុជីវិត ) ឬសាខាក្រុមហ៊ុនបរទេស | មិនមាន |
| 7 | សេវាផ្តល់អាជ្ញាបណ្ណជើងសាធានារ៉ាប់រង | មិនមាន |
| 8 | សេវាផ្តល់អាជ្ញាបណ្ណភ្នាក់ងារធានារ៉ាប់រងនីតិបុគ្គល | មិនមាន |
| 9 | សេវាផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង | មិនមាន |
| 10 | សេវាផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច (បណ្តោះអាសន្ន) | មិនមាន |
| 11 | សេវាផ្តល់វិញ្ញាបនបត្រសាខាក្នុងស្រុក របស់ក្រុមហ៊ុនធានារ៉ាប់រង | មិនមាន |
| 12 | សេវាផ្តល់ការអនុញ្ញាតសម្រាប់ការផ្លាស់ប្តូរទីតាំង ឬ ភាគទុនិក ឬ សមាជិកក្រុមប្រឹក្សាភិបាល ឬ អគ្គនាយក ឬ នាយកប្រតិបត្តិ របស់គ្រឹះស្ថានធានារ៉ាប់រង | មិនមាន |
| 13 | សេវាផ្តល់ការអនុម័តលើផលិតផលធានារ៉ាប់រងថ្មីមួយ | មិនមាន |
| 14 | សេវាផ្តល់ការអនុម័តលើការកែប្រែផលិតផលធានារ៉ាប់រងមួយដែលមានស្រាប់ | មិនមាន |
| 15 | សេវាផ្តល់ការអនុញ្ញាតបន្ថយដើមទុន ឬបង្កើនដើមទុន | មិនមាន |
| 16 | សេវាផ្តល់ការអនុម័តលើសំណើសុំតែងតាំងសវនករឯករាជ្យ | មិនមាន |
| 17 | សេវាផ្តល់លិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មរបស់គ្រឹះស្ថានធានារ៉ាប់រង | មិនមាន |
| 18 | សេវាពិគ្រោះយោបល់លើការបកស្រាយខ្លឹមសារច្បាប់ និង បទប្បញ្ញត្តិស្តីពីការធានារ៉ាប់រង ឬ នីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណធានារ៉ាប់រង | មិនមាន |
| 19 | សេវាផ្តល់បទឧទ្ទេសនាមស្តីពីវិស័យធានារ៉ាប់រងក្នុងអង្គសិក្ខាសាលា ឬ ពិធីផ្សេងៗ | មិនមាន |
| 20 | សេវាបន្តសុពលភាពក្រុមហ៊ុនធានារ៉ាប់រង ( ទូទៅ អាយុជីវិត ឬ បន្ត ) ឬ សាខាក្រុមហ៊ុនបរទេស | មិនមាន |
| 21 | សេវាបន្តសុពលភាពអាជ្ញាបណ្ណជើងសាធានារ៉ាប់រង | មិនមាន |
| 22 | សេវាបន្តសុពលភាពអាជ្ញាបណ្ណភ្នាក់ងារធានារ៉ាប់រងនីតិបុគ្គល | មិនមាន |
| 23 | សេវាបន្តសុពលភាពអាជ្ញាបណ្ណក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង | មិនមាន |

| ល.រ | ឈ្មោះសេវា | ប្រព័ន្ធ IT |
|---|---|---|
| 24 | សេវាបន្តសុពលភាពអាជ្ញាបណ្ណក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច (បណ្ដោះអាសន្ន) | មិនមាន |
| 25 | សេវាបន្តសុពលភាពវិញ្ញាបនបត្រសាខាក្នុងស្រុករបស់ក្រុមហ៊ុនធានារ៉ាប់រង | មិនមាន |
| 26 | សេវាផ្តល់ការអនុញ្ញាតបន្ថយដើមទុន ឬ បង្កើនដើមទុនរបស់ក្រុមហ៊ុនជើងសាធានារ៉ាប់រង | មិនមាន |
| 27 | សេវាផ្តល់ការអនុម័តលើករណីស្នើសុំតែងតាំងអ្នកជំនាញគណនាតម្លៃហានិភ័យធានារ៉ាប់រង | មិនមាន |
| 28 | សេវាផ្តល់វិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ | មិនមាន |
| 29 | សេវាផ្តល់ការអនុញ្ញាតផ្លាស់ប្តូរលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ | មិនមាន |
| 30 | សេវាពិគ្រោះយោបល់លើខ្លឹមសារច្បាប់ និង បទប្បញ្ញត្តិទាក់ទងបរធនបាលកិច្ចហិរញ្ញវត្ថុ | មិនមាន |
| 31 | សេវាផ្តល់អាជ្ញាបណ្ណកាស៊ីណូ | មិនមាន |
| 32 | សេវាបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ | មិនមាន |
| 33 | សេវាផ្ទេរសិទ្ធិកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ | មិនមាន |
| 34 | សេវាផ្តល់ការអនុញ្ញាតនាំចូលឧបករណ៍ល្បែង | មិនមាន |
| 35 | សេវាផ្តល់អាជ្ញាបណ្ណឆ្នោត-ឡូតូ | មិនមាន |
| 36 | សេវាបន្តសុពលភាពអាជ្ញាបណ្ណឆ្នោត-ឡូតូ | មិនមាន |
| 37 | សេវាផ្តល់វិញ្ញាបនបត្រឆ្នោត-ឡូតូ | មិនមាន |
| 38 | សេវាបន្តសុពលភាពវិញ្ញាបនបត្រឆ្នោត-ឡូតូ | មិនមាន |
| 39 | សេវាផ្តល់ការអនុញ្ញាតដំណើរការប្រភេទឆ្នោត | មិនមាន |
| 40 | សេវាផ្ទេរសិទ្ធិកាន់កាប់អាជ្ញាបណ្ណឆ្នោត | មិនមាន |
| 41 | សេវាផ្ទេរសិទ្ធិកាន់កាប់វិញ្ញាបនបត្រឆ្នោត | មិនមាន |
| 42 | វិញ្ញាបនបត្រវិជ្ជាជីវៈ និង អាជ្ញាបណ្ណវាយតម្លៃភ្នាក់ងារអចលនវត្ថុ និង គ្រប់គ្រងអចលនវត្ថុ | មិនមាន |
| 43 | សេវាផ្តល់អាជ្ញាបណ្ណអភិវឌ្ឍលំនៅឋាន | មិនមាន |
| 44 | សេវាផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន | មិនមាន |
| III | **ក្រុមប្រឹក្សាជាតិគណនេយ្យ** | មិនមាន |
| 45 | សេវាចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មគណនេយ្យ និងសវនកម្ម | មិនមាន |
| 46 | សេវាបន្តសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មគណនេយ្យនិងសវនកម្ម | មិនមាន |
| 47 | សេវាចេញលិខិតអនុញ្ញាតផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ | មិនមាន |
| 48 | សេវាចេញលិខិតអនុញ្ញាតបដិប្បញ្ញត្តិដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្ម | មិនមាន |

| ល.រ | ឈ្មោះសេវា | ប្រព័ន្ធ IT |
|---|---|---|
| 49 | សេវាកម្មទទួល រក្សាទុក របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចដោយសហគ្រាស | មិនមាន |
| VI | **អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** | |
| 50 | សេវាផ្ដល់អាជ្ញាបណ្ណជើងសាគយ | មាន |
| 51 | សេវាផ្ដល់អាជ្ញាបណ្ណកណ្ណាគារគយមានដែនកំណត់ | មាន |
| 52 | សេវាផ្ដល់អាជ្ញាបណ្ណសន្និធិគយបណ្ដោះអាសន្ន | មាន |
| 53 | សេវាផ្ដល់លិខិតអនុញ្ញាតគយ | មាន |
| 54 | សេវាផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ | មាន |
| 55 | សេវាផ្ទៀងផ្ទាត់វិញ្ញាបនបត្រដើមកំណើតទំនិញ | មាន |
| 56 | ការផ្ដល់សេវាតាមវិធានបញ្ជាក់ជាមុន ( Advance Ruling ) | មាន |
| 57 | សេវាពាក់ព័ន្ធការបំពេញបែបបទបញ្ចេញទំនិញពីគយលើទំនិញនាំចូល និង ទំនិញឆ្លងកាត់ | មាន |
| 58 | សេវាពាក់ព័ន្ធការបំពេញបែបបទបញ្ចេញទំនិញពីគយលើទំនិញនាំចេញ | មាន |
| 59 | សេវាផ្ដល់ប័ណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូន | មាន |
| 60 | សេវាផ្ដល់ប្រឹក្សាអំពីនីតិវិធីគយ | មាន |
| 61 | សេវាចុះបញ្ជីធុរជនចូលប្រព័ន្ធគ្រប់គ្រងហានិភ័យគយ | មាន |
| 62 | សេវាកែតម្រូវ ឬ ធ្វើទុតិយតាបង្កាន់ដៃពន្ធ និង លតាបត្រ | មាន |
| 63 | សេវាផ្ដល់លិខិតរាយការណ៍គយសម្រាប់អ្នកដំណើរចូលព្រះរាជាណាចក្រកម្ពុជា | មាន |
| 64 | សេវាលក់តែមប្រឹអាករសម្រាប់បិទលើកញ្ចប់បារី | មាន |
| IV | **អគ្គនាយកដ្ឋានពន្ធដារ** | |
| 65 | សេវាចុះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធធំ ដែលជាសហគ្រាសបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស | មាន |
| 66 | សេវាចុះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធធំ នៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ( QIP ) | មាន |
| 67 | សេវាចុះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធមធ្យម ដែលជាសហគ្រាស និង ការិយា-ល័យតំណាង | មាន |
| 68 | សេវាចុះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធមធ្យម នៃអង្គការ និង សមាគមនានា | មាន |
| 69 | សេវាចុះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធមធ្យម ដែលជាស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាល និង គណបក្សនយោបាយ | មាន |

| ល.រ | ឈ្មោះសេវា | ប្រព័ន្ធ IT |
|---|---|---|
| 70 | សេវាចុះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធតូច ដែលជាសហគ្រាសឯកបុគ្គល និង សហកម្មសិទ្ធិ | មាន |
| 71 | សេវាចុះបញ្ជីពន្ធដារសម្រាប់អ្នកជាប់ពន្ធដទៃទៀត | មាន |
| 72 | សេវាបច្ចុប្បន្នភាពព័ត៌មានសម្រាប់អ្នកជាប់ពន្ធធំ ដែលជាសហគ្រាសបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស | មាន |
| 73 | សេវាបច្ចុប្បន្នភាពព័ត៌មានសម្រាប់អ្នកជាប់ពន្ធធំ នៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) | មាន |
| 74 | សេវាបច្ចុប្បន្នភាពព័ត៌មានសម្រាប់អ្នកជាប់ពន្ធមធ្យម ដែលជាសហគ្រាស និង ការិយាល័យតំណាង | មាន |
| 75 | សេវាបច្ចុប្បន្នភាពព័ត៌មានសម្រាប់អ្នកជាប់ពន្ធមធ្យម នៃអង្គការ និង សមាគមនានា | មាន |
| 76 | សេវាបច្ចុប្បន្នភាពព័ត៌មានសម្រាប់អ្នកជាប់ពន្ធមធ្យម ដែលជាស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាល និង គណបក្សនយោបាយ | មាន |
| 77 | សេវាបច្ចុប្បន្នភាពព័ត៌មានសម្រាប់អ្នកជាប់ពន្ធតូច ដែលជាសហគ្រាសឯកបុគ្គល និង សហកម្មសិទ្ធិ | មាន |
| 78 | សេវាបច្ចុប្បន្នភាពព័ត៌មានសម្រាប់អ្នកជាប់ពន្ធដទៃទៀត | មាន |
| 79 | សេវាពិគ្រោះយោបល់តាមទូរសព្ទ-១២៧៧ (GDT-Call Center:1277) | មាន |
| 80 | សេវាកម្មវិធីជជែកផ្ទាល់ពីពន្ធដារ (GDT-Live Chat) | មាន |
| 81 | សេវាអ៊ីមែល (Email) | មាន |
| 82 | សេវាលិខិតជាលាយលក្ខណ៍អក្សរ (Letter) | មិនមាន |
| 83 | សេវាពិគ្រោះយោបល់ផ្ទាល់ (Face to Face) | មិនមាន |
| 84 | សេវាទទួលលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ នៃពន្ធតែមប្រើសារពើពន្ធ (ស្លាកអាជីវកម្មដ្ឋាន និង ផ្ទាំងផ្សាយពាណិជ្ជកម្ម) | មាន |
| 85 | សេវាទទួលលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ នៃពន្ធប៉ាតង់សម្រាប់អ្នកជាប់ពន្ធតូច មធ្យម និង ធំ | មាន |
| 86 | សេវាទទួលលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ នៃពន្ធលើប្រាក់ចំណូលសម្រាប់អ្នកជាប់ពន្ធតូច | មាន |
| 87 | សេវាទទួលលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ នៃពន្ធលើប្រាក់ចំណូលសម្រាប់អ្នកជាប់ពន្ធមធ្យម និង អ្នកជាប់ពន្ធធំ | មាន |
| 88 | សេវាទទួលលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ នៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ | មាន |

| ល.រ | ឈ្មោះសេវា | ប្រព័ន្ធ IT |
|---|---|---|
| 89 | សេវាទទួលលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ នៃពន្ធលើអចលនទ្រព្យ | មាន |
| 90 | សេវាទទួលលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ នៃពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ | មាន |
| 91 | សេវាទទួលលិខិតប្រកាសពន្ធប្រចាំខែ នៃពន្ធលើឈ្នួលផ្ទះ និង ដី | មាន |
| 92 | សេវាទទួលលិខិតប្រកាសពន្ធប្រចាំខែ សម្រាប់អ្នកជាប់ពន្ធតូច | មាន |
| 93 | សេវាទទួលលិខិតប្រកាសពន្ធប្រចាំខែ នៃពន្ធលើប្រាក់បៀវត្សសម្រាប់អ្នកជាប់ពន្ធមធ្យម និង អ្នកជាប់ពន្ធធំ | មាន |
| 94 | សេវាទទួលលិខិតប្រកាសពន្ធប្រចាំខែ នៃពន្ធកាត់ទុកសម្រាប់អ្នកជាប់ពន្ធមធ្យម និង អ្នកជាប់ពន្ធធំ | មាន |
| 95 | សេវាទទួលលិខិតប្រកាសពន្ធប្រចាំខែ នៃអាករលើតម្លៃបន្ថែមសម្រាប់អ្នកជាប់ពន្ធមធ្យម និង អ្នកជាប់ពន្ធធំ | មាន |
| 96 | សេវាទទួលលិខិតប្រកាសពន្ធប្រចាំខែ នៃប្រាក់រំដោះពន្ធលើប្រាក់ចំណូល អាករពិសេសលើទំនិញ និង សេវាមួយចំនួន អាករបំភ្លឺសាធារណៈ និង ពន្ធអាករផ្សេងៗ សម្រាប់អ្នកជាប់ពន្ធមធ្យម និង អ្នកជាប់ពន្ធធំ | មាន |
| 97 | សេវាលិខិតប្រកាសពន្ធប្រថាប់ត្រា នៃឯកសារមានលក្ខណៈគតិយុត្ត ស្តីពីការបង្កើតក្រុមហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និង ការបិទក្រុមហ៊ុន | មាន |
| 98 | សេវាលិខិតប្រកាសពន្ធប្រថាប់ត្រា នៃការផ្ទេរភាគហ៊ុន | មាន |
| 99 | សេវាលិខិតប្រកាសពន្ធប្រថាប់ត្រា នៃកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬ សេវាដែលប្រើ-ប្រាស់ថវិការដ្ឋ | មាន |
| 100 | សេវាពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យដែលមានតម្លៃចាប់ពី ១០០ លានរៀលឡើងទៅ ឬ ប្រាក់ពន្ធចាប់ពី ៤ លានរៀលឡើងទៅ | មាន |
| 101 | សេវាពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យលក្ខណៈប្រទានកម្ម ឬ សន្តតិកម្ម និង អចលនទ្រព្យដែលមានតម្លៃក្រោម ១០០ លានរៀល ឬ មានប្រាក់ពន្ធក្រោម ៤ លានរៀល | មាន |
| 102 | សេវាពន្ធប្រថាប់ត្រា នៃការផ្ទេរកម្មសិទ្ធិយានយន្ត | មាន |
| 103 | សេវាលើសំណើសុំអនុញ្ញាតទូទាត់បំណុលពន្ធតាមរយៈកិច្ចព្រមព្រៀងទូទាត់ជាដំណាក់កាល | មាន |
| 104 | សេវាដោះស្រាយបណ្តឹងតវ៉ាពន្ធដារ | មាន |
| 105 | សេវាផ្តល់អាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ | មាន |
| 106 | សេវាផ្តល់វិញ្ញាបនបត្របញ្ជាក់ស្ថានភាពសារពើពន្ធ | មាន |
| 107 | សេវាផ្តល់វិញ្ញាបនបត្រនិវាសនជន | មាន |

| ល.រ | ឈ្មោះសេវា | ប្រព័ន្ធ IT |
|---|---|---|
| 108 | សេវាផ្តល់វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ | មាន |
| 109 | សេវាផ្តល់វិញ្ញាបនបត្រលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសធុនតូច និង មធ្យមដែលបានចុះបញ្ជីស្ម័គ្រចិត្ត | មាន |
| 110 | សេវាផ្តល់ការអនុវត្តអត្រាសូន្យនូវអាករលើតម្លៃបន្ថែម | មាន |
| 111 | សេវាផ្តល់លិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញ ឬ សេវាក្នុងនាមសហគ្រាសដើម | មាន |
| 112 | សេវាលើការលើកលែងពន្ធលើប្រាក់ចំណូលសម្រាប់អ្នកជាប់ពន្ធធំ | មាន |
| 113 | សេវាផ្តល់ការអនុញ្ញាតឱ្យទទួលអត្ថប្រយោជន៍នានា នៃកិច្ចព្រមព្រៀងស្តីពីការ ចៀសវាងការយកពន្ធត្រួតគ្នា | មាន |
| 114 | សេវាលើការបង្វិលសងអាករលើតម្លៃបន្ថែមចំពោះអ្នកជាប់ពន្ធមធ្យម និង អ្នក ជាប់ពន្ធធំ | មាន |
| 115 | សេវាលើការស្នើសុំប្តូរឆ្នាំជាប់ពន្ធ | មាន |
| 116 | សេវាផ្តល់ប័ណ្ណសម្គាល់ការបង់ពន្ធ និង ការស្នើសុំបោះពុម្ពសារជាថ្មី | មាន |
| 117 | សេវាលក់តែមប្រើអាករ | មាន |
| 118 | សេវាបណ្តុះបណ្តាលភ្នាក់ងារសេវាកម្មពន្ធដារ | មាន |
| 119 | សេវាបណ្តុះបណ្តាល ស្តីពីពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក និង ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូល | មាន |
| 120 | សេវាបណ្តុះបណ្តាលស្តីពីកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធតូច | មាន |
| 121 | សេវាបណ្តុះបណ្តាលស្តីពីការបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (E-Payment) | មាន |
| 122 | សេវាបណ្តុះបណ្តាលស្តីពីប្រព័ន្ធបង្វិលសង អតប (E-VAT Refund) | មាន |
| 123 | សេវាផ្តល់សិទ្ធិប្រឡងភ្នាក់ងារសេវាកម្មពន្ធដារ ចំពោះសិក្ខាកាមដែលបានចូលរួម វគ្គបណ្តុះបណ្តាលនៅសាលាជាតិពន្ធដារ | មាន |
| 124 | សេវាផ្តល់សិទ្ធិប្រឡងភ្នាក់ងារសេវាកម្មពន្ធដារ ចំពោះសិក្ខាកាមដែលមិនបាន ចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាជាតិពន្ធដារ | មាន |
| V | **អគ្គនាយកដ្ឋានរតនាគារ** | |
| 125 | ការត្រួតពិនិត្យ បើកប្រាក់ និង លិខិតយុត្តិការចំណាយដើម្បីផ្តល់ការទូទាត់ ចំណាយថវិកា | មិនមាន |
| 126 | ការផ្តល់ដីកាអមបញ្ចេញអាណត្តិអាណត្តិបើកប្រាក់ | មិនមាន |
| 127 | ការផ្តល់លិខិតប្រកាសឥណទានពីការកាត់ពន្ធអាករ | មាន |
| 128 | ការផ្តល់លិខិតប្រកាសឥណទានលើការកាត់ពន្ធលើប្រាក់បៀវត្ស | មាន |
| 129 | ការផ្តល់លិខិតជូនដំណឹងឥណទានស្តីពី ចំណូលពន្ធដារ និង ពន្ធគយ | មាន |

| ល.រ | ឈ្មោះសេវា | ប្រព័ន្ធ IT |
|---|---|---|
| 130 | ការផ្តល់លិខិតជូនដំណឹងឥណទានស្តីពី ចំណូលពន្ធដារមកពីរាជធានី-ខេត្ត | មាន |
| 131 | សេវាទូទាត់ បើកផ្តល់ និង បង្វែរប្រាក់ | មាន |
| 132 | ការផ្តល់លិខិតធានាប្រាក់កក់ | មិនមាន |
| 133 | ការដកប្រាក់កក់ | មាន |

## ឧបសម្ព័ន្ធទី ៣: ប្រកាសស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅក្រុមប្រឹក្សា IT នៃ កសហវ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.៣៦៩.......សហវ.ប្រក

**ប្រកាស**
**ស្ដីពី**
**ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន**
**នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ត្រូវបានបង្កើត ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា **ក.ប.ព**. ដើម្បីដឹកនាំសម្របសម្រួល និងជំរុញការកសាង និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រកបដោយដវភាព សង្គតិភាព និងសុខដុមភាព សំដៅកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងចូលរួមចំណែកដល់ការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ ក.ប.ព

**ប្រការ២.-**

**ក.ប.ព**. មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យ និងគោលការណ៍អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងតម្រង់ទិសលើការរៀបចំផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីកសាង និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងជំរុញការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងជំរុញការកសាងនិងការអភិវឌ្ឍភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចឌីជីថលនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សម្រេច និងដាក់ឱ្យអនុវត្តស្តង់ដារបច្ចេកទេស ស្តង់ដារសន្តិសុខឌីជីថល ស្តង់ដារនីតិវិធីប្រតិបត្តិ និងសេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ដឹកនាំ សម្របសម្រួល និងដោះស្រាយការងារនិងបញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរអង្គភាពពាក់ព័ន្ធនឹងគម្រោងបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កៀរគរធនធានហិរញ្ញវត្ថុ, ធនធានបច្ចេកទេស និងធនធានមនុស្ស ក្នុងបុព្វហេតុអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពិនិត្យ និងសម្រេចលើការស្នើសុំថវិកាគាំទ្រគម្រោងបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ជំរុញលើកទឹកចិត្ត និងគាំទ្រការចូលរួមលើកស្ទួយការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញតួនាទីនិងភារកិច្ចដទៃទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## សមាសភាព ក.ប.ព.

**ប្រការ៣.-**

**ក.ប.ព.**មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប | អនុប្រធានប្រចាំការ |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | អនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| - អនុរដ្ឋលេខាធិការពាក់ព័ន្ធមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **ក.ប.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ប.ព.

**ប្រការ៤.-**

អនុប្រធាននិងសមាជិក **ក.ប.ព.**ត្រូវចូលរួមកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។

ក្នុងករណីអវត្តមានឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ឬអនុប្រធានប្រចាំការ ឱ្យកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំ។

**ប្រការ៥.-**

**ក.ប.ព**មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

**ប្រការ៦.-**

**ក.ប.ព.** មានក្រុមការងារបច្ចេកទេសមួយជាសេនាធិការ នៅក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។

ក្រុមការងារបច្ចេកទេស **ក.ប.ព.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - អនុប្រធានប្រចាំការនៃ **ក.ប.ព.** | ប្រធាន |

- ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានប្រចាំការ
- ប្រធានអង្គភាព ឬអនុប្រធានប្រចាំការទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាននៃអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយចំនួន អនុប្រធាន
- ប្រធាននាយកដ្ឋានទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រុមការងារទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

សមាសភាពជាក់ស្តែងនៃក្រុមការងារបច្ចេកទេស **ក.ប.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧.-**

ក្រុមការងារបច្ចេកទេស **ក.ប.ព.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួលលើការងារអនុវត្តផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីកសាងនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សហការការងារជាមួយនឹងអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក់ព័ន្ធការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កសាង អភិវឌ្ឍ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្នាលឌីជីថលសម្រាប់ការប្រើប្រាស់រួម
- រៀបចំស្តង់ដារបច្ចេកទេស ស្តង់ដារសន្តិសុខឌីជីថល ស្តង់ដារនីតិវិធីប្រតិបត្តិ និងសេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ផ្តួចផ្តើម និងកំណត់កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ និងរៀបចំទស្សនកិច្ចសិក្សាទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីទាញយកបទពិសោធន៍និងប្រមូលធាតុចូលសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- រៀបចំឱ្យមានការបណ្តុះបណ្តាល ការពង្រឹងសមត្ថភាព និងការចែករំលែកចំណេះដឹងទៅលើការអភិវឌ្ឍ ការប្រតិបត្តិ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលនានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំផែនការវិនិយោគ ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- ពិនិត្យ ពិភាក្សា វាយតម្លៃ និងធ្វើអាទិភាពរូបនីយកម្មគម្រោងបច្ចេកវិទ្យាព័ត៌មានដែលបានស្នើក្នុងក្របខណ្ឌការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពនៃថវិកា និងសង្គតិភាពជាមួយផែនការមេបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយត្រូវរៀបចំរបាយការណ៍ជូន **ក.ប.ព.**

- បំពេញតួនាទីនិងភារកិច្ចដទៃទៀត តាមការប្រគល់របស់ប្រធានក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨.-**

ក្រុមការងារបច្ចេកទេស **ក.ប.ព.** មាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋានក្រុមការងារបច្ចេកទេស **ក.ប.ព.** បំពេញមុខងារជាសេនាធិការជូនក្រុមការងារបច្ចេកទេស **ក.ប.ព.** លើការងាររដ្ឋបាល និងបច្ចេកទេស។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ